ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 04-Apr-2011, 09:18
CMS/CFO: Uch Arun

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Court Suprême

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីលើ "បណ្តឹងសាទុក្ខ", កាំង ហ្គេកអ៊ាវ ហៅ ឌុច
# សាធារណៈ

សំណុំរឿងលេខៈ ០០១/១៨-០៧-២០០៧-អវតក/អជតក

**ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១១**

**ម៉ោង ០៨: ៥៣នាទី**

**ចៅក្រមជំនុំជម្រះ៖**

ចៅក្រម គង់ ស្រីម ជាប្រធាន
ចៅក្រម ស៊ិន រិទ្ធ
ចៅក្រម ម៉ូតូ ណូហ្គូជិ
*(Judge Motoo NOGUCHI)*
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត
*(Judge Agnieszka KLONOWIECKA-MILART)*
ចៅក្រម យ៉ា ណារិន
ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហ៍
*(Judge Chandra Nilhal JAYASINGHE)*
ចៅក្រម ម៉ុង មន្នីចរិយា (បម្រុង)
ចៅក្រម ផ្លូរិន ម៉ុមបា (បម្រុង)
*(Judge Florence Mumba)*

**ក្រឡាបញ្ជី៖**

លោក ស៊ា ម៉ៅ
លោក គ្រីស្តូហ្វឺ ម៉ាក រីយ៉ាន
*(Mr. Christopher Mark Ryan)*
លោក ផន ធឿន

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង
លោក អាន់ឌ្រូ ខេលី *(Mr.Andrew CAYLEY)*
លោក ពេជ សម្បត្តិ
លោក សេង ប៊ុនឃាង

**មេធាវីការពារជនត្រូវចោទ កាំង ហ្គេកអ៊ាវ:**

លោក ការ សាវុត្ថ
លោក កង ឫទ្ធារី

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោកស្រី ស៊ីលឃី ស្ទួតហ្ស៊ីនស្គី
*(Ms. Silke Studzinsky)*

លោកស្រី ទី ស្រ៊ីនណា

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី ម៉ាទីន ហ្សាកកាំង
*(Ms. Martine Jacquing)*

លោក ហ្វីលីព កាណុន
*(Mr. Philippe Canonne)*

លោក គឹម ម៉េងឃី

លោកស្រី អេលីហ្សាប៊ែត រ៉ាបេសាន់ដ្រាតាណា
*(Ms. Elisabeth RABESANDRATANA)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

**បញ្ជីឈ្មោះអ្នកនិយាយៈ**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម គង់ ស្រីម (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ម៉ូតូ ណូហ្គូជិ | អង់គ្លេស |
| ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត | អង់គ្លេស |
| ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហ៍ | អង់គ្លេស |
| ចៅក្រម សោម សិរិវឌ្ឍ | ខ្មែរ |
| លោកស្រី ជា លាង | ខ្មែរ |
| លោក អាន់ឌ្រូ ខេលី | អង់គ្លេស |
| លោក ការ សាវុត្ថ | ខ្មែរ |
| លោក កង ឫទ្ធារី | ខ្មែរ |
| លោក ផន ធឿន (ក្រឡាបញ្ជី) | ខ្មែរ |
| លោក គីម ម៉េងឃី | ខ្មែរ |
| ជនជាប់ចោទ | ខ្មែរ |
| | |

# កិច្ចដំណើរការនីតិវិធី

[០៨:៥៣:១៩]

**លោក ស៊ា ម៉ៅ៖**

ខ្ញុំបាទឈ្មោះ ស៊ា ម៉ៅ ជាក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល សូមការអនុញ្ញាតអាននូវបទបញ្ជាផ្ទៃក្នុងគ្រប់គ្រងសាលសវនាការក្នុងថ្ងៃសវនាការដូចតទៅ៖

បទបញ្ជាផ្ទៃក្នុងគ្រប់គ្រងសាលសវនាការក្នុងថ្ងៃសវនាការរបស់អង្គជំនុំជម្រះតុលាការកំពូល លេខ ៧៧-អវតក-អជតក។

ដើម្បីរក្សាបាននូវសណ្តាប់ធ្នាប់របៀបរៀបរយ សន្តិសុខ និងដំណើរការល្អក្នុងពេលសវនាការ ប្រធានអង្គជំនុំជម្រះតុលាការកំពូលសម្រេចដាក់ចេញនូវបទបញ្ជាផ្ទៃក្នុងគ្រប់គ្រងសាលសវនាការក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខដូចខាងក្រោម៖

១) អ្នកដែលមានបំណងចូលរួមក្នុងសវនាការទាំងអស់ ត្រូវមានវត្តមានក្នុងសាលសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជាឲ្យបានមុនម៉ោង៨:៣០ ព្រឹក និងមុនម៉ោង១:៣០នាទីល្ងាច។

២) សាធារណជននិងភាគីទាំងអស់ត្រូវក្រោកឈរនៅពេលដែលក្រឡាបញ្ជីបញ្ជាក់ថា "ក្រោកឈរ" ហើយត្រូវអង្គុយចុះនៅពេលដែលប្រធានអង្គជំនុំជម្រះតុលាការកំពូលប្រកាសឲ្យ "អង្គុយចុះ"។

៣) អ្នកចូលរួមក្នុងសាលសវនាការត្រូវមានអាកប្បកិរិយាថ្លៃថ្នូរ សមរម្យជានិច្ច។ អ្នកចូលរួមត្រូវស្លៀកពាក់សមរម្យ មិនត្រូវបង្ហាញពាក្យស្លោក ការគាំទ្រដល់ភាគីណាមួយនៃដំណើរការនីតិវិធី ឬប្រើពាក្យសម្តីដែលមិនសមរម្យឡើយ។

៤) ហាមយកម៉ាស៊ីនថតរូបភាព ម៉ាស៊ីនថតវីដេអូ ឧបករណ៍ថតសំឡេង និងឧបករណ៍បំពងសំឡេងគ្រប់ប្រភេទពីខាងក្រៅចូលក្នុងសាលសវនាការឡើយ។ លើកលែងតែមានការអនុញ្ញាត ដោយអង្គជំនុំជម្រះតុលាការកំពូល។

៥) ហាមជក់បារី ឬយកចំណីអាហារ ភេសជ្ជៈគ្រប់ប្រភេទចូលក្នុងសាលសវនាការ។

៦) ហាមយកអាវុធជាតិផ្ទុះគ្រប់ប្រភេទចូលក្នុងសាលសវនាការ លើកលែងតែសន្តិសុខដែលមានសមត្ថកិច្ច។

៧) ហាមប្រើប្រាស់ទូរស័ព្ទគ្រប់ប្រភេទក្នុងសាលសវនាការ។ ហាមថតរូបភាព ឬថតសំឡេងតាមគ្រប់មធ្យោបាយ លើកលែងតែមានការអនុញ្ញាតពីប្រធានអង្គជំនុំជម្រះតុលាការកំពូល។

៨) ហាមប្តូរកន្លែងអង្គុយ ឬដើររហេតរហូតក្នុងសាលសវនាការ។

៩) ហាមទះដៃ ឬស្រែកជយឃោស ឬស្រែកឡូឡា ឬការធ្វើឱ្យមានសំឡេងខ្លាំង ដែលនាំឱ្យរំខានដល់ដំណើរការសាលសវនាការ។

១០) ហាមដើរចេញចូលដោយអនាធិបតេយ្យនៅពេលសវនាការ។ ការចេញចូលត្រូវមានការអនុញ្ញាតពីកម្លាំងសន្តិសុខរក្សាសណ្តាប់ធ្នាប់ក្នុងសាលសវនាការ។

១១) ហាមកុមារដែលមានអាយុក្រោមតិចជាង ១៦ឆ្នាំចូលក្នុងសាលសវនាការ។ កុមារដែលមានអាយុចាប់ ពី១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំ អាចចូលក្នុងសាលសវនាការបាន បើសិនជាគាត់មកជាមួយឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាល លើកលែងតែកុមារណាដែលត្រូវចូលរួមក្នុងនាមជាដើមបណ្តឹងរដ្ឋប្ប-វេណី ឬជាសាក្សី។

១២) ក្នុងករណីមានបុគ្គលប្រព្រឹត្តល្មើសនឹងបទបញ្ជាផ្ទៃក្នុងនេះ ប្រធានអង្គជំនុំជម្រះតុលាការកំពូលនឹងចាត់វិធានការដើម្បីរារាំង ឬទប់ស្កាត់ភ្លាម តាមករណីសមស្របផ្អែកតាមវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងតាមបទប្បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជាជាធរមាន។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១១

ហត្ថលេខា និង ត្រា

គង់ ស្រ៊ឹម

បាទ, សូមអរគុណ។

[០៩:០០:២៩]

*(ចៅក្រមចូលមកកាន់បន្ទប់សវនាការ)*

**លោក ស៊ា ម៉ៅៈ**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំៈ**

បាទ, សូមអញ្ជើញអង្គុយចុះ!

**ប្រធានអង្គជំនុំៈ**

តាងនាមអង្គការសហប្រជាជាតិ និងតាងនាមប្រជារាស្ត្រខ្មែរ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រកាសបើកសវនាការដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខរបស់

ភាគីប្រឆាំងនឹងសាលក្រមចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងសំណុំរឿងលេខ០០១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ដែលមានជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ។

សមាសភាពអង្គជំនុំជម្រះតុលាការកំពូលនៅពេលនេះរួមមានៈ ១) ខ្ញុំ គង់ ស្រ៊ឹម ជាប្រធាន, ២) លោកចៅក្រម ម៉ូត្វ ណូហ្គូជិ, ៣) លោកចៅក្រម សោម សិរិវឌ្ឍ, ៤) លោកចៅក្រម អាកនីស្កាក្លូណ្សូវឹកកា មីឡាត, ៥) ចៅក្រម សុិន រិទ្ធ, ៦) ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហ៍, ៧) ចៅក្រម យ៉ា ណារិន។ ចៅក្រមបម្រុង ចៅក្រម ម៉ុង មុន្នីចរិយា និងចៅក្រម ផ្លូរិន ម៉ុមបា។ ក្រឡាបញ្ជីនាសវនាការនៅពេលនេះ ១) លោក ស៊ា ម៉ៅ, ២) លោក គ្រីស្តូហ្វើ ម៉ាក រីយ៉ាន, ៣) លោក ផន ធឿន។

**ប្រធានអង្គជំនុំៈ**

លោកក្រឡាបញ្ជី, តើភាគីនិងមេធាវីមានវត្តមានគ្រប់ចំនួនហើយឬនៅពេលនេះ?

[០៩:០៣:៣០]

**លោក ស៊ា ម៉ៅៈ**

សូមគោរពប្រសាសន៍ឯកឧត្តមប្រធាន, ភាគីគ្រប់អស់ហើយ គឺទី១) ខាងសហព្រះរាជអាជ្ញាមាន លោកជំទាវ ជា លាង, មានលោក អាន់ឌ្រូ ខេលី ជាសហព្រះរាជអាជ្ញា។ មានខាងជនជាប់ចោទមាន លោក ការ សាវុត្ថ ជាសហមេធាវី និងលោក កង ឫទ្ធារី ជាសហមេធាវីជនជាប់ចោទ ហើយនិងមានវត្តមានរបស់លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាជនជាប់ចោទមានវត្តមាននៅទីនេះ។

រីឯខាងដើមបណ្តឹងរដ្ឋប្បវេណីមានវត្តមានក្រុមមួយ គឺមានមេធាវី លោកស្រី ទី ស្រ៊ីនណា, មានលោក ការីម ខាន, ដោយអវត្តមានរបស់លោក អាឡាំង វ៉ែនណឺ។ រីឯក្រុមពីរ មានកញ្ញា ស៊ីលឃីស្ទូតហ្វ៊ីនស្តិ តំណាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ មានលោក ហុង គឹមសួន ជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ។ លោកស្រី ម៉ុច សុវណ្ណារី ជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី, លោក គឹម ម៉េងឃី ជាមេធាវី ដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី ហើយនិងលោកស្រី អេលីហ្សាប៊េត រ៉ាបេសាន់ដ្រាតាណា ជំនួសលោកស្រី ម៉ាទីន ហ្សាកកាំង ជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី ហើយនិងលោក ហ្វីលីព កាណុន ជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមបីដែរ។

បាទ សូមអរគុណ។

[០៩:០៥:២០]

**ប្រធានអង្គជំនុំ៖**

អង្គសវនាការថា សំណុំរឿងលេខ០០១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ដែលមានជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំវិសាមញ្ញក្នុងតុលាការកម្ពុជាលើកយកជំនុំជម្រះចាប់ពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ និងបញ្ចប់កិច្ចពិភាក្សាដេញដោលនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ហើយនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០។ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំវិសាមញ្ញក្នុងតុលាការកម្ពុជា បានចេញសាលក្រមសម្រេច៖

[០៩:០៦:០០]

១) ការផ្តន្ទាទោស

អង្គជំនុំជម្រះសាលាដំបូងរកឃើញថា ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច មានពិរុទ្ធភាពតាមមាត្រា៥, ៦ និងមាត្រា២៩ថ្មី នៃច្បាប់ស្តីពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយដែលរួមបញ្ចូលនូវបទល្មើសនូវការសម្លាប់រង្គាល រួមបញ្ចូលទាំងការធ្វើមនុស្សឃាត ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម រួមទាំងការរំលោភផ្លូវភេទមួយករណីផងដែរ និងអំពើអមនុស្សធម៌ផ្សេងទៀត និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩។ មានការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្មនិងការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដោយរាងកាយ ឬសុខភាព។

[០៩:០៧:១៥]

ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិ ទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួន ជនស៊ីវិលដោយខុសច្បាប់ ដែលប្រព្រឹត្តនៅទីក្រុងភ្នំពេញ និងលើទឹកដីនៃប្រទេសកម្ពុជាក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ផ្តន្ទាទោសជនជាប់ចោទ ដាក់ពន្ធនាគារសរុបរួមកំណត់៣៥ឆ្នាំ ដោយកាត់បន្ថយទោសនេះចំនួន៥ឆ្នាំ ដោយសារការរំលោភសិទ្ធិលើជនជាប់ចោទក្នុងអំឡុងពេលឃុំខ្លួនខុសច្បាប់ នីតិវិធីរបស់តុលាការយោធាកម្ពុជាពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧។

[០៩:០៨:១២]

ជនជាប់ចោទត្រូវទទួលបានការទូទាត់នូវរយៈពេលឃុំខ្លួន នៅក្រោមសមត្ថកិច្ចតុលាការយោធា

កម្ពុជាពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ និងរយៈពេលឃុំខ្លួននៅក្រោមសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចាប់ពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ រហូតដល់សាលក្រមចូលស្ថាពរ។

[០៩:០៨:៤៣]

២)បទឧក្រិដ្ឋជាតិ

អង្គជំនុំជម្រះសាលាដំបូងមិនពិចារណាអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ពីបទឧក្រិដ្ឋជាតិនៃការធ្វើមនុស្សឃាតទុកជាមុន និងការធ្វើទារុណកម្មតាមមាត្រា ៥០១, ៥០៦, និងមាត្រា៥០០ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងតាមមាត្រា៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក ទេ។

[០៩:០៨:១២]

៣) សំណងរដ្ឋប្បវេណី

អង្គជំនុំជម្រះសាលាដំបូងប្រកាសថា ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ដែលមានក្នុងកថាខណ្ឌ ៦៤៥ និង៦៥០ នៃសាលក្រម ពិតជាបានទទួលរងគ្រោះដែលជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋដែល កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានរកឃើញថា មានពិរុទ្ធភាព និងបង្គាប់ថាអង្គជំនុំជម្រះត្រូវចងក្រងសេចក្ដីថ្លែងសុំអភ័យទោសទាំងអស់ និងការទទួលស្គាល់ ការទទួលខុសត្រូវដែល កាំង ហ្គេកអ៊ាវ ហៅ ឌុច បានធ្វើក្នុងអំឡុងពេលសវនាការនៅលើគេហទំព័រផ្លូវការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងរយៈពេល១៤ថ្ងៃ បន្ទាប់ពីសាលក្រមនេះចូលស្ថាពរ។

[០៩:១០:០៥]

ចំណែកការទាមទារទាំងអស់របស់ដើមបណ្ដឹងរដ្ឋប្បវេណី តុលាការកម្ពុជាក្នុងរយៈពេល១៤ថ្ងៃបន្ទាប់ពីសាលក្រមនេះចូលជាស្ថាពរ។ ចំណែកការទាមទារផ្សេងទៀតទាំងអស់របស់ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបដិសេធចោល។

[០៩:១០:១១]

៤) ការឃុំខ្លួន

អង្គជំនុំជម្រះសាលាដំបូង សម្រេចរក្សាជនជាប់ចោទនៅក្នុងមន្ទីរឃុំឃាំងនៃ អ.វ.ត.ក រហូតសាលក្រមចូលជាស្ថាពរ ឬរហូតដល់អង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក សម្រេចសេចក្ដីលើបណ្ដឹងសាទុក្ខ។

៥) ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី

ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន២៤ ដែលមាននៅក្នុងកថាខណ្ឌ ៦៤៧, ៦៤៨ និង៦៤៩ នៃសាលក្រម ត្រូវបានសាលាដំបូងបដិសេធចោលនូវឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី។

[០៩:១០:៥៦]

សាលក្រមនេះ ប្រកាសជាសាធារណៈនូវសាលសវនាការធំនៃ អ.វ.ត.ក នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ និងសម្រេចបើកផ្លូវប្តឹងសាទុក្ខដល់ភាគីតាមការកំណត់នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។

**អំពីបណ្តឹងសាទុក្ខ៖**

សាលក្រមនេះត្រូវបានភាគីនៃសំណុំរឿងនេះធ្វើបណ្តឹងសាទុក្ខមកអង្គជំនុំជម្រះតុលាការកំពូល៖

១) សហព្រះរាជអាជ្ញាបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០១០ ថា អង្គជំនុំជម្រះសេចក្តីដោយភ័ន្តច្រឡំអំពីអង្គច្បាប់ដែលធ្វើឲ្យសាលក្រមមិនអាចទទួលយកបានមានចំនួនពីរ ការប្រើឆន្ទានុសិទ្ធិក្នុងការផ្តន្ទាទោស និងការផ្តន្ទាទោសត្រួត។

[០៩:១០:៤៨]

សហព្រះរាជអាជ្ញាបានដាក់សារណាបណ្តឹងសាទុក្ខជាភាសាអង់គ្លេសនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ ២០១០ និងជាភាសាខ្មែរនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០។ ហើយបានជូនដំណឹងនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០ ប៉ុន្តែ គ្មានសារណាឆ្លើយតបរបស់ភាគីពាក់ព័ន្ធទេ។

២) សហមេធាវីការពារក្តីជនជាប់ចោទបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខនៅថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០១០ ស្តីពីកំហុសអង្គច្បាប់ ដែលសាលក្រមមិនអាចទទួលយកបានគឺ ការភ័ន្តច្រឡំអំពីយុត្តាធិការបុគ្គល និងការផ្តន្ទាទោសដាក់ពន្ធនាគារ ឌុច សរុបរួមកំណត់ ៣៥ឆ្នាំ។ បានដាក់សារណាបណ្តឹងសាទុក្ខ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ និងមានការកែសម្រួលខ្លះៗ។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី បានដាក់សារណាតបនៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១០។

[០៩:១២:៥៨]

សហព្រះរាជអាជ្ញាបានដាក់សារណា តបនៅថ្ងៃទី២០ ខែ១២ ឆ្នាំ២០១០ និងដាក់សេចក្តីសង្កេតទៅលើសារណាបណ្តឹងសាទុក្ខ ច្បាប់កែតម្រូវជាភាសាអង់គ្លេសនៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១១។

សហមេធាវីការពារជនជាប់ចោទដាក់ចម្លើយតប ទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញា នៅថ្ងៃ១៤ ខែ០១ ឆ្នាំ២០១១ ជាភាសាខ្មែរ និងជាភាសាអង់គ្លេសនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១១។

[០៩:១៣:៣៣]

៣) សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ បានដាក់បណ្តឹងសាទុក្ខភ្លាមៗនៅថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១០ មិនសុខចិត្តចំពោះការសម្រេចដកឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីចេញពីសាលក្រមចំនួនប្រាំបួនរូប។ ប៉ុន្តែ តាមសេចក្តីសម្រេចកំណត់ចរិតលក្ខណៈនៃបណ្តឹងសាទុក្ខភ្លាមៗចុះថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០១០ របស់អង្គជំនុំជម្រះតុលាការកំពូល សហព្រះរាជអាជ្ញាតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ បានដាក់សារណាបន្ថែមនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០។ គ្មានសារណាតបណាមួយត្រូវបានដាក់ដោយភាគីពាក់ព័ន្ធនោះទេ។

[០៩:១៤:២៥]

៤) សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ និងថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១០ មិនសុខចិត្តចំពោះការសម្រេចដកឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីចេញពីសាលក្រមចំនួនប្រាំរូប មិនបញ្ចូលឈ្មោះក្នុងសាលក្រម និងការសម្រេចអំពីសំណង បានដាក់សារណាបណ្តឹងសាទុក្ខនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០, ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១០ ជាភាសាអង់គ្លេស និងជាភាសាខ្មែរនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ និងថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១០។ គ្មានសារណាតបណាមួយត្រូវបានដាក់ដោយភាគីពាក់ព័ន្ធនោះទេ។

[០៩:១៥:១៦]

៥) សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១០ មិនសុខចិត្តចំពោះការសម្រេចដកឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីចេញពីសាលក្រមចំនួនប្រាំបីរូប និងការសម្រេចអំពីសំណង បានដាក់សារណាបណ្តឹងសាទុក្ខនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០ ជាភាសាអង់គ្លេស និងជាភាសាខ្មែរនៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០១០។ គ្មានសារណាតបណាមួយត្រូវបានដាក់ដោយភាគីពាក់ព័ន្ធនោះទេ។

[០៩:១៥:៥៨]

**អំពីការចាត់តាំងចៅក្រមរបាយការណ៍**

អនុលោមតាមវិធាន១០៨ អនុវិធាន៥ នៃវិធានផ្ទៃក្នុង ប្រធានអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចាត់តាំងចៅក្រមរបាយការណ៍ដើម្បីពិនិត្យបណ្តឹងសាទុក្ខដែលបែងចែកជាបួនផ្នែក:

ទីមួយ មួយបណ្តឹងសាទុក្ខស្តីពីយុត្តាធិការដែលទទួលខុសត្រូវ និងធ្វើរបាយការណ៍ដោយសហចៅក្រមរបាយការណ៍ លោក ចៅក្រម សោម សិរិវឌ្ឍ និងលោក ចៅក្រម ចាត់ជ្រា នីហាល ចាយ៉ាស៊ីញហ៍។

ទីពីរ បណ្តឹងសាទុក្ខស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានលោកចៅក្រម ស៊ិន រិទ្ធ និងលោកស្រីចៅក្រម អាកនីកា ក្លូណូវីកកា មីឡាត ជាសហចៅក្រម របាយការណ៍។

ទីបី បណ្តឹងសាទុក្ខស្តីពីការកំណត់ទោស មានចៅក្រម ស៊ិន រិទ្ធ និងចៅក្រម ម៉ូតូ ណូហ្គូជិ ជាសហចៅក្រមរបាយការណ៍។

ទីបួន បណ្តឹងសាទុក្ខស្តីពីឋានៈដើមបណ្តឹងរដ្ឋប្បវេណី និងសំណងដែលមានលោកចៅក្រម យ៉ាណារិន និងលោកស្រីចៅក្រម អាកនីកា ក្លូណូវីកកា មីឡាត ជាសហចៅក្រមរបាយការណ៍។

[០៩:១៧:២២]

**អំពីភស្តុតាងបន្ថែម**

តាមសំណើរបស់សហមេធាវីការពារក្តីជនជាប់ចោទ និងតំណាងដើមបណ្តឹងរដ្ឋប្បវេណី មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ ក្រុមពីរ និងក្រុមបី បានសុំដាក់ភស្តុតាងបន្ថែមមកអង្គជំនុំជម្រះតុលាការកំពូល ហើយអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ សម្រេចទទួលយកភស្តុតាងបន្ថែមទាំងនោះ។

[០៩:១៧:៥៦]

យើងខ្ញុំសូមជម្រាបផងដែរថា នៅពេលដែលសហមេធាវីធ្វើសេចក្តីថ្លែងការណ៍ទាក់ទងនឹងសារណារបស់ខ្លួន គឺសូមលើកឡើង និងបង្ហាញនូវភស្តុតាងទាំងនោះជូនអង្គជំនុំជម្រះ។

បន្តទៅទៀតទៅនេះ គឺចូលដល់បណ្តឹងសាទុក្ខស្តីពីយុត្តាធិការបុគ្គល។

សូមអញ្ជើញលោកសហចៅក្រមរបាយការណ៍ អានរបាយការណ៍។

[០៩:១៨:៤៧]

**ចៅក្រម សោម សិរិវឌ្ឍ៖**

សូមអរគុណលោកប្រធាន ដោយបានការឯកភាពពីលោកសហចៅក្រមរបាយការណ៍ នីហាល ចាយ៉ាស៊ីញហ៍។ ខ្ញុំសូមលើកឡើងនៅរបាការណ៍ស្តីពីបញ្ហាយុត្តាធិការបុគ្គល

ក) សាលក្រមសាលាដំបូង

អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា មេធាវីការពារក្តីពុំបានលើកឡើងអំពីអញ្ញត្រកម្ម បឋមស្តីពីយុត្តាធិការបុគ្គលនៅក្នុងសវនាការបឋមឡើយ ហើយអង្គជំនុំជម្រះសាលាដំបូងបានច្រាន ចោលនូវអញ្ញត្រកម្មស្តីពីយុត្តាធិការបុគ្គលនេះផងដែរ ដោយសារមេធាវីការពារក្តីមានការយឺតយ៉ាវក្នុង ការលើកឡើងនូវអញ្ញត្រកម្មនេះ។

[០៩:១៩:៣៣]

អង្គជំនុំជម្រះសាលាដំបូងដោះស្រាយបញ្ហាយុត្តាធិការបុគ្គល ទៅតាមការយល់ឃើញរបស់ខ្លួន ដោយអនុលោមទៅតាមវិធាន៩៨(៣) នៃវិធានផ្ទៃក្នុង ហើយបានសម្រេចថា ជនជាប់ចោទគឺស្ថិតក្នុង ចំណោមអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត។ អង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថា ពុំមានការ ចាំបាច់ក្នុងការពិនិត្យលើបញ្ហាថាតើជនជាប់ចោទ គឺជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ នោះទេ។

ខ) សារណារបស់ភាគី

មេធាវីការពារក្តីលើកទឡ្ហីករណ៍ប្តឹងជំទាស់ទៅនឹងសាលក្រមសាលាដំបូងថា មានការភ័ន្តច្រឡំ លើអង្គហេតុនិងអង្គច្បាប់ ដោយសាលាដំបូងធ្វើការសម្រេចថា ជនជាប់ចោទស្ថិតក្នុងយុត្តាធិការបុគ្គល របស់ អ.វ.ត.ក។ ចំណុចខាងក្រោមនេះគឺជាទឡ្ហីករណ៍គាំទ្ររបស់មេធាវីការពារក្តីនៅក្នុងសារណា បណ្តឹងសាទុក្ខរបស់ជនជាប់ចោទ។

[០៩:២០:៣១]

អង្គជំនុំជម្រះសាលាដំបូងភ័ន្តច្រឡំ ដោយបានបដិសេធចោលនូវការជំទាស់ស្តីពីយុត្តាធិការរបស់ មេធាវីការពារក្តីថា មានលក្ខណៈយឺតយ៉ាវ ដោយអនុលោមតាមវិធាន៨៩ នៃវិធានផ្ទៃក្នុង។ អង្គជំនុំ ជម្រះសាលាដំបូងភ័ន្តច្រឡំក្នុងការបង្កើតនូវយុត្តាធិការបុគ្គលនៃ អ.វ.ត.ក ជាប្រភេទបុគ្គលពីរដាច់ដោយ ឡែកផ្សេងគ្នា គឺមេដឹកនាំជាន់ខ្ពស់ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត ហើយដោយសារតែជនជាប់ ចោទមិនមែនជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ។ ហេតុដូច្នេះ ជនជាប់ចោទមិនស្ថិត ក្នុង ចំណោមអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ។

អង្គជំនុំជម្រះសាលាដំបូងភ័ន្តច្រឡំ ដោយខកខានមិនបានពិចារណាលើភស្តុតាងដោះបន្ទុក។ មេធាវីការពារក្តីស្នើសុំដល់អង្គជំនុំជម្រះតុលាការកំពូលធ្វើការបង្គាប់ឲ្យដោះលែងជនជាប់ចោទ និង សម្រេចថា ការឃុំខ្លួន កាំង ហ្គេកអ៊ាវ ហៅ ឌុច គឺជាទម្រង់មួយនៃការការពារចំពោះសាក្សី។

សហព្រះរាជអាជ្ញាធ្វើការឆ្លើយតបថា ការជំទាស់របស់មេធាវីការពារក្ដីគ្មានមូលដ្ឋានភស្តុតាងត្រឹមត្រូវ ឬអាចនិយាយផ្សេងទៀតថា មិនបានបំពេញនូវលក្ខខណ្ឌអប្បបរមានៃបណ្ដឹង គប្បីត្រូវបានត្រូវបដិសេធចោលដោយអង្គជំនុំជម្រះតុលាការកំពូល។ សហព្រះរាជអាជ្ញាលើកឡើងនូវទឡ្ហីករណ៍ទាក់ទងទៅនឹងអង្គសេចក្ដីនៃបណ្ដឹងសាទុក្ខស្ដីពីយុត្តាធិការបុគ្គលរបស់មេធាវីការពារក្ដីដូចខាងក្រោមៈ

[០៩:២២:០៥]

អនុលោមតាមវិធាន៨៩ នៃវិធានផ្ទៃក្នុង មេធាវីការពារក្ដីត្រូវតែលើកឡើងនូវអញ្ញត្រកម្មស្ដីពីយុត្តាធិការនៅក្នុងសវនាការបឋម។ ប៉ុន្តែមេធាវីការពារក្ដីខកខានមិនបានធ្វើដូច្នោះ ហើយថែមទាំងបានបង្ហាញផងដែរ ថាខ្លួនមិនមានបំណងជំទាស់លើយុត្តាធិការបុគ្គលនេះទេ។

អង្គជំនុំជម្រះសាលាដំបូង បានបង្កើតយ៉ាងត្រឹមត្រូវនូវយុត្តាធិការបុគ្គលនៃ អ.វ.ត.ក ជាប្រភេទបុគ្គលពីរផ្សេងគ្នា។ មេដឹកនាំជាន់ខ្ពស់និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត។ អង្គជំនុំជម្រះសាលាដំបូងធ្វើការសម្រេចយ៉ាងត្រឹមត្រូវថា ជនជាប់ចោទគឺស្ថិតក្នុងចំណោមអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត។

[០៩:២២:៥០]

នៅក្នុងការឆ្លើយតបជាលាយលក្ខណ៍អក្សររបស់ខ្លួន មេធាវីការពារក្ដីលើកឡើង នូវចំណុចមួយចំនួនទាក់ទងទៅនឹងការឆ្លើយតបរបស់សហព្រះរាជអាជ្ញាដូចខាងក្រោមៈ

សហព្រះរាជអាជ្ញាធ្វើការឆ្លើយតបដោយពាក្យសម្ដីធ្ងន់ៗស្ដីអំពីយុត្តិសាស្ត្រតុលាការអន្តរជាតិច្បាប់អន្តរជាតិគប្បីត្រូវបានអនុវត្តតែក្នុងកាលៈទេសៈមួយចំនួនដែលគ្មាននៅ អ.វ.ត.ក ប៉ុណ្ណោះ។ យុត្តិសាស្ត្រអន្តរជាតិ មិនអាចប្រើប្រាស់ដើម្បីដាក់ជនជាប់ចោទឲ្យស្ថិតក្នុងប្រភេទអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ។ សហព្រះរាជអាជ្ញាភ័ន្តច្រឡំក្នុងការកំណត់វិធាន៨៩ នៃវិធានផ្ទៃក្នុង ហើយដោយសារយុត្តាធិការបុគ្គលត្រូវបានជំទាស់ដោយសំអាងលើភស្តុតាងដែលបានលើកឡើងក្នុងពេលជំនុំជម្រះ ដែលស្របតាមវិធាន៨៧ នៃវិធានផ្ទៃក្នុង។ ដូច្នេះ ការជំទាស់លើយុត្តាធិការនេះអាចទទួលយកបានជាបណ្ដឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។

[០៩:២៣:៤៨]

ដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបី បានដាក់ចម្លើយតបជាលាយលក្ខណ៍អក្សរទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់ជនជាប់ចោទ ដោយស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការបដិសេធចោលនូវទឡ្ហីករណ៍របស់មេធាវីការពារក្ដីថាគ្មានមូលដ្ឋានច្បាស់លាស់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញជនជាប់ចោទឡើងមកលើកន្លែងក្រចកសេះ។

[០៩:២៥:០០]

មុននឹងឲ្យជនជាប់ចោទធ្វើការកត់សម្គាល់នូវបណ្ដឹងសាទុក្ខរបស់ខ្លួន។ ខ្ញុំសូមជម្រាបជូនថា ជនជាប់ចោទនៅពេលនេះ គឺនៅក្នុងនីតិវិធីនេះគឺត្រូវចាត់ទុកថា គ្មានទោសដរាបណាពិរុទ្ធភាពរបស់លោកមិនទាន់ត្រូវបានរកឃើញនោះទេ។

លោកមានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ ដូចជាខ្ញុំបានជម្រាបជូនអម្បាញ់មិញៗនេះ និងសិទ្ធិមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន និងនៅក្រុមពេលវេលានៅក្នុងដំណាក់កាលនៃកិច្ចដំណើរការជំនុំជម្រះនេះ គឺលោកមានសិទ្ធិនៅស្ងៀមមិនឆ្លើយតបបាន។ ដូច្នេះ គឺជាជម្រើសមួយដែលជនត្រូវចោទ អាចធ្វើការកត់សម្គាល់ខ្លីអំពីបណ្ដឹងសាទុក្ខ ហើយរយៈពេលដែលជូនលោកគឺមានរយៈពេលប្រាំនាទី គឺខ្លីៗទេ។ សូមឲ្យធ្វើខ្លីៗ គឺចំនួនប្រាំនាទី។

ខ្ញុំបាទសូមអញ្ជើញ!

[០៩:២៦:២៣]

**ជនជាប់ចោទ៖**

សូមគោរពតុលាការ, បណ្ដឹងសាទុក្ខរបស់ខ្ញុំបាទ ផ្ដោតតែទៅលើយុត្តាធិការបុគ្គលប៉ុណ្ណោះ។ ដូច្នេះវាជាបញ្ហាខាងផ្លូវច្បាប់សុទ្ធសាធ យើងខ្ញុំបានជូនការងារអស់នេះទៅសហមេធាវីការពារក្ដីរបស់ខ្ញុំបាទរួចអស់ហើយ។ នេះជាសេចក្ដីសម្រេចដែលខ្ញុំអត់ប្រែប្រួលទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ ,សូមអញ្ជើញសម្រួលឥរិយាបថ។

ដោយសារមានការកត់សម្គាល់រួចហើយអំពីបណ្ដឹងសាទុក្ខ គឺជនជាប់ចោទនៅតែមានជំហរថានៅតែប្ដឹងសាទុក្ខដដែល ហើយគឺប្រគល់តួនាទីនេះដល់សហមេធាវីជាតិទាំងពីររូបដើម្បីធ្វើសារណា។ អ៊ីចឹងសូមអញ្ជើញលោកទៅកាន់ទីកន្លែង។

ជាបន្តទៅទៀតសូមអញ្ជើញសហមេធាវីការពារក្ដីជនជាប់ចោទ។ សូមអញ្ជើញសហមេធាវីពារក្ដីជនជាប់ចោទធ្វើសេចក្ដីថ្លែងការណ៍អំពីបណ្ដឹងសាទុក្ខទាក់ទងនឹងផ្នែកយុត្តាធិការ។

បាទ,សូមអញ្ជើញ!

[០៩:២៨:០៦]

**លោក ការ សាវុត្ថៈ**

សូមគោរពឯកឧត្តមប្រធាន សូមគោរពលោកចៅក្រមជាតិនិងអន្តរជាតិ និងសូមគោរពអង្គសវនាការទាំងមូល។ ខ្ញុំបាទជាមេធាវីការពារជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលត្រូវអង្គជំនុំជម្រះសាលាដំបូងរបស់ អ.វ.ត.ក បានចេញសាលក្រមសម្រេចផ្តន្ទាទោស ៣៥ឆ្នាំ ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ តាមមាត្រា៥ មាត្រា៦ និងមាត្រា២៩(ថ្មី) នៃច្បាប់ អ.វ.ត.ក។

[០៩:២៩:១២]

អង្គសវនាការជាទីគោរព, ក្រោមកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាសាលាជម្រះក្តីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីយកមកជំនុំជម្រះនិងផ្តន្ទាទោស ចំពោះជនទាំងឡាយដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម អំពើប្រល័យពូជសាសន៍ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩។

[០៩:៣០:១៧]

ក្រោមកិច្ចព្រមព្រៀងនេះ ភាគីទាំងពីរមានគោលបំណង រួមគ្នាដើម្បីស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជា និងក៏ដើម្បីធ្វើឲ្យមានការផ្សះផ្សាជាតិ បង្រួបបង្រួមជាតិ និងទទួលបានសន្តិភាព ព្រមទាំងឲ្យគោរពអធិបតេយ្យជាតិខ្មែរទៀតផង។

ក្រោមមាត្រា២ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា និងមាត្រា១ និងមាត្រា២(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានផ្តល់សិទ្ធិអំណាចដល់ និងក៏បានដាក់កំហិតនូវយុត្តាធិការលើ អ.វ.ត.ក ផងដែរ។

១) អ.វ.ត.ក មានសិទ្ធិអំណាចជំនុំជម្រះតែទៅលើបទឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការរំលោភយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែ សីហា ឆ្នាំ១៩៤៩។

២) អ.វ.ត.ក មានសិទ្ធិនិងអំណាចជំនុំជម្រះ និងផ្តន្ទាទោសទៅលើបទឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងអំឡុងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

៣) អ.វ.ត.ក មានសិទ្ធិអំណាចជំនុំជម្រះ និងផ្ដន្ទាទោសបទឧក្រិដ្ឋកម្ម នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។

៤) អ.វ.ត.ក មានសិទ្ធិអំណាចជំនុំជម្រះនិងផ្ដន្ទាទោស តែទៅលើមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម។

[០៩:៣២:៣៦]

នេះជាលក្ខខណ្ឌយុត្តាធិការ ដែលតម្រូវឲ្យតុលាការកំពូលធ្វើការពិនិត្យឡើងវិញ ព្រោះថា យុត្តាធិការនៅក្នុងសាលាជម្រះក្ដីជាទូទៅមានសមាសធាតុចំនួនបួន៖១) យុត្តាធិការបុគ្គល, ២) យុត្តាធិការដែនដី, ៣) យុត្តាធិការពេលវេលា, ៤) គឺយុត្តាធិការសម្ភារៈ។

ប្រសិនបើ សាលាជម្រះក្ដីត្រូវបញ្ចប់និទណ្ឌភាព សាលាជម្រះក្ដីចាំបាច់ត្រូវតែពិចារណាដោយយកចិត្តទុកដាក់ពីអំពើប្រព្រឹត្តនិងបុគ្គល ដែលសាលាជម្រះក្ដីអាចពិនិត្យវិនិច្ឆ័យបាន។

[០៩:៣៣:០០]

ការកំណត់ដែនវិសាលភាពយុត្តាធិការរបស់សាលាជម្រះក្ដីព្រហ្មទណ្ឌ មានសារៈសំខាន់ណាស់ដោយហេតុថា ចំណុចនេះអាចមានផលប៉ះពាល់ដល់ធម្មានុរូប និងប្រសិទ្ធភាពរបស់សាលាជម្រះក្ដី។

ការដាក់កម្រិតកំណត់ចំពោះយុត្តាធិការពេលវេលា ដែនដី និងសម្ភារៈរបស់សាលាក្ដី និងកំណត់ព្រំដែន អំពើប្រព្រឹត្តដែលអាចជាកម្មវត្ថុសម្រាប់ដំណើការក្ដីនៅចំពោះមុខសាលាជម្រះក្ដី។

ទន្ទឹមនេះដែរ យុត្តាធិការបុគ្គលដែលត្រូវបានកំណត់អាចមិនរាប់បញ្ចូលបុគ្គល ឬក្រុមសំខាន់ៗដែលនៅក្រៅដែនវិសាលភាពរបស់សាលាក្ដីទេ។ ខណៈដែលការជ្រើសរើសយុត្តាធិការសម្ភារៈនឹងចង្អុលបង្ហាញអំពីអំពើប្រព្រឹត្តដែលត្រូវចាត់ថាជាអំពើឧក្រិដ្ឋ និងរបៀបនៃការចាត់ថ្នាក់អំពើនោះថា តើជាអំពើឧក្រិដ្ឋកម្មអន្តរជាតិ ឬជាអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ឬក៏ជាឧក្រិដ្ឋកម្មធម្មតា ស្របតាមច្បាប់ក្នុងស្រុក។

[០៩:៣៤:៥៩]

ហើយដើម្បីសម្រេចឲ្យបានគោលបំណងស្ដីពីការគ្មាននិទណ្ឌភាព ជាឧត្ដមគតិដែនវិសាលភាពយុត្តាធិការគួរតែមានលក្ខណៈទូលំទូលាយតាមដែលអាចធ្វើទៅបាន ហើយអាចគ្រប់ដណ្ដប់ទៅលើអំឡុងពេល ទីតាំងភូមិសាស្ត្រ អំពើប្រព្រឹត្ត និងបុគ្គលពាក់ព័ន្ធទាំងអស់។ តែទោះជាយ៉ាងណាក៏ដោយតាមដែលយើងបានសិក្សាកន្លងមក សាលាក្ដីនានាមិនបានដំណើរការតាមបរិបទជាឧត្ដមគតិនេះទេ ហើយ អ្នករៀបចំស្ថាបនាសាលាក្ដីអន្តរជាតិ និងកូនកាត់បានធ្វើការសម្របសម្រួលជាច្រើន។

[០៩:៣៥:៥៦]

ដូច្នេះ តាមវិធាន១១ ស្ទួន យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិយូហ្គោស្លាវី បានធ្វើការបកស្រាយអំពីអត្ថន័យនៃឃ្លា "មេដឹកនាំជាន់ខ្ពស់បំផុត" ថា សំដៅដល់បុគ្គលទាំងឡាយណា ដែលដោយសារមុខតំណែង និងមុខងាររបស់ពួកគេក្នុងឋានានុក្រមរដ្ឋបាលពោលគឺ តាមផ្លូវច្បាប់ និងតាមព្រឹត្តិហេតុជាក់ស្ដែងត្រូវបានចោទថា ស្ថិតក្នុងកម្រិតអំណាចដែលសមស្របចាត់ទុកពួកគេថាឋិតក្នុងចំណោមអ្នកដឹកនាំជាន់ខ្ពស់បំផុត គឺមិនមែនថ្នាក់កណ្ដាលទេ។ ឯតា ឌុច នេះគឺថ្នាក់ក្រោមបំផុត គឺថ្នាក់ មូលដ្ឋាន។

[០៩:០០:០០]

ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្ដីរបស់តុលាការអន្តរជាតិយូហ្គោស្លាវី បានពិចារណាអំពីលក្ខណៈវិនិច្ឆ័យដូចជា តួនាទី ថ្នាក់ដឹកនាំអចិន្ត្រៃយ៍ និងក្នុងរយៈពេលកំណត់កម្រិតថ្នាក់ដឹកនាំជាន់ខ្ពស់ បើមានតំណែងទទួលខុសត្រូវថ្នាក់នយោបាយណាមួយរបស់ជនជាប់ចោទ។ ឧទាហរណ៍ថា តាមរយៈការចរចាជាមួយសមាសភាពអន្តរជាតិ ន៉ែអាហ្នឹងបានវាអ្នកទទួលខុសត្រូវខ្ពស់បំផុត ហើយតា ឌុច ស-២១ គាត់ដែលទៅចរចាជាមួយអន្តរជាតិ អត់មានទេក្នុងឯកសារសំណុំរឿង ស-២១ ទាំងអស់ គឺគ្មានទេ និងចំនួនបុគ្គលដែលស្ថិតក្រោមការបញ្ជារបស់ជនជាប់ចោទ។

[០៩:៣៧:៥៧]

ដោយសារហេតុផលនេះហើយ បានជាក្នុងកថាខណ្ឌ៥ សេចក្ដីសម្រេចលេខ១៥៣៤ ដោយសំអាងលើយុត្តិសាស្ត្រនៃសវនាការបញ្ចប់ ក្រុមប្រឹក្សាសន្តិសុខបានកំណត់លក្ខណៈវិនិច្ឆ័យ អំពីកម្រិតថ្នាក់ជាន់ខ្ពស់ ដែលបានស្នើសុំឱ្យអង្គជំនុំជម្រះត្រូវធានាឲ្យបានថា ការចេញដីកាបណ្ដោះអាសន្នថ្មីណាមួយក៏ដោយ ត្រូវផ្ដោតទៅលើអ្នកដឹកនាំជាន់ខ្ពស់បំផុត ដែលជាប់សង្ស័យពីបទទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ស្របតាមយុត្តាធិការរបស់អង្គជំនុំជម្រះពាក់ព័ន្ធ។

[០៩:៣៨:៥០]

ហើយបើតាមយុត្តាធិការបុគ្គលរបស់តុលាការកំពូលសៀរ៉ាឡេអូន ត្រូវបានកម្រិតចំពោះបុគ្គលទាំងឡាយដែលមានការទទួលខុសត្រូវខ្ពស់បំផុត ចំពោះការរំលោភបំពានធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ ហើយច្បាប់របស់ សៀរ៉ាឡេអូន ដែលរាប់បញ្ចូលទាំងអ្នកដឹកនាំទាំងឡាយណាដែលពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មនានា បានគំរាមកំហែងដល់ការស្ថាបនា និងការអនុវត្តដំណើរការស្វែងរកសន្តិភាពនៅ សៀរ៉ាឡេអូន។

ចំណែកយុត្តាធិការបុគ្គលរបស់តុលាការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាប្រភពមួយក្នុងចំណោមប្រភពដ៏រឹងមាំបំផុតនានា សម្រាប់ការខ្វែងគំនិតគ្នារវាងភាគីកម្ពុជា និងអង្គការសហប្រជាជាតិក្នុងអំឡុងពេលចរចា។ សំណើសុំជំនួយ សុំជំនួយដំបូងរបស់ភាគីកម្ពុជា បានបង្ហាញនូវការចង់បានរបស់កម្ពុជា ដែលថាកំណត់តែទៅលើអ្នកដឹកនាំជាន់ខ្ពស់ប៉ុណ្ណោះ។ ហើយអង្គការសហប្រជាជាតិ ជាយថាហេតុបានយល់ព្រមចំពោះការកម្រិតកំណត់នេះ ដើម្បីឈានទៅដល់កិច្ចព្រមព្រៀងបង្កើតអង្គជំនុំជម្រះនេះឡើង។

[០៩:៤០:៤៦]

យុត្តាធិការបុគ្គលរបស់តុលាការ អ.វ.ត.ក ត្រូវបានកម្រិតកំណត់ចំពោះអ្នកដឹកនាំជាន់ខ្ពស់ នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុងដែនយុត្តាធិការពេលវេលារបស់ អ.វ.ត.ក។

ទោះជាមានសំណើស្នើសុំឲ្យមានយុត្តាធិការបុគ្គលទូលាយជាងមុន ដែលអាចឲ្យសហព្រះរាជអាជ្ញាមានឆន្ទានុសិទ្ធិកាន់តែច្រើនក្នុងការសម្រេចកំណត់អំពីបុគ្គល ដែលត្រូវធ្វើការស៊ើបអង្កេតត្រូវបានបដិសេធចោលដោយភាគីកម្ពុជា។ ដូចមាត្រា៥ ចំណុច៣ និងមាត្រា៦ ចំណុច៣ នៃកិច្ចព្រមព្រៀង អ.វ.ត.ក បានកំណត់អំពីវិសាលភាពនៃការស៊ើបអង្កេត និងការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេត និងសហព្រះអាជ្ញា គឺកម្រិតកំណត់ត្រឹមតែមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលមានចែងក្នុងច្បាប់ អ.វ.ត.ក។

ដូច្នេះ ច្បាប់នេះបានចងឆន្ទានុសិទ្ធិរបស់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតរួចស្រេចហើយ ឲ្យដើរតែក្នុងរង្វង់ហ្នឹង បើដើរចេញក្រៅពីរង្វង់ហ្នឹង គឺខុសពីច្បាប់ អ.វ.ត.ក។

[០៩:៤២:៥១]

នៅក្នុងដំណាក់កាលជជែកដេញដោលនៅក្នុងអង្គសវនាការសាលាដំបូង មេធាវីការពារជនជាប់ចោទបានលើកឡើងពីភាពគ្មានយុត្តាធិការរបស់ អ.វ.ត.ក ទៅលើជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដោយតម្រូវឲ្យតុលាការ អ.វ.ត.ក ពិនិត្យមើលភ័ស្តុតាងបញ្ជាក់ដែលមិនចងភ្ជាប់ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ទៅនឹងមាត្រា១ និងមាត្រា២(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ ប៉ុន្តែ ចៅក្រមខកខានមិនបានពិនិត្យ ហើយបន្តសវនាការរហូតដល់ទីបញ្ចប់នៃនីតិវិធី។ ជាលទ្ធផលមេធាវីការពារជនចាប់ចោទបានព្យាយាមលើកឡើងម្តងទៀត នៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួន ដើម្បីទាមទារឲ្យចៅក្រម

ពិនិត្យឡើងវិញភស្តុតាងដោះបន្ទុកដែលបញ្ជាក់ថា ជនជាប់ចោទមិនស្ថិត-- មិនត្រូវចងភ្ជាប់ទៅនឹងមាត្រា១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា និងមាត្រា១ និងមាត្រា២(ថ្មី) នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក។

[០៩:៤៤:១៦]

ជាលទ្ធផល ចៅក្រមខកខានជាថ្មីម្ដងទៀត ក្នុងការពិនិត្យមើលភស្តុតាងដោះបន្ទុកតាមការស្នើសុំរបស់មេធាវីការពារជនជាប់ចោទដដែល ហើយកាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចប្រកាសចេញសាលក្រមលើសំណុំរឿងលេខ០០១ ផ្ដន្ទាទោសឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ជាប្រធានស-២១ ដែលគ្រប់គ្រងផ្ទាល់ដោយក្រសួងការពារជាតិ និងមន្ទីរអគ្គសេនាធិការកងទ័ពដែលមានឈ្មោះ សុន សេន ជាប្រធាន ឲ្យជាប់ពន្ធនាគារសរុបកំណត់ ៣៥ឆ្នាំ។

[០៩:៤៥:១២]

ដោយហេតុថា សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ បានផ្ដន្ទាទោសជនជាប់ចោទ ដែលមិនស្ថិតនៅក្នុងយុត្តាធិការរបស់ខ្លួន។ នេះជាលក្ខខណ្ឌយុត្តាធិការដែលតម្រូវឲ្យមានការពិនិត្យឡើងវិញរបស់តុលាការ ចំពោះពាក្យថា “មេដឹកជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត” ក្នុងកិច្ចព្រមព្រៀងនិងច្បាប់របស់ អ.វ.ត.ក។ នៅចំពោះមុខអង្គជំនុំជម្រះសាលដំបូង មេធាវីការពារក្ដីបានជំទាស់តែទៅលើវិធីសាស្ត្ររបស់សហព្រះរាជអាជ្ញារបស់សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះសាលាដំបូង ដែលខិតខំទាញយក ឌុច ឲ្យចូលក្នុងយុត្តាធិការរបស់ អ.វ.ត.ក។ មេធាវីការពាក្ដីយល់ឃើញថា ឌុច មិនស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដោយផ្អែកលើទឡ្ហីករណ៍ដូចតទៅៈ

[០៩:៤៦:៣៣]

ទឡ្ហីករណ៍ទីមួយ ការភ័ន្តច្រឡំអំពីយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង យុត្តាធិការរូបបុគ្គល។ យុត្តាធិការលើរូបបុគ្គលត្រូវបានកំណត់ចំពោះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងអន្តរជាតិ។ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និងច្បាប់ អ.វ.ត.ក មិនមានចែងច្បាស់អំពីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែល

ទទួលខុសត្រូវខ្ពស់បំផុតនោះទេ។ ហើយនៅក្នុងកិច្ចព្រមព្រៀង និងច្បាប់របស់ អ.វ.ត.ក ដដែល ក៏មិនមានចែងដែរថា កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនោះទេ។

[០៩:៤៧:៥៨]

ដូច្នេះ តើមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះ តើអ្នកណាខ្លះ? បើតាមយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិខ្លះ បានឲ្យអត្ថន័យនៃពាក្យថា មេដឹកនាំជាន់ខ្ពស់បំផុតដែលត្រូវបានគេសង្ស័យថា ជាអ្នកទទួលខុសត្រូវខ្ពស់បំផុត បានសេចក្តីថា ទាល់តែអ្នកនោះជាមេដឹកនាំជាន់ខ្ពស់បំផុត ទើបបានគេសង្ស័យថា អ្នកនោះឯងជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ព្រោះទាល់តែអ្នកនោះជាមេដឹកនាំជាន់ខ្ពស់ ទើបអ្នកនោះមានសិទ្ធិសម្រេចនិងមានសិទ្ធិបញ្ជា។ អ៊ីចឹង មេដឹកនាំជាន់ខ្ពស់បំផុតដែលមានសិទ្ធិសម្រេច និងមានសិទ្ធិបញ្ជា ទើបជាអ្នកទទួលខុសត្រូវខ្ពស់បំផុត។ ឯអ្នកដែលមិនមែនជាអ្នក-- ជាមេដឹកនាំជាន់ខ្ពស់ ក៏គេមិនសង្ស័យថា ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះដែរ។ អ៊ីចឹង ប្រធានឆ្មាំគុក ដូចតា ឌុច នេះ ជាអ្នកដឹកនាំតូចតាចតាមមូលដ្ឋាន មានរឿងអីទៅសង្ស័យថា គាត់ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះ?

[០៩:៤៩:៣៨]

ចំពោះច្បាប់ អ.វ.ត.ក បានចែង បានបំបែកជាពីរ។ មួយមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ មួយទៀតគឺអ្នកទទួលខុសត្រូវខ្ពស់បំផុត។ អ្នកទទួលខុសត្រូវខ្ពស់បំផុតនេះ ចង់និយាយថា ជាអ្នកមានសិទ្ធិសម្រេចនិងមានសិទ្ធិបញ្ជា។ អ៊ីចឹងបើពិនិត្យទៅលើលក្ខខណ្ឌ២៥៦ នៃសាលក្រមបានបញ្ជាក់ច្បាស់ថា បុគ្គលិកស-២១ ទទួលបញ្ជាពី ឌុច បុគ្គលិកចាត់ទុកជាចារី មិនត្រូវយកមកកាត់ទោសទេ គឺចារីនៅក្រៅយុត្តាធិការរបស់ អ.វ.ត.ក។ ឌុច ទទួលបញ្ជាពីមជ្ឈិមបក្ស ឌុច ក៏ត្រូវចាត់ទុកជាចារីមិនត្រូវយកមកកាត់ទោសទេ គឺនៅក្រៅយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដូចបុគ្គលិកស-២១ដែរ ព្រោះទទួលបញ្ជាតៗគ្នា។ នេះជាលក្ខខណ្ឌយុត្តាធិការដែលទាមទារឲ្យតុលាការកំពូលធ្វើការពិនិត្យឡើងវិញ។

[០៩:៥១:០០]

អង្គជំនុំជម្រះសាលាដំបូងបានសន្និតយក កាំង ហ្គេកអ៊ាវ ហៅ ឌុច មកឧបកិច្ចឲ្យទៅជាអ្នកទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ឲ្យដំណើរការក្តីបានប្រព្រឹត្តទៅជាលក្ខណៈវិជ្ជមាន ដោយពុំបានគិតដល់តម្លៃធម្មនុញ្ញរបស់ជាតិ ដែលត្រូវបានហាមឃាត់នៅក្នុងកថាខណ្ឌ២ ឧបសម្ព័ន្ធ៥ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃ២៣ តុលា ឆ្នាំ១៩៩១ ដែលបានចែងថា “រដ្ឋធម្មនុញ្ញ ត្រូវហាមឃាត់នូវការអនុវត្តច្បាប់

ឧក្រិដ្ឋទៅលើឧក្រិដ្ឋកម្មដែលកើតឡើងក្នុងអតីតកាល”។

[០៩:៥២:០៦]

ឧបសម្ព័ន្ធទី៥ នេះបានរុញច្រានភាគីខ្មែរក្រហមទាំងអស់ឲ្យរួចផុតពីសំណាញ់ច្បាប់ ឲ្យនៅក្រៅយុត្តាធិការបុគ្គល តាំងពីថ្ងៃទី២៣ តុលា ១៩៩១។ ពិសេសត្រង់មាត្រាទី២១ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស បានចែងយ៉ាងច្បាស់ឲ្យដោះលែងឈ្លើយសឹក និងជនស៊ីវិលជាប់ឃុំឃាំងទាំងអស់ ដល់ពេលអ៊ុនតាក់ចូលមកនៅឆ្នាំ៩១ ដោះលែងអស់គ្មានសល់ ឲ្យទៅអង្គុយតុចរចាស្មើភាពគ្នា ដោយទទួលស្គាល់ខ្មែរក្រហមជាភាគីមួយមានសិទ្ធិចូលរួមបោះឆ្នោត និងឈរឈ្មោះឲ្យគេបោះឆ្នោតឲ្យ។ បានសេចក្ដីថាគេលើកលែងទោសអស់ហើយ គ្មានទោសទៀតទេ បើនៅមានទោសមិនអាចឈរឈ្មោះឲ្យគេបោះឆ្នោតឲ្យនោះទេ។ គ្រាន់តែពេលនោះភាគីខ្មែរក្រហមធ្វើពហិការ មិនព្រមឈរឈ្មោះឲ្យគេបោះឆ្នោតឲ្យប៉ុណ្ណោះ។

[០៩:៥៣:២២]

ដូច្នេះ ភាគីខ្មែរក្រហមត្រូវបានច្បាប់លើកលែងទោសជាទូទៅតាំងពីថ្ងៃទី២៣ តុលា ១៩៩១ មករហូតបច្ចុប្បន្ន។ នេះបើយោងទៅតាមមាត្រា៧ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៧ ត្រង់ចំណុចទីបីបានបញ្ជាក់ពីការរលត់នៃបណ្ដឹងអាជ្ញា ហើយមូលហេតុនៃការរលត់បណ្ដឹងអាជ្ញា ដោយសារច្បាប់បានលើកលែងទោសជាទូទៅអស់ហើយ គ្មាននៅសល់ទោសអីទៀតយកមកកាត់ទេ។

ដូច្នេះ ការអនុវត្តច្បាប់ឧក្រិដ្ឋទៅលើឧក្រិដ្ឋកម្ម ដែលកើតឡើងក្នុងអតីតកាលរបស់សាលាដំបូងនៃអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿងលេខ០០១ គឺជាការបំពានយ៉ាងធ្ងន់ធ្ងរទៅលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃ២៣ តុលា ១៩៩១ ផង និងជាការបំពានទៅលើមាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ ផង-- សូមទោស ២០០៧។

[០៩:៥៤:៤៧]

ខ្ញុំបាទសូមអនុញ្ញាតជម្រាបថា ២០ប្រទេសចុះហត្ថលេខាលើកិច្ចព្រមពៀង ២៣ តុលា ១៩៩១។ ២០ ប្រទេសហ្នឹងត្រូវគោរពកិច្ចព្រមព្រៀងទាំងអស់ រួចថៃចូលល្បានពានទឹកដីកម្ពុជា ក៏រាជរដ្ឋាភិបាលកម្ពុជាតវ៉ាទៅអង្គការសហប្រជាជាតិ ឲ្យថៃគោរពកិច្ចព្រមព្រៀង ២៣ តុលា ៩១ ដែរ។

ចុះតឡូវ ឌុច ក៏ទាមទារឲ្យតុលាការ អ.វ.ត.ក គោរពកិច្ចព្រមព្រៀង ២៣ តុលា ១៩៩១ ដែរ។ ថៃមិនគោរពកិច្ចព្រមព្រៀង យើងថាថៃខុស។ ដូច្នេះ ខ្ញុំសង្ឃឹមថា តុលាការ អ.វ.ត.ក មិនខុសដូចថៃទេ។

[០៩:៥៥:៥៩]

ដូច្នេះ ច្បាប់នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ២៣ តុលា ៩១ បានរុញច្រានភាគីខ្មែរក្រហមទាំងអស់ឱ្យនៅក្រោយុត្តាធិការរបស់ អ.វ.ត.ក ស្រេចទៅហើយ។ ដូច្នេះ យក ឌុច មកឧបកិច្ចឱ្យទៅជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ឲ្យចូលក្នុងយុត្តាធិការ អ.វ.ត.ក ជាការមិនត្រឹមត្រូវ។ នេះជាលក្ខខណ្ឌយុត្តាធិការមួយ ក្នុងចំណោមលក្ខខណ្ឌយុត្តាធិការដ៏ច្រើន ដែលតម្រូវឱ្យតុលាការកំពូលធ្វើការពិនិត្យឡើងវិញអំពីពាក្យថា "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត" ក្នុងកិច្ចព្រមព្រៀង និងក្នុងច្បាប់របស់ អ.វ.ត.ក នោះ។

[០៩:៥៦:៤៨]

សូមតុលាការកំពូលនៃ អ.វ.ត.ក មេត្តាពិចារណាចុះ ថាសម័យ ឌុច សម័យខ្មែរក្រហម គ្មានច្បាប់ទេ គេប្រើមាគ៌ារបស់អង្គការ របស់បក្សជំនួសច្បាប់។ សម័យនោះក៏គ្មានតុលាការ សម័យនោះបើគ្មានច្បាប់ បើវាគ្មានច្បាប់ក៏វាគ្មានបទល្មើសដែរ។ ដូច្នេះ ឌុច មិនបានបំពារបំពានអនុសញ្ញាទីក្រុងហ្សឺណែវ ១៩៤៩ ទេ។ ឌុច ត្រូវនៅក្រៅយុត្តាធិការរបស់ អ.វ.ត.ក។

មេធាវីការពារក្តីសង្ឃឹមថា តុលាការកំពូលនឹងអនុវត្តតាមច្បាប់ដូចករណី *ហ្វិនតា* នៅតុលាការកំពូលអន្តរជាតិក្នុងប្រទេសកាណាដា។ ពេលតុលាការកំពូលពិនិត្យឃើញ *ហ្វិនតា* នៅក្រៅយុត្តាធិការរបស់តុលាការ គឺតុលាការកំពូលដោះលែង *ហ្វិនតា* ឱ្យទៅផ្ទះវិញភ្លាម។

[០៩:៥៨:០៣]

ឧបសម្ព័ន្ធទី៥ នៃកិច្ចព្រមព្រៀងបានចែងបញ្ជាក់ទៀតថា "បុគ្គលដែលត្រូវរំលោភបំពានមានសិទ្ធិប្តឹងទៅតុលាការ ដើម្បីកាត់សេចក្តី និងធ្វើឱ្យគេគោរពសិទ្ធិទាំងអស់នេះ"។ ឥឡូវនេះ ឌុច បានប្តឹងមកតុលាការកំពូលដើម្បីឱ្យតុលាការកំពូលកាត់សេចក្តី និងឱ្យគោរពសិទ្ធិទាំងអស់នេះ ដូចដែលមានចែងក្នុងឧបសម្ព័ន្ធទីប្រាំ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ២៣ តុលា ៩១។

បើយោងតាមមាត្រា៥ នៃច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ បានចែងថា "ច្បាប់នេះអនុគ្រោះទុកពេលប្រាំមួយខែ ក្រោយពីចូលជាធរមានឱ្យជនជាសមាជិកអង្គការនយោបាយ ឬកម្លាំងយោធានៃក្រុមកម្ពុជាប្រជាធិបតេយ្យ វិលត្រឡប់មករួមរស់ក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនយកទោសពៃរ៍ចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត"។

[០៩:៥៩:៣៣]

បទដ្ឋានខាងលើនេះគួរតែត្រូវបានយកមកពិនិត្យថ្លឹងថ្លែង ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងបែរជាខនខាន។ ជាហេតុនាំឲ្យបាត់បង់នូវតម្លៃច្បាប់ជាតិដែលកំពុងនៅជាធរមាន ហើយផ្ទុយនឹងវិធាន ៨៧(១) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ទៀតផង។

[១០:០០:០០]

ដូច្នេះ តាមស្មារតីនៃមាត្រា៥ ច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យ ឲ្យនៅក្រៅច្បាប់ បានបញ្ជាក់ច្បាស់ថា មិនយកទោសពៃរ៍ចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត។ អ៊ីចឹង កន្លងមកទោះបី ឌុច បានប្រព្រឹត្តបទល្មើសអ្វីក៏ដោយ ក៏ច្បាប់មិនយកទោសពៃរ៍ដែរ។ ហេតុនេះ ឌុច ត្រូវតែនៅក្រៅយុត្តាធិការរបស់ អ.វ.ត.ក ស្របនឹងមាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ការរលត់នៃបណ្តឹងអាជ្ញាដោយមូលហេតុនៃការលត់បណ្តឹងអាជ្ញានេះ ដោយច្បាប់លើកលែងទោសជាទូទៅអស់ហើយ។

តាមត្រា៦ នៃច្បាប់ដដែល ចំពោះមេដឹកនាំនៃក្រុមកម្ពុជាប្រជាធិបតេយ្យ មិនអាចមានការអនុគ្រោះដូចមានចែងក្នុងច្បាប់នេះឡើយ។ អ៊ីចឹងច្បាប់នេះ គេអនុគ្រោះអស់ហើយ ចារី អ្នកដៃដល់ អ្នករួមប្រព្រឹត្ត អ្នកសមគំនិត គេមិនយកទោសពៃរ៍ទេ ចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្តកន្លងមក គឺយកទោសពៃរ៍តែមេដឹកនាំនៃក្រុមកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ។ ឯ ឌុច ជាប្រធានឆ្មាំគុក ដូចប្រធានឆ្មាំគុកទាំង១៩៥ គុកគងទៀតហ្នំ! ដែលសាលាដំបូង ចាត់ទុកថា ជាចារីត្រូវនៅក្រៅយុត្តាធិការរបស់ អ.វ.ត.ក។ មកនៅក្នុងយុត្តាធិការអីតែតា ឌុច មួយ ចុះអា ១៩៥ គុក ទៀត គេសម្លាប់ ១០ម៉ឺន ២០ម៉ឺន ម៉េចក៏នៅក្រៅយុត្តាធិការ។ ន៎ែ! សូមតុលាការពិចារណាទៅ។

[១០:០២:២១]

មាត្រា ៩ នៃច្បាប់ដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យ ឲ្យនៅក្រៅច្បាប់អានឹងបញ្ជាក់ច្បាស់កាន់តែច្បាស់ទៀតហើយ។ ជនណាមួយដែលយកច្បាប់នេះទៅរំលោភសិទ្ធិប្រជាពលរដ្ឋ ដោយធ្វើការគំរាមកំហែង ការចោទប្រកាន់ លេសចោទប្រកាន់ ការចាប់ខ្លួន ការឃុំខ្លួន ន៎ែ! បញ្ជាក់ច្បាស់អ៊ីចឹងហ្នំង ត្រូវផ្តន្ទាទោសដាក់គុកពី ពីរឆ្នាំ ទៅប្រាំឆ្នាំ។ ដូច្នេះ សូមតុលាការពិចារណា ខ្ញុំមិនចង់លើកមាត្រានេះទេ។

[១០:០៣:០៤]

មាត្រា២ ចាប់ពីថ្ងៃដែលច្បាប់នេះចូលជាធរមាន។ ជនទាំងឡាយណា ដែលជាសមាជិកអង្គការនយោ-បាយ និងជាកម្លាំងយោធារបស់កម្ពុជាប្រជាធិបតេយ្យ ត្រូវចាត់ទុកជាជនល្មើសនឹងរដ្ឋធម្មនុញ្ញ

និងជាជនល្មើសនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ឌុច ចូលមក ពីរឆ្នាំ ប្រាំមួយខែ មុនច្បាប់នេះចូលជាធរមាន។ បើ ឌុច នៅរឹងរូសមិនព្រមចូលមក នៅបន្តប្រព្រឹត្តបទល្មើសទៀត នោះទើបវាបានវាល្មើសនឹងច្បាប់។ ដូច្នេះតាំងពីច្បាប់នេះ ចូលជាធរមានរហូតបច្ចុប្បន្ន ឌុច ឥតបានប្រព្រឹត្តអ្វីឲ្យល្មើសនឹងរដ្ឋធម្មនុញ្ញ ឬច្បាប់នៃព្រះរាជាណាចក្រកម្ពុជាឡើយ។ ហេតុនេះ ប្រធានឆ្នាំគុកស-២១ នឹងត្រូវតែនៅក្រៅយុត្តាធិការរបស់ អ.វ.ត.ក ដូចប្រធានឆ្នាំគុកទាំង១៩៥គុកទៀតដែរ។ នេះជាលក្ខខណ្ឌយុត្តាធិការដែលតម្រូវឲ្យតុលាការកំពូលធ្វើការពិចារណាឡើងវិញ។

[១០:០៤:២០]

ម៉្យាងទៀត សេចក្តីអំពាវនាវរបស់រដ្ឋាភិបាល នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ ចុះថ្ងៃទី២៧ ខែ៧ ឆ្នាំ១៩៩៤ នោះ បានអំពាវនាវឲ្យប្រជាជនរហូតដល់នាយទាហាន ពលទាហាន ដែលកំពុងរស់នៅក្រោមការត្រួតត្រារបស់ខ្មែរក្រហម ឲ្យប្រញាប់ប្រញាល់រិះរកគ្រប់វិធីមករួមរស់ជាមួយរដ្ឋាភិបាលវិញ។ ដោយពេលនោះ រាជរដ្ឋាភិបាលប្រកាសជាទូទៅ មិនគ្រាន់តែមិនយកទោសពៃរ៍ប៉ុណ្ណោះទេ ថែមទាំងរក្សាទុកនូវឋានន្តរស័ក្តិឲ្យថែមទៀតផង។ ជាក់ស្តែង នៅក្រសួងការពារជាតិសព្វថ្ងៃនេះ មានអតីតទ័ពខ្មែរក្រហមមួយចំនួននៅមានឋានន្តរស័ក្តិនៅឡើយ។

[១០:០៥:២២]

ឌុច ចូលមកជាងពីរឆ្នាំ មុនសេចក្តីអំពាវនាវ បែរជាមានទោសទៅវិញ។ មានទោស លុះត្រាតែរឹងរូសមិនព្រមចូលមក ហើយនៅបន្តប្រព្រឹត្តបទល្មើសតទៅទៀត នឹងហ្នឹងបានមានទោស។ យោងតាមមាត្រា៧ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧ បានបញ្ជាក់ថា ការរលត់នៃបណ្តឹងអាជ្ញា ហើយមូលហេតុនៃការរលត់បណ្តឹងអាជ្ញា ដោយរដ្ឋាភិបាលប្រកាសលើកលែងលែងទោសជាទូទៅ កាលពីថ្ងៃទី២៧-៧-៩៤ និងកិច្ចព្រមព្រៀងប៉ារីស ២៣ តុលា ៩១ ក៏បានប្រកាសលើកលែងទោសជាទូទៅដែររហូតបង្គាប់ឲ្យរដ្ឋធម្មនុញ្ញ ហាមឃាត់ការអនុវត្តឧក្រិដ្ឋទៅលើឧក្រិដ្ឋកម្ម ដែលកើតឡើងពីអតីតកាលទៀតផង។

ដូច្នេះ ឌុច គ្មានទោសពៃរ៍អ្វីទាំងអស់។ ឌុច ត្រូវតែនៅក្រៅយុត្តាធិការរបស់ អ.វ.ត.ក។ នេះសុទ្ធតែជាលក្ខខណ្ឌនៃយុត្តាធិការដែលសំណូមពរឲ្យតុលាការកំពូលធ្វើការពិចារណាឡើងវិញ។

អង្គជំនុំជម្រះសាលាដំបូង បានយល់ស្របជាមួយការចោទប្រកាន់ របស់សហចៅក្រមស៊ើបអង្កេត ដែលឋិតក្នុងស្ថានភាពស្រពេចស្រពិលនៅឡើយក្នុងការចាត់ទុកជនជាប់ចោទថា ជាអ្នកទទួល

ខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលមានចែងក្នុងយុត្តាធិការរបស់ អ.វ.ត.ក ក្នុងនោះដោយបានចោទថា ទោះជា ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏អាចគាត់ត្រូវចាត់ទុកថា ចូលក្នុងប្រភេទនៃអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្មដែរ។

[១០:០៧:២២]

ការយល់ស្របទាំងក្នុងស្ថានភាពស្រពេចស្រពិលបែបនេះ គឺជាកំហុសឆ្គងធ្ងន់ធ្ងរបំផុតរបស់អង្គជំនុំជម្រះសាលាដំបូង ដោយប្រព្រឹត្តផ្ទុយទៅនឹងវិធាន៨១.១ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក និងផ្ទុយទៅនឹងមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាក្រកម្ពុជា ដែលបានចែងថា វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ ឃើញទេ! គាត់អាច ពាក្យថា “គាត់អាច” ត្រូវបានចាត់ទុកថា នែ៎ក្នុងប្រភេទនៃអ្នកទទួលខុសត្រូវខ្ពស់បំផុត។ អ៊ីចឹងនែ៎ អ៊ីចឹងបើអាចចូល៥០ ក៏វាអាចអត់៥០ ព្រោះគ្រាន់តែអាចតើ។ អ៊ីចឹង បើវា វិមតិសង្ស័យដូច្នេះ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។

[១០:០៨:១៨]

ចំណែកឯ ក្រុមអ្នកជំនាញក៏ស្ទាក់ស្ទើរក្នុងការសន្និដ្ឋាន ថែមទាំងលើសពីអ្វីដែលច្បាប់ អ.វ.ត.ក បានចែងក្នុងមាត្រា១ ការកំណត់អ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម និងការរំលោភធ្ងន់ធ្ងរលើច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដោយប្រើពាក្យថា ករណីនេះហាក់ដូចជាការពិត។ អ្នកជំនាញក៏អ៊ីចឹងទៀត ប្រើថាករណីនេះហាក់ដូចជាការពិត។ បើវាគ្រាន់តែហាក់ដូចជាការពិតទេ ជនជាប់ចោទត្រូវបានរួចខ្លួនហើយ វាជាផលប្រយោជន៍របស់ជនជាប់ចោទ។

[១០:០៩:០៥]

បើផ្អែកតាមច្បាប់របស់ អ.វ.ត.ក ដែលមានលក្ខណៈរួមបញ្ចូលគ្នានៃបទដ្ឋានព្រហ្មទណ្ឌ និងបទដ្ឋានរដ្ឋបាលសំដៅកាត់ក្តីចោះៗលើមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យ គឺទាមទារឲ្យអង្គជំនុំជម្រះពិចារណាឲ្យស៊ីជម្រៅលើយុត្តាធិការបុគ្គល ដោយផ្អែកលើច្បាប់រដ្ឋបាលរបស់ជាតិជាមូលដ្ឋានសម្រាប់កំណត់អត្តសញ្ញាណនៃអ្នកទទួលខុសត្រូវខ្ពស់បំផុត។ ករណីដូចជា ឌុច គឺមានឯកសារច្បាប់ជាតិ បានកំណត់យ៉ាងច្បាស់ណាស់ អំពីតួនាទី និងឋានានុក្រមផ្លូវច្បាប់របស់គាត់ដែលពុំមាននៅក្នុងរចនាសម្ព័ន្ធដឹកនាំជាន់ខ្ពស់ និងជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្មដែលប្រព្រឹត្តក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

[១០:១០:១១]

ដូច្នេះ ពុំមានអ្វីគួរឲ្យសង្ស័យទេថា ជនជាប់ចោទត្រូវតែនៅក្រៅយុត្តាធិការរបស់ អ.វ.ត.ក នោះ។ ក្នុងនាមគាត់ជាប្រធានមន្ទីរស-២១ ដែលជាគុកមួយក្នុងចំណោមគុកជិត២០០ នៅកម្ពុជានារបប កម្ពុជាប្រជាធិបតេយ្យ។ មន្ទីរស-២១ មានចំនួនអ្នកទោសដែលស្លាប់តិចជាងគុកដទៃទៀតជាច្រើនដង ក្នុងនោះ ដូចជា គុកចុងជ្រោយ នៅខេត្តកំពង់ឆ្នាំង មានការសម្លាប់អ្នកទោសរហូតដល់១៥ម៉ឺននាក់ និង គុកផ្សេងៗទៀត មានការសម្លាប់ច្រើនលើសលប់។ ចំណុចនេះ ចង់បញ្ជាក់ថា ច្បាប់ អ.វ.ត.ក មិន បានចាត់ទុកជនទាំងឡាយ ដែលមានឋានៈជាមេគុកនៃ ចូលក្នុងប្រភេទនៃអ្នកទទួលខុសត្រូវបំផុតឡើយ គឺនៅក្រៅយុត្តាធិការរបស់ អ.វ.ត.ក។ នេះក៏ជាលក្ខខណ្ឌយុត្តាធិការ ដែលតម្រូវឲ្យតុលាការកំពូល ធ្វើការពិនិត្យឡើងវិញដែរ។ អា១៩៥ គុកនោះវានៅក្រៅយុត្តាធិការរបស់ អ.វ.ត.ក រួច ស-២១ វាជា គុកដែរ ក៏វានៅក្រៅយុត្តាធិការដូចគ្នា វាមិនអាចនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ទេ។ ឬមួយមកពី ស-២១ ហ្នឹងវាសម្លាប់តិចជាងគេ បានវានៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក បើវាសម្លាប់បាន១០ម៉ឺន ២០ម៉ឺន ដូចគេប្រហែលជានៅក្រៅយុត្តាធិការ អ.វ.ត.ក ដូចគេដែរហើយមើលទៅ។

[១០:១២:០៤]

កថាខណ្ឌ១១៩ នៃសាលក្រមរបស់ អ.វ.ត.ក បានលើកឡើងថា ក្នុងចំណោមមន្ទីរសន្តិសុខនានា មានតែស-២១ តែមួយគត់ដែលមានលក្ខណៈពិសេស ដោយសារមានទំនាក់ទំនងផ្ទាល់នឹងគណៈមជ្ឈិម និងមិនមានតួនាទីឃុំខ្លួន សម្លាប់កម្មាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជា។ អ៊ីចឹងទីមួយ យើងឃើញថា ស-២១ តែមួយគត់ វាពិសេសបានគេយកមកកាត់ ឌុច ហ្នឹងមកកាត់ទោស វាពិសេស ពិសេសត្រង់ស្អី ពិសេសត្រង់ថាគាត់មានលក្ខណៈពិសេសហ្នឹង ដោយសារគាត់ទំនាក់ទំនងផ្ទាល់ជាមួយគណៈមជ្ឈិម។ នៃចំណុចហ្នឹង បានជា អ.វ.ត.ក យកតែស-២១ គត់ យកមកកាត់ទោស ឯអ្នកដទៃទៀតគ្មានទំនាក់ ទំនងផ្ទាល់ជាមួយនឹងគណៈកម្មការមជ្ឈិមបក្សទេ បានជា អ.វ.ត.ក មិនយកមកកាត់ទោស។

[១០:១៣:០១]

ខ្ញុំសុំតុលាការមេត្តាពិនិត្យ ចុះគុកនៅបូព៌ាកាន់កាប់ផ្ទាល់ដោយ សោ ភឹម ដែលជាបុគ្គលទីបី ក្នុង អចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា អាហ្នឹងមិនមានទំនាក់ទំនងផ្ទាល់ជាមួយគណៈកម្មការមជ្ឈិមទេអី សូមតុលាការពិចារណាមើល។ ចុះគុកនៅនិរតី ដែលកាន់កាប់គ្រប់គ្រងផ្ទាល់ដោយ ឈិត ជឿន ហៅ ម៉ុក របស់ តាម៉ុក អ្ហ៎! ដែល តាម៉ុក កាន់ផ្ទាល់ អ្ហ៎! រួច តាម៉ុក ហ្នឹងជាបុគ្គលទីបួន ក្នុងមជ្ឈិមបក្ស។ នៃ អាហ្នឹងមិននៅម៉េចក៏វានៅក្រៅយុត្តាធិការរបស់បុគ្គល? អាហ្នឹងហើយមិនមែនទំនាក់ទំនងផ្ទាល់ជាមួយ

គណៈមជ្ឈិមទេអី ព្រោះតា ម៉ុក ហ្នឹងវាបុគ្គលទីបួន នៃមជ្ឈិមបក្ស។ រួចមកពិសេសអីតែស-២១ ដែលគ្រប់គ្រងដោយ សុន សេន ដែលជាបុគ្គលទីប្រាំពីរក្នុងអចិន្ត្រៃយ៍មជ្ឈិមបក្សទៅវិញ។ នេះសូមតុលាការពិចារណា។

ចំណុចទី២ វាពិសេសទី២ ត្រង់ស-២១ មានតួនាទីឃុំខ្លួន សម្លាប់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា អ៊ីចឹងយកប្រធានស-២១មកនេះ មកកាត់ទោសនេះ គឺដើម្បីរកយុត្តិធម៌ឲ្យអ្នកណា? ពីព្រោះអាស-២១ ហ្នឹងក្រែងគេយកតែពួក-- មានមួយចំនួនទេដែលអ្នកទើបនឹងត្រូវគេយកទៅសម្លាប់ក្នុងនុំង ហ្នឹងមួយចំនួនធំ មួយម៉ឺនជាងតាមខ្ញុំមើលទៅនេះ វាសុទ្ធតែបាតដៃប្រឡាក់ឈាម។ ឧទាហរណ៍ កុយ ធួន, ជូ ជេត ហៅ ស៊ី មួយគរគោកហ្នឹង វន វ៉េត អីហ្នឹង មុនគេយកមកចូលស-២១ តើពួកហ្នឹងសម្រេចសម្លាប់ប្រជាជនអស់ប៉ុន្មាននាក់? អ៊ីចឹងខ្ញុំបាទពិចារណាគឺថា ឃើញថានេះជាកត្តាកត្តាមួយដែលតម្រូវឲ្យតុលាការកំពូលធ្វើការពិចារណាថែមទៀត។

[១០:១៥:១០]

នៅកថាខណ្ឌ៦៧៧ អង្គជំនុំជម្រះរកឃើញថា កាំង ហ្គេកអ៊ាវ ហៅ ឌុច មានពិរុទ្ធភាព នែ៎! អង្គជំនុំជម្រះសាលាដំបូងរកឃើញថា មានពិរុទ្ធភាព។ ពិរុទ្ធភាពទីមួយ គឺបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិយ៉ាងម៉េច? គេថាតា ឌុច នេះ ធ្វើអាខែងអ្នកនៅស-២១ ដែលគេចាប់យកមកឲ្យទៅជាទាសករ ហើយចុះអា១៩៥ គុកទៀតហ្នឹង មិនធ្វើឲ្យទៅជាទាសករដែរ ឬក៏យ៉ាងម៉េច? គេធ្វើឲ្យទៅជាសេដ្ឋីអា១៩៥គុកទៀតហ្នឹងបានជាវារួចខ្លួន។ បានជាតុលាការមិនរកយុត្តិធម៌ឲ្យ។

ទីពីរ គេថាតា ឌុច យកមកឃុំឃាំងនៅក្នុងមន្ទីរឃុំឃាំង ចុះអា១៩៥ គុកទៀតហ្នឹង អត់ដាក់ក្នុងមន្ទីរឃុំឃាំង ឬយ៉ាងម៉េច? គេយកទៅដាក់ក្នុងសណ្ឋាគារ បានតុលាការអត់រកយុត្តិធម៌ឲ្យ? អានេះខ្ញុំឆ្ងល់អ៊ីចឹង។

[១០:១៦:១៣]

មួយទៀតគេថា តាឌុច នៅសាលក្រមដដែល បើតាឌុច ជាប់បទឧក្រិដ្ឋបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ១៩៤៩ ដោយថា គាត់ហ្នឹងបានធ្វើមនុស្សឃាតដោយចេតនា។ អ៊ីចឹង ខ្ញុំសួរទៅ ខ្ញុំពិចារណាទៅ ថាសុំឲ្យតុលាការពិចារណាដូចខ្ញុំដែរ ថាសុំឲ្យពិចារណាទៅ ហើយចុះអា១៩៥ គុកទៀតហ្នឹង ធ្វើមនុស្សឃាតដោយអចេតនាអីបានអត់រកយុត្តិធម៌ឲ្យ? ថាតាឌុច នៅស-២១ ធ្វើទារុណកម្មគេ ហើយចុះអា១៩៥ គុកហ្នឹង អត់ធ្វើទារុណកម្មទេអី បានជាតុលាការមិនរកយុត្តិធម៌ឲ្យ?

អ្ហ៊ុក! ថា ស-២១ ធ្វើបាបដោយអមនុស្សធម៌ ដកហូតដោយចេតនាពីឈ្លើយសឹកជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌និងទៀងទាត់។ ចុះអា១៩៥ គុកទៀតនោះ បានកាត់ទោសដោយយុត្តិធម៌ហើយឬនៅ បានជា អ.វ.ត.ក មិនរកយុត្តិធម៌ឲ្យ?

[១០:១៧:១៣]

អ្ហ៊ុក! មួយទៀត គេថាយកស-២១ នេះ គាត់ហ្នឹងវាខូចដោយសារការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ឃុំខ្លួនជនស៊ីវិលដោយខុសច្បាស់ ហើយចុះអា១៩៥ គុកទៀតនេះ ឃុំខ្លួនជនស៊ីវិលហ្នឹងដោយត្រូវច្បាប់អី? បានជាតុលាការមិនរកយុត្តិធម៌ឲ្យ? សុំតុលាការពិចារណា។ ហើយក្នុងសាលក្រមពិចារណា ១២.៣៧៣ នាក់ សម្លាប់នៅស-២១ វាខុសច្បាប់បានជាយកគាត់មកកាត់ទោស។ អ៊ីចឹង អា១៩៥ គុកទៀតនោះសម្លាប់អស់រាប់លាន អាហ្នឹងស្លាប់យ៉ាងម៉េច? ត្រូវច្បាប់? សម្លាប់ដោយត្រូវច្បាប់បានមិនរកយុត្តិធម៌ឲ្យ?

[១០:១៧:៥៨]

ដូច្នេះ ប្រធានគុកនៅក្នុងសាលក្រម! ប្រធានគុកដទៃទៀតចាត់ទុកជាចារី មិនត្រូវយកមកកាត់ទោស។ សូមតុលាការពិចារណាទៅ? ប្រធានគុក១៩៥ គុកជាចារី។ គុក ឌុច នេះ ស-២១ វាជាប្រធានគុកដែរ វាត្រូវតែជាចារីដូចគ្នា។ អ្ហ៊ុក! ក្នុងសាលក្រមពោលអះអាងថា ឌុច មិនមែនចារីដូច១៩៥ គុកទៀតទេ។ តើសមរម្យទេ? ត្រឹមត្រូវទេ? រួចខាងព្រះរាជអាជ្ញាគាត់បាននិយាយដែរគាត់ថា នៅក្នុងសាលក្រមអ៊ីចឹងអីនៅក្នុងនោះ? នៅក្នុងចម្លើយតបមកមេធាវីហ្នឹង? គាត់ថាគ្មានច្បាប់ឯណាឲ្យគាត់ចោទទៅលើ១៩៥គុកទៀតជាចារីទេ គាត់អត់មានសិទ្ធិចោទជាចារីនោះទេ។ ហើយអ៊ីចឹង តាឌុច ចោទទៅលើ តាឌុច នោះកើត? បើតាឌុច ប្រធានគុកដូចគ្នា មិនចារីដូចគ្នា? នេះសូមតុលាការពិចារណា។

[១០:១៨:១០]

ដូច្នេះ ឌុច ជាចារីដូចមេគុកទាំង១៩៥គុក។ ឌុច ត្រូវតែនៅក្រោយុត្តាធិការរបស់ អ.វ.ត.ក ដូចមេគុកទាំង១៩៥គុតទៀតដែរ។ លក្ខខណ្ឌទាំងអស់នេះហើយ ជាលក្ខខណ្ឌយុត្តាធិការដែលសំណូមពរឲ្យតុលាការកំពូលធ្វើការពិចារណាឡើងវិញ។

[១០:១៨:៤៣]

នៅដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលត្រូវធ្វើការកែប្រែបានចោទថា "ក្នុងនាមជាអនុលេខាមន្ទីរស-២១ ជនជាប់ចោទបានដឹកនាំក្រុមសួរចម្លើយ និងបានចូលរួមក្នុងការរៀបចំផែនការបង្កើតស-២១

និងបង្រៀនបុគ្គលិកបច្ចេកទេសសួរចម្លើយ។ ក្នុងនាមជាប្រធានស-២១ តួនាទីរបស់គាត់ពិនិត្យមើលប្រតិបត្តិការទាំងមូល ដោយរួមបញ្ចូលទាំងការធ្វើចំណាររនៅលើចម្លើយសារភាព និងបញ្ជាឲ្យសម្លាប់។

មន្ទីរស-២១ គឺជាមន្ទីសសន្តិសុខសំខាន់បំផុតរបស់កម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានចាត់ទុកជាផ្នែកមួយនៃរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា ដោយរាយការណ៍ទៅថ្នាក់ដឹកនាំខ្ពស់បំផុតរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយធ្វើប្រតិបត្តិការពាសពេញប្រទេស និងទទួលកម្មាភិបាលឋានៈខ្ពស់ និងអ្នកទោសសំខាន់ៗ ។ល។"

[១០:២០:៤៦]

ករណីនេះ អង្គជំនុំជម្រះបានយល់ស្របដោយមិនត្រឹមត្រូវជាមួយនឹងការសំអាងលេសដែលគ្មានមូលដ្ឋានគតិយុត្តិសមហេតុផលរបស់ដើមចោទ ក្នុងការដាក់បន្ទុកឲ្យជនជាប់ចោទស្ថិតក្នុងប្រភេទនៃអ្នកទទួលខុសត្រូវខ្ពស់បំផុត ដោយសំអាងថា ស-២១ ជាមន្ទីរសន្តិសុខសំខាន់ ធ្វើប្រតិបត្តិការពាសពេញប្រទេស។ ការសំអាងបែបនេះពុំមានលក្ខណៈតក្កក្នុងវិស័យច្បាប់ សម្រាប់លើកយកមកបង្ហាញអំពីការធ្វើអត្តសញ្ញាកម្មនៃអ្នកទទួលខុសត្រូវនោះទេ។ សួរថាតើច្បាប់តម្រូវឲ្យវិនិច្ឆ័យទោសស្ថានប័នពន្ធនាគារដែលមានវិសាលភាពពាសពេញប្រទេសនោះ ឬមួយក៏វិនិច្ឆ័យទោសបុគ្គលអ្នកប្រព្រឹត្ត-- អ្នកទទួលខុសត្រូវខ្ពស់បំផុត។

[១០:២១:៤៨]

តាមទ្រឹស្តីច្បាប់ការធ្វើអត្តសញ្ញាកម្មនៃអ្នកទទួលខុសត្រូវខ្ពស់បំផុត គឺផ្អែកលើអំណាចឆន្ទៈរបស់បុគ្គលនោះតាមរយៈឋានានុក្រមដែលកំណត់ក្នុងច្បាប់រដ្ឋបាល។ បញ្ហានៅត្រង់ថា ក្នុងឋានៈជាលេខាមន្ទីរស-២១ ឌុច មានតួនាទីត្រឹមតែចាំទទួលអ្នកទោសដែលបានបញ្ជូនមកគ្រប់ទិសទី សួរចម្លើយ រួចហើយបញ្ជូនឲ្យកម្ទេចតាមបញ្ជាថ្នាក់លើតែប៉ុណ្ណោះ។ ដូច្នេះ អំពើនេះមិនចាត់ទុកជាលក្ខណៈទទួលខុសត្រូវខ្ពស់បំផុតនោះទេ ព្រោះពុំចេញពីអំណាចឆន្ទៈរបស់ខ្លួនផ្ទាល់ ហើយបានអនុវត្តដូចគ្នានឹងប្រធានសន្តិសុខផ្សេងៗទៀតទូទាំងប្រទេស។

[១០:២២:៤៤]

ហេតុផលចោទប្រកាន់មួយទៀតដែលខុសឆ្គងជាងនេះ ដោយចោទថា "មន្ទីរស-២១ ត្រូវបានចូលរួមបង្កើតដោយជនជាប់ចោទ"។ ករណីនេះ មិនពិតទេ។ បើសំអាងលើឋានៈតូចតាចជាអនុលេខាមន្ទីរស-២១ និងសំអាងលើកក្របខ័ណ្ឌនយោបាយដែលមិនមែនជាសមាជិកអចិន្ត្រៃយ៍បក្សនោះទេ

ជនជាប់ចោទគ្មានសមត្ថភាពក្នុងផ្លូវអំពើ ក្នុងការបញ្ចេញមតិ និងផ្តល់ជាគំនិតជូនទៅបក្សនូវរាល់បញ្ហាដែលទាក់ទងនឹងគោលនយោបាយសន្តិសុខរបស់ជាតិឡើយ។ ការចោទប្រកាន់បែបនេះ មិនសមហេតុមិនសមផលទេ។

ជាការពិត អ្នកច្បាប់ទូទៅតែងតែទទួលស្គាល់ថា ស្ថាប័នពន្ធនាគារជាឧបករណ៍នៃអំណាចរបស់រដ្ឋ។ ដូច្នេះ រាល់ការបង្កើត ការរំលាយ ឬការផ្លាស់ប្តូរ គឺត្រូវស្ថិតនៅក្រោមការសម្រេចរបស់រដ្ឋ ពុំមែនបុគ្គលម្នាក់ ឬពីរនាក់ជាលក្ខណៈរូបវន្តអាចសម្រេចបង្កើតបានទេ។ ជាក់ស្តែង មន្ទីរស-២១ បានបង្កើតឡើងតាមរយៈសេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិមនាកិច្ចប្រជុំអចិន្ត្រៃយ៍បក្សក្នុងខែតុលា ឆ្នាំ ១៩៧៥ ដោយបានប្រគល់សិទ្ធិឲ្យ សុន សេន ដែលជាសមាជិកអចិន្ត្រៃយ៍របស់បក្ស ជាអ្នកទទួលខុសត្រូវលើបញ្ហាសន្តិសុខ។

[១០:២៤:២៤]

ជាក់ស្តែងជាទូទៅ គ្រប់ប្រទេសទាំងអស់លើសាកលលោកតែងយកពន្ធនាគារនគរបាលយោធាកងរាជអាវុធជាឧបករណ៍នៃអំណាចរបស់រដ្ឋ រដ្ឋជាអ្នកបញ្ជាឧបករណ៍ បើវាខុសត្រូវយ៉ាងណា រដ្ឋជាអ្នកទទួលខុសត្រូវ ព្រោះរដ្ឋជាអ្នកបញ្ជា។ រដ្ឋហ្នឹងមាន ប៉ុល ពត នាយករដ្ឋមន្ត្រី មាន សុន សេន ជាឧបនាយករដ្ឋមន្ត្រី ជាអ្នកបញ្ជាមិនមែនរដ្ឋជាអ្នកបញ្ជា ហើយដល់ពេលខុសទៅយកឧបករណ៍ដាក់គុកនោះទេ ហើយ កាំង ហ្គេកអ៊ាវ នៅពេលនោះជាឧបករណ៍។ ឧបករណ៍ត្រូវតែនៅក្រោយយុត្តាធិការរបស់ អ.វ.ត.ក។ នេះជាលក្ខខណ្ឌយុត្តាធិការ ដែលតម្រូវឲ្យតុលាការកំពូលធ្វើការពិចារណាឡើងវិញ។

[១០:២៥:១៧]

នៅក្នុងវាក្យខណ្ឌ២ នៃកថាខណ្ឌ៣៣ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលយោងទៅលើកំណត់ហេតុនៃការសួរចម្លើយបានបង្ហាញក្នុងន័យថា ជនជាប់ចោទក្នុងនាមជាលេខាមន្ទីរស-២១ ក៏ពិតមែនប៉ុន្តែពុំមានអំណាចផ្លូវច្បាប់ពេញលេញក្នុងការគ្រប់គ្រងលម្អិតនោះទេ គឺគាត់មានត្រឹមតែអំណាចធ្វើការផ្សព្វផ្សាយពីថ្នាក់លើតែប៉ុណ្ណោះ។ នេះបើយើងរៀបរាប់ពីឋានៈក្នុងបក្សវិញ វាមាន៥ថ្នាក់ គឺមានលេខាដូចលេខាមជ្ឈិមបក្សអ៊ីចឹងគឺ ប៉ុល ពត។ បន្ទាប់មក ទីពីរលេខាភូមិភាគ ឬលេខាកងពលធំហ្នឹង។ ទីបីលេខាគណៈកម្មាធិការតំបន់ លេខាគណៈកម្មាធិការកងពលតូច លេខាក្រសួង អាហ្នឹងឋានៈទីបី។ ទីបួនលេខាគណៈកម្មាធិការបក្សស្រុក លេខាគណៈកម្មាធិការវរសេនាធំ ឬក៏មួយទៀតស្មើនឹងលេខាគណៈកម្មាធិការមន្ទីរ ដូច តាឌុច អ៊ីចឹង។ អ៊ីចឹង តាឌុច វានៅលំដាប់ថ្នាក់ទីបួន ហើយដល់អាទីប្រាំ គឺលេខា

សាខាដែលឋានៈតូចជាគេបំផុតក្នុងបក្ស។

ដូច្នេះ ក្នុងជួរបក្ស ឌុច ជាលេខាតូចតាចមិនមានសិទ្ធិអំណាចអាអ្វីឲ្យធ្វើ អាចធ្វើសេចក្តីសម្រេចរបស់ ឬក៏ចាត់ចែងខុសពីសេចក្តីសម្រេចរបស់បក្សថ្នាក់លើបានទេ ហេតុនេះមិនអាចគាត់ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតបានទេ។

[១០:២៦:៥៧]

តាមទស្សនៈរបស់ចៅក្រម ខាតវ៉ាយច៌ ក៏បានយល់ឃើញដែរថា “បក្សកុម្មុយនីស្តកម្ពុជាជាអ្នកកំណត់អត្តសញ្ញាណខ្មាំង និងជាញ៉ីកញាប់ជាអ្នកបញ្ជាឲ្យធ្វើការចាប់ខ្លួន។” គាត់បានបញ្ជាក់បន្ថែមទៀតថា “ជនជាប់ចោទមិនបានដឹងអំពីសេចក្តីសម្រេចសម្លាត់បំផុតចុះថ្ងៃទី៣០ មីនា ៧៦ នោះទេ។” ដូច្នេះហើយ មិនអាចនិយាយថា គាត់បានចូលរួមចំណែករៀបចំគោលនយោបាយទាំងនេះនោះទេ។ ហេតុផលច្បាស់លាស់ទាំងនេះ បញ្ជាក់ថា ឌុច ពុំមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដូចដែលបានលើកឡើងខាងលើនេះទេ។ នេះក៏ជាលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌយុត្តាធិការទាំងឡាយ ដែលសូមឲ្យតុលាការកំពូលធ្វើការពិនិត្យឡើងវិញ។

[១០:២៧:៥០]

ភស្តុតាងជាច្រើនទៀត ដែលបញ្ជាក់ថា ឌុច គ្មានសិទ្ធិអំណាចក្នុងការសម្រេចឲ្យចាប់ ឬបញ្ជាឲ្យសម្លាប់អ្នកទោសទេ។ ករណីដូចជាការស្លាប់របស់ កុយ ធួន, ឆាយ គឹមហ៊ា, វន វ៉េត, ណាត គឺស្លិតក្រោមការសម្រេចឲ្យចាប់ខ្លួន និងឲ្យកម្ទេចពីថ្នាក់លើទាំងអស់។ ពិសេសក្រោមបញ្ជារបស់ សុន សេន និងអ្នកទោសជាច្រើនទៀត ដូចជាលោកសាស្ត្រាចារ្យ ភឹង គុន, វ័ន្ត គត់ និងមិត្តភក្តិមួយចំនួនធំព្រមទាំងប្អូនថ្លៃរបស់ខ្លួនផ្ទាល់ (របស់ ឌុច) ក៏ពុំមានសិទ្ធិអន្តរាគមន៍ ឬសម្រេចអ្វីទាំងអស់។ លក្ខណៈទាំងនេះហើយ ដែលបញ្ជាក់ថា ឌុច ពុំមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនឹងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់ជាតិ និងអន្តរជាតិនោះទេ។ ទាំងអស់នេះ ក៏សុទ្ធតែជាលក្ខខណ្ឌយុត្តាធិការទាំងអស់ ដែលទាមទារឲ្យតុលាការកំពូលមេត្តាពិនិត្យឡើងវិញ។

[១០:២៨:៥០]

**ប្រធានអង្គជំនុំៈ**

សូមជម្រាបលោកមេធាវី ឥឡូវនេះយើងដល់ម៉ោងសម្រាកហើយ។ អ៊ីចឹង លោកនៅសល់៥០នាទីទៀត។ អ៊ីចេះ ដូចចាំចូលមកវិញ ចាំលោកមាន-- ធ្វើបន្ត។

ដូច្នេះ តុលាការប្រកាសសម្រាកសាមសិបនាទី។ ម៉ោងដប់មួយយើងនឹងបន្តកិច្ចសវនាការបន្តទៅទៀត។ សូមសម្រាក។

*(សវនាការសម្រាកពីម៉ោង ១០:៣០ នាទី ដល់ម៉ោង ១០:៥៩ នាទី)*

[១០:៥៩:០០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

បាទ, តុលាការប្រកាសបន្តសវនាការ។ សូមអញ្ជើញលោកមេធាវីការពារជនជាប់ចោទបន្ត។

**លោក ការ សាវុត្ថ៖**

សូមអនុញ្ញាតធ្វើសេចក្តីសន្និដ្ឋានបន្ត។ ដោយខ្វះខាតពេលវេលា ខ្ញុំសំណូមពរតុលាការកំពូលមេត្តាពិនិត្យទៅលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ត្រង់មាត្រា៩៩ មិនទុកជាអំពើល្មើសក្នុងបទព្រហ្មទណ្ឌទេ កាលណាបើអំពើទាំងឡាយនោះធ្វើតាមបង្គាប់របស់ច្បាប់ ហើយអ្នកបញ្ជាឲ្យធ្វើក៏ជាអាជ្ញាធរធម្មានុរូប។ អ៊ីចឹង តាមបង្គាប់របស់ច្បាប់ពេលនោះ គឺតាមបង្គាប់របស់មាគ៌ា ហើយម្ចាស់មាគ៌ាមិនមែន តាឌុច ទេ ហើយបើអ្នកបញ្ជាឲ្យធ្វើក៏ជាអាជ្ញាធរធម្មានុរូប។ អ្នកបញ្ជាឲ្យធ្វើគឺ សុន សេន ដែលជាឧបនាយករដ្ឋមន្ត្រីជាអាជ្ញាធរធម្មានុរូប។ ដូច្នេះ ឌុច មិនចាត់ទុកជាបទល្មើសទេ ចំពោះឌុច។

[១១:០០:៣១]

ទីពីរ សូមឲ្យតុលាការកំពូលមេត្តាពិនិត្យមើលមាត្រា២៣៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដដែល និងមាត្រា២៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ព្រោះមាត្រាពីរហ្នឹងវាស៊ីសងគ្នាទេ។ គឺថាអ្នកបញ្ជាត្រូវផ្តន្ទាទោស អ្នកអនុវត្តបញ្ជាត្រូវរួចខ្លួន។ ព្រោះថានៅក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មាត្រា២៤ហ្នឹង បុគ្គលម្នាក់ៗទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនរបស់ខ្លួនប៉ុណ្ណោះ ហើយចំណែកអំពើរបស់ ឌុច មិនមែនជាអំពើផ្ទាល់ខ្លួនទេ គឺតាមបញ្ជារបស់ថ្នាក់លើ វាមិនមែនចេញពី ឌុច ផ្ទាល់ទេ។ នេះជាចំណុចមួយ។

ហើយទីពីរ ក្នុងការបញ្ជានេះសូមឲ្យតុលាការពិនិត្យមើលចុះ នៅក្នុង កាលឆ្នាំ១៩៧០ មក៧៥ ន៉ៃ រីឆាល និចសុន ប្រធានាធិបតីអាមេរិកដែលបញ្ជាឲ្យលោក គ្រៃថុនអាប្រាម ហ្នឹង មកបញ្ជាឲ្យ

ទម្លាក់គ្រាប់នៅស្រុកខ្មែរនៅកម្ពុជា។ រួចពីឡុតអាមេរិកនេះ គឺថា ក្រៃថុនអាប្រាម ហ្នឹង បញ្ជាពីឡុតអាមេរិកឲ្យមកទម្លាក់ សួរថាតើ ក្រៃថុនអាប្រាម ហ្នឹង ដឹងថាបញ្ជា រីឆាល និចសុន ខុសដែរ? ខុសវាគ្មានច្បាប់អាមេរិកណាចែងអ៊ីចឹង។ ដឹង មិនមែនមិនដឹងទេ ក៏ប៉ុន្តែមិនដឹងធ្វើម៉េច បើមេបញ្ជា ហើយពីឡុតអាមេរិកក៏ដឹងដែរ ដឹងថា ក្រៃថុនអាប្រាម ហ្នឹង បញ្ជាឲ្យមកទម្លាក់គ្រាប់បែកហ្នឹង ដឹងថាវាខុសប៉ុន្តែមិនដឹថាធ្វើម៉េច មេបញ្ជា។ អ៊ីចឹងហើយ បានជាអ្នកបញ្ជាវាត្រូវមានទោស អ្នកអនុវត្តបញ្ជាត្រូវរួចខ្លួន។ នេះ ខ្ញុំសូមសង្ខេបដោយខ្លីតែប៉ុណ្ណឹង។

[១១:០២:១១]

ហើយទីពីរ ខ្ញុំសូមនិយាយអំពីទោស (សុំទោស) និយាយអំពីពីឆ្នាំ១៩៧៥ ដល់មក ១៧ មេសា ៧៥ មកដល់ថ្ងៃ៣០ មីនា ១៩៧៦ ក្នុងចន្លោះពេលហ្នឹង ឌុច គាត់នៅអមលាំង។ ហើយគាត់មកដល់ពេលចូលមកភ្នំពេញ គាត់ជាអនុប្រធានគុក។ ដូច្នេះ គាត់អត់មានពាក់ព័ន្ធនឹងការបង្កើតគុកទេ គាត់ត្រូវរួចខ្លួនហើយអាម៉ាចន្លោះពេលហ្នឹង ហើយគាត់នៅអមលាំងឯណោះ អាជម្លៀសកាប់សម្លាប់ប្រជាជនចេញពីភ្នំពេញទៅ គាត់អត់បានដឹងទេ។ នេះជាចំណុចទីមួយដែលត្រូវគាត់រួចខ្លួន ជាថ្នាក់ទាប។

[១១:០២:៥៧]

ហើយទីពីរ ចាប់ពីថ្ងៃទី៣០ មីនា ១៩៧៦ រហូតដល់ ៦ មករា ១៩៧៩ ខ្ញុំសំណូមពរឲ្យតុលាការពិនិត្យមើលឯកសារលេខ ០០០០៣១៣៦ សូន្យបួនដង ៣១៣៦ នេះ ៣៤៣៦ ដែលសហព្រះរាជអាជ្ញាបានដាក់ឯកសារនេះចូលក្នុងសំណុំរឿង។ រួចឯកសារនេះគឺមានឈ្មោះគ្រប់គ្រាន់ៗ អ្នកមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ-- អឺ! អ្នកទទួលខុសត្រូវខ្ពស់បំផុត គឺមេដឹកនាំ។ មុនដំបូងមេដឹកនាំ។ មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យមានឈ្មោះនៅហ្នឹង គឺថាសេចក្តសម្រេចរបស់គណៈមជ្ឈិមអ្នកណាគណៈមជ្ឈិម? គណៈមជ្ឈិមមានគ្នាប៉ុន្មាននាក់? អចិន្ត្រៃយ៍មជ្ឈិមបក្សហ្នឹង មានគ្នាប្រាំពីរនាក់ឃើញទេ? ហ្នឹងហើយមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យដែលវាដឹកនាំឲ្យកាប់សម្លាប់។

[១១:០២:៥៧]

បន្ទាប់មកទៀត សួរថាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មហ្នឹង អ្នកណាខ្លះ? មាននៅក្នុងហ្នឹងទៀត។ អាប្រាំពីរក្បាលហ្នឹង អាប្រាំពីរនាក់ហ្នឹង វាចាត់តាំងមនុស្សបួនក្រុមឲ្យមកកាប់សម្លាប់មួយស្រុកខ្មែរហ្នឹង។

[១១:០៤:០៣]

ក្រុមទីមួយ គឺថាសិទ្ធិសម្រេចកម្ទេចក្នុងជួរនិងក្រៅជួរ មានឯកសារគ្រប់គ្រាន់។ ឃើញទេ? ទីមួយ បើនៅក្នុងក្របខ័ណ្ឌមូលដ្ឋាន ត្រូវអចិន្ត្រៃយ៍ភាគសម្រេច។ អ៊ីចឹង អចិន្ត្រៃយ៍ភាគមួយស្រុកខ្មែរហ្នឹង មានភាគប៉ុន្មានភូមិភាគ? មានប្រាំពីរភូមិភាគ ហើយសួរថាប្រាំពីរភូមិភាគហ្នឹង មាន តាឌុច ទេ? តាឌុច គុកស-២១ អត់មានទេ។ ដូច្នេះ ឌុច អត់មានទេ។ ឃើញទេ?

[១១:០៤:២៦]

មកក្រុមទីពីរ មើលឲ្យជុំវិញមន្ទីរមជ្ឈិម។ ជុំវិញមន្ទីរមជ្ឈិម ត្រូវគណៈមន្ទីរមជ្ឈិមសម្រេច ហើយគណៈមន្ទីរមជ្ឈិមអ្នកណា? លេខាមន្ទីរ៨៧០ មិនមែន តាឌុច ទេ តាឌុច ស-២១ ឃើញអត់មាន តាឌុច ទៀត។ ហើយក្រុមទីបី តំបន់ឯករាជ្យត្រូវអចិន្ត្រៃយ៍សម្រេច។ តំបន់ឯករាជ្យឯណាខ្លះ? កំពង់សោម សៀមរាប ព្រះវិហារ ឧត្តរមានជ័យ។ ហ្នឹងតំបន់ឯករាជ្យ ហើយមានតា ឌុច ឯណា។ តំបន់ឯករាជ្យហ្នឹងត្រូវអចិន្ត្រៃយ៍ អចិន្ត្រៃយ៍អ្នកណា? លេខាអចិន្ត្រៃយ៍ ប៉ុល ពត ជាអ្នកសម្រេចអាហ្នឹង។

[១១:០៥:០២]

មកដល់ក្រុមទីបួន កងទ័ពមជ្ឈិមត្រូវសេនាធិការសម្រេច។ សេនាធិការអ្នកណា? សុន សេន មាន តាឌុច ឯណា គេអត់មានចាត់តាំង តាឌុច ឲ្យទៅសម្រេចកាប់សម្លាប់មនុស្សអត់មានទេ។ គាត់ចាំតែទទួលតាមបញ្ជាគេទេតើ។ ដូច្នេះ នៅក្នុងឯកសារហ្នឹងមានឈ្មោះគ្រប់គ្រាន់ទាំងអស់ អត់មានត្រូវមកពាសវាលពាសកាលអីអត់មានទេ។ នេះមានត្រឹមត្រូវទាំងអស់។

ហ្នឹងសូមឲ្យតុលាការមេត្តាពិនិត្យឯកសារហ្នឹង ដើម្បីកំណត់ថាអ្នកណាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម។ មិនមែន តាឌុច ទេ។ នេះជាឯកសារសំអាង។ ឯកសារច្បាប់ជាតិ។

[១១:០៥:៤២]

ហើយតទៅទៀតជាចំណុចទីពីរ គឺខ្ញុំសូមឲ្យតុលាការមេត្តាអនុវត្តតាមមាត្រា១២៦ (ថ្មី) រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ រដ្ឋធម្មនុញ្ញថ្មីហ្នឹង គេចែងច្បាស់ណាស់ ថាកាត់ជម្រះក្តីយុត្តិធម៌ត្រឹមត្រូវ។ យុត្តិធម៌ត្រឹមត្រូវ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរតាមនីតិវិធី និងតាមច្បាប់ជាធរមាន។

យុត្តិធម៌ត្រឹមត្រូវ គឺថាត្រូវអនុវត្តទៅតាមនីតិវិធី រួចទៅមើលនីតិវិធី នីតិវិធីមាត្រា១២។ នីតិវិធីរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានបញ្ជាក់ហើយ ក្នុងមាត្រា១២ នីតិវិធីហ្នឹង គេថាឲ្យប្រើច្បាប់ខ្មែរ ឲ្យប្រើច្បាប់ជាតិ ព្រោះតុលាការនេះ ជាតុលាការជាតិ វាមិនមែនជាតុលាការ

អន្តរជាតិទេ ជាតុលាការជាតិ។ ដូច្នេះ តុលាការជាតិត្រូវប្រើច្បាប់ជាតិ។ អ៊ីចឹង នីតិវិធីមាត្រា១២ គេបញ្ជាក់ច្បាស់ហើយ។

[១១:០៦:៤៣]

អ្ហ៊ក! ច្បាប់ជាធរមាន។ ដូចខ្ញុំបានលើកឡើងអំមិញអ៊ីចឹង។ ច្បាប់ជាធរមាននៅច្រើនណាស់ ក្រមព្រហ្មទណ្ឌរបស់យើង នីតិវិធីព្រហ្មទណ្ឌ ដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យក្រៅច្បាប់ និងកិច្ចព្រមព្រៀងបារីស គឺថាមានគ្រប់គ្រាន់ មិនចាំរត់ទៅរកច្បាប់បរទេសនាំតែហត់ទេ។ នេះជាសំណូមពររបស់ខ្ញុំ។

[១១:០៧:០២]

សំណូមពរទីពីរ គឺសូមឱ្យតុលាការកំពូលមេត្តាអនុវត្តតាមមាត្រា១២៩ រដ្ឋធម្មអនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហើយទីជាបញ្ចប់នេះ គឺខ្ញុំសំណូមពរៗសូមឱ្យចាត់ទុកសាលក្រមសំណុំរឿងលេខ០០១ជាមោឃៈ និងដោះលែង កាំង ហ្គេកអ៊ាវ ហៅ ឌុច ឱ្យមានសេរីភាពឡើងវិញ។

ទីពីរ គឺខ្ញុំសូមឱ្យកំណត់ថា ការឃុំខ្លួន កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាកិច្ចការថែរក្សាការពារសាក្សីមានសក្តានុពល សម្រាប់ចង្អុលបង្ហាញអំពីមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនៅគុកទួលស្លែងតែប៉ុណ្ណោះ។

ហើយជាទីបញ្ចប់នេះ សូមឱ្យលោកមេធាវី កង ឫទ្ធារី ធ្វើសេចក្តីសន្និដ្ឋានបន្ថែម សូមអរគុណ។

**លោក កង ឫទ្ធារីៈ**

ជាដំបូង ខ្ញុំបាទសូមគោរពចំពោះលោកប្រធាននៃអង្គជំនុំជម្រះតុលាការកំពូល និងអង្គជំនុំជម្រះតុលាការកំពូលទាំងមូល ព្រមទាំងសូមអភ័យទោសផង ចំពោះគ្រួសារ ឬគ្រួសារនៃជនរងគ្រោះក្នុងមន្ទីរសន្តិសុខស-២១។ ខ្ញុំមកកាន់ទីនេះ គឺមិនមែនដើម្បីនិយាយបំបិទបាំងនូវឧក្រិដ្ឋកម្មដ៏សាហាវព្រៃផ្សៃនៅឯមន្ទីរស-២១ នោះទេ។ ហើយបើទោះខ្ញុំចង់និយាយបិទបាំងអំពីឧក្រិដ្ឋកម្មដែលកើតឡើងនៅមន្ទីរស-២១ ក៏ខ្ញុំមិនអាចធ្វើបានដែរ ហើយក៏ខ្ញុំសង្ឃឹមថា នៅទីនេះមិនមានអ្នកណាម្នាក់ចង់បិទបាំងអំពីឧក្រិដ្ឋកម្មដែលនៅស-២១ នោះឡើយ។ ខ្ញុំមកទីនេះ ក្នុងនាមជាមេធាវីម្នាក់ ដើម្បីការពារឱ្យអស់លទ្ធភាពតាមផ្លូវច្បាប់ចំពោះជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ស្របតាមសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលថាជនជាប់ចោទមិនស្ថិតនៅក្នុងយុត្តាធិការនៃសាលាជម្រះក្តីនេះទេ។

[១១:០៨:០៦]

ខ្ញុំមកទីនេះ គ្រាន់តែដើម្បីធានាឲ្យប្រាកដថាជនជាប់ចោទទទួលបាននូវសិទ្ធិគ្រប់គ្រាន់ និងទទួលបានការកាត់ក្តីឲ្យបានត្រឹមត្រូវ និងធ្វើឲ្យកាន់តែមានសារប្រយោជន៍ដល់ការផ្តល់ជំនួយផ្នែកច្បាប់ទៅដល់ជនជាប់ចោទតែប៉ុណ្ណោះ។ ខ្ញុំនឹងព្យាយាមធ្វើឲ្យអស់សមត្ថភាពរបស់ខ្ញុំដើម្បីកំណត់ឲ្យឃើញថាតុលាការជាន់ខ្ពស់ គឺតុលាការកំពូលមិនប្រើប្រាស់វេទិកានេះ ជាការសងសឹកផ្នែកនយោបាយគ្នា ឬផ្នែកមនោគមវិជ្ជា ឬក៏ខ្ចីដៃ អ.វ.ត.ក ធ្វើការបោសសម្អាតនយោបាយគ្នាទៅវិញទៅមកតែប៉ុណ្ណោះឯង។

បាទ សូមអរគុណ។

[១១:០៩:៤៨]

ខ្ញុំសូមចាប់ផ្តើមធ្វើសេចក្តីសន្និដ្ឋានដូចតទៅ៖

ក្រោមកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា សាលាជម្រះក្តី អ.វ.ត.ក ត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីបង្កើត ដើម្បីយកមកជំនុំជម្រះ និងផ្តន្ទាទោសជនទាំងឡាយណាដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម អំពើប្រល័យពូជសាសន៍ និងការរំលោភធ្ងន់ធ្ងរទៅលើអនុសញ្ញាណក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩។

[១១:១០:២០]

កិច្ចព្រមព្រៀងនេះ ភាគីទាំងពីរមានគោលបំណងរួមគ្នា ដើម្បីស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជា និងដើម្បីធ្វើឲ្យមានការផ្សះផ្សាជាតិ ការបង្រួបបង្រួមជាតិ និងទទួលបានសន្តិភាព ព្រមទាំងឲ្យគោរពអធិបតេយ្យភាពជាតិកម្ពុជា។

នៅក្នុងពាក្យប្រារព្ធនៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើតសាលាជម្រះក្តី អ.វ.ត.ក បានផ្តើមថាដោយហេតុថា នៅក្នុងសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិ បានក្រើនរំឭកឡើងនូវសេចក្តីព្រួយបារម្ភយ៉ាងធ្ងន់ធ្ងរចំពោះការរំលោភបំពានចំពោះច្បាប់កម្ពុជា និងច្បាប់មនុស្សធម៌អន្តរជាតិ ក្នុងរយៈការនៃរបបកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ការព្រួយបារម្ភនេះ ជាដើមហេតុធ្វើមហាសន្និបាតអង្គការសហប្រជាជាតិបានចេញសេចក្តីសម្រេចរបស់លេខ ៥៧-២២៨ ចុះថ្ងៃទី១៨ ធ្នូ ឆ្នាំ២០០២ ដោយទទួលស្គាល់នូវការព្រួយបារម្ភពេញច្បាប់របស់រដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុងការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថិរភាព សន្តិសុខ និងសន្តិភាព។

[១១:១១:២៧]

នេះគឺជាការទទួលស្គាល់ដោយស្របច្បាប់ នៃសេចក្តីព្រួយបារម្ភរបស់រដ្ឋាភិបាលកម្ពុជា ដោយអង្គការសហប្រជាជាតិ។ នេះជាការទទួលស្គាល់យ៉ាងត្រឹមត្រូវ និងជាសំអាងហេតុមួយមុនគេបង្អស់នៃកិច្ចព្រមព្រៀងបង្កើត អ.វ.ត.ក។ គេក៏អាចរកឃើញផងដែរនូវកំណត់សុវត្ថិភាពនៃក្តីព្រួយបារម្ភនេះនៅក្នុងមាត្រា១។ ខ្ញុំសូមរំឭកឡើងវិញ។ គេក៏អាចរកឃើញផងដែរនូវការកំណត់សុវត្ថិភាពនៃក្តីព្រួយបារម្ភនេះនៅក្នុងមាត្រា១ នៃកិច្ចព្រមព្រៀងនេះ។

មាត្រា១ នៃកិច្ចព្រមព្រៀងនេះ បានកំហិតនៃសិទ្ធិអំណាច អ.វ.ត.ក ដែលជាសមិទ្ធផលរួមរវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើតអ.វ.ត.ក ហើយគេក៏អាច-- ហើយគេក៏បានឃើញសេចក្តីព្រួយបារម្ភនេះ នៅក្នុងមាត្រា១ នៃកិច្ចព្រមព្រៀងនេះ និងមាត្រា១ មាត្រា២ នៃច្បាប់បង្កើតអ.វ.ត.ក ដែលបានដាក់កំហិតយ៉ាងដាច់ណាត់នូវវង្វង់សិទ្ធិអំណាចរបស់សាលាក្តីនេះ។

[១១:១២:២៨]

ក្រោមមាត្រា២ នៃកិច្ចព្រមព្រៀងរវាងអង្គការប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា និងមាត្រា១ មាត្រា២ (ថ្មី) នៃច្បាប់ អ.វ.ត.ក បានផ្តល់សិទ្ធិអំណាចដល់ និងក៏បានដាក់កំហិតនូវយុត្តាធិការលើ អ.វ.ត.ក ផងដែរ។

ទីមួយគឺ អ.វ.ត.ក មានសិទ្ធិអំណាចជំនុំជម្រះតែទៅលើបទឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការរំលោភធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី១២ សីហា ឆ្នាំ១៩៤៩។ ទីពីរ អ.វ.ត.ក មានសិទ្ធិនិងអំណាចជំនុំជម្រះនិងផ្តន្ទាទោសតែទៅលើបទឧក្រិដ្ឋទីមួយដែលបានប្រព្រឹត្តឡើងនៅអំឡុងពេលថ្ងៃ១៧ មេសា ៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩។ ទីបី អ.វ.ត.ក មានសិទ្ធិអំណាចជំនុំជម្រះ និងផ្តន្ទាទោសឧក្រិដ្ឋកម្មនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

[១១:១៣:២២]

ទីបួន អ.វ.ត.ក មានសិទ្ធិអំណាចជំនុំជម្រះ និងផ្តន្ទាទោសតែទៅលើមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម។ នៅក្នុងដំណាក់កាលជជែកដេញដោលក្នុងអង្គសវនាការសាលាដំបូង មេធាវីការជនជាប់ចោទបានលើកឡើងពីភាពគ្មានយុត្តាធិការរបស់ អ.វ.ត.ក លើជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលតម្រូវឲ្យតុលាការ អ.វ.ត.ក ពិនិត្យភស្តុតាងបញ្ជាក់ដែលមិនចងភ្ជាប់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ទៅនឹងមាត្រា១ មាត្រា២ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ ហើយត្រូវបានគាំទ្រយ៉ាងហោចមួយម្នាក់ គឺខាតវ៉ាយថ៍ ដែល

ពោលអះអាងថា ឌុច មិនបានដឹងសេចក្តីសម្រេចចិត្តថ្នាក់លើក្នុងការបែងចែកអំណាចឲ្យមានការកាប់សម្លាប់ ការធ្វើទារុណកម្មជាទូទៅ ដែលគេរកឃើញក្នុងសេចក្តីសម្រេចសម្ងាត់បំផុត ចុះថ្ងៃទី៣០ មីនា ឆ្នាំ១៩៧៦ របស់បក្សកុម្មុយនីស្តកម្ពុជា។

ឯកសារនេះ ខ្ញុំបាទសូមបញ្ជាក់ថា ត្រូវបានលើកឡើងដោយសហមេធាវីរបស់ខ្ញុំបាទហើយ។

[១១:១៤:២៥]

នេះបានបញ្ជាក់ពីការមិនមានទទួលខុសត្រូវខ្ពស់បំផុតរបស់គាត់ ចំពោះបទឧក្រិដ្ឋដែលកើតឡើងនៅគុកស-២១។ សូមមេត្តាអានសាលក្រមលេខ០០១ កថាខណ្ឌលេខ៣៩៧ លេខ៣៩៨ លេខ៣៩៩។ វាជាការទទួលដឹងឮអំពីអង្គជំនុំជម្រះសាលាដំបូង អ.វ.ត.ក ពីការស្នើឲ្យពិនិត្យភស្តុតាងលើយុត្តាធិការបុគ្គល ហើយវាប្រាកដណាស់ដែរថា សាលាជំនុំជម្រះក្តី អ.វ.ត.ក មានភស្តុតាងគ្រប់គ្រាន់ថា ខ្លួនមិនមានយុត្តាធិការលើបុគ្គល កាំង អ៊ាវហ្គេក ហៅ ឌុច ទេ។ ប៉ុន្តែ ចៅក្រមខកខានមិនបានពិនិត្យហើយបន្តសវនាការរហូតដល់ទីបញ្ចប់នៃនីតិវិធី។

[១១:១៥:០០]

ជាលទ្ធផល មេធាវីការពារជនជាប់ចោទបានព្យាយាមលើកឡើងម្តងទៀតនៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួន ដើម្បីទាមទារឲ្យចៅក្រមពិនិត្យឡើងវិញភស្តុតាងដោះបន្ទុកដែលបញ្ជាក់ថា ជនជាប់ចោទមិនត្រូវបានចងភ្ជាប់នឹងមាត្រាមួយនៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា និងមាត្រា១ មាត្រា២ (ថ្មី) នៃច្បាប់ អ.វ.ត.ក ទេ។

[១១:១៥:២៧]

ជាលទ្ធផល ចៅក្រមខកខានម្តងទៀតក្នុងការពិនិត្យមើលភស្តុតាងដោះបន្ទុកតាមការស្នើសុំរបស់សហមេធាវីការពារជនជាប់ចោទ និងមតិរបស់ចៅក្រម ខាត់វ៉ាយថ៍។ ហើយថ្ងៃទី២៦ កក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូង អ.វ.ត.ក បានសម្រេចប្រកាសចេញសាលក្រមសំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ ផ្តន្ទាទោសឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាប្រធានស-២១ ហៅគុកសម្ងាត់យោធា ដែលគ្រប់គ្រងដោយក្រសួងការពារជាតិ និងមន្ទីរអគ្គសេនាធិការកងទ័ព ដែលមានឈ្មោះ សុន សេន ជាប្រធានឲ្យជាប់ពន្ធនាគាររួមកំណត់ ៣៥ឆ្នាំ។

យោងសេចក្តីជូនដំណឹងរបស់សហមេធាវីការពារឲ្យជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមចុះថ្ងៃទី២៦ កក្កដា ២០១០ របស់អង្គជំនុំជម្រះរបស់សាលាដំបូង

ដោយហេតុថា សាលក្រមរបស់ អ.ជ.ស.ដ ចុះថ្ងៃទី២៦ កក្កដា ២០១០ បានផ្តន្ទាទោសជនជាប់ចោទដែលមិនថិតនៅក្នុងយុត្តាធិការរបស់ខ្លួន ជាដើមហេតុនាំឲ្យសាលក្រមរបស់ អ.ជ.ស.ដ មានកំហុសឆ្គងផ្លូវច្បាប់។ ដូចនេះ សហមេធាវីការពារជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច សូមដាក់ជូននូវសេចក្តីថ្លែងហេតុដោយពឹងផ្អែកលើទឡ្ហីករណ៍ដូចតទៅ៖

[១១:១៦:៤៦]

ទឡ្ហីករណ៍ទី១៖ ការភ័ន្តច្រឡំអំពីយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងលើយុត្តាធិការបុគ្គល

អង្គជំនុំជម្រះសាលាដំបូង អ.វ.ត.ក បានប្រើប្រាស់ប្រព័ន្ធស្វ័យពង្រីកសិទ្ធិអំណាចរបស់ខ្លួនឲ្យចេញផុតពីយុត្តាធិការរបស់ខ្លួនតាមមាត្រា១ នៃកិច្ចព្រមព្រៀងរវាងនៃអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា និងមាត្រា១ និងមាត្រា២ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ក្នុងការជំនុំជម្រះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ដោយមិនពិនិត្យមើលភស្តុតាងដោះបន្ទុកដោយមានសារប្រយោជន៍ គឺសេចក្តីសម្រេចចិត្តរបស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ចុះថ្ងៃទី៣០ មីនា ១៩៧៦ ស្តីពីការសម្រេចឲ្យកម្ទេចក្នុងជួរនិងក្រៅជួរ។

[១១:១៧:២៩]

សេចក្តីសម្រេចនេះ ឌុច មិនស្ថិតនៅឋានានុក្រមនោះឡើយ។ ហើយប្រធានស-២១ បើតាមសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញការ ក្រេក អេតធេសាន់ ធ្វើការនៅការិយាល័យសហព្រះរាជអាជ្ញា គឺបានបញ្ជាក់ថា សុន សេន ជាអ្នកគ្រប់គ្រងផ្ទាល់។ បន្ទាប់មក មានខាងសេនាធិការមជ្ឈិមបក្សគឺប្រធាន ស-៧១ មានឈ្មោះ ឈឹម សំអោក ហៅ ប៉ង់ ជាប្រធានសន្តិសុខ និង លីន ហើយខាងក្រសួងការពារជាតិ មានបន្ទាយសេនាធិការកងទ័ពត្រួតពីលើថែមទៀតអំពីការងារចាប់ចងមកមន្ទីរស-២១ មានឈ្មោះ ស្វ៊ ម៉េត, រឿង ជាដើម បន្ទាប់ពីមានការសម្រេចចិត្តចេញពីមជ្ឈិមបក្ស ឬឃោធាមជ្ឈិម។

[១១:១៨:១១]

សាលាដំបូង អ.វ.ត.ក មិនបានពិនិត្យច្បាស់លាស់លើយុត្តាធិការបុគ្គលដូចដែលមានចែងនៅក្នុងមាត្រា១ រវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា និងមាត្រា១ និងមាត្រា២ថ្មី នៃច្បាប់ អ.វ.ត.ក ហើយផ្ទុយនឹងទំនៀមទម្លាប់អន្តរជាតិដូចការធ្លាប់អនុវត្តនៅ នូរឹមប៊ឺក និង តូក្យូ ដែលដាក់កំហិតលើសិទ្ធិអំណាចអង្គជំនុំជម្រះជារឿងសំខាន់។

នៅ នូរឹមប៊ឺក និង តូក្យូ អង្គជំនុំជម្រះមិនបានធ្វើការចោទប្រកាន់ ឬជំនុំជម្រះដល់បុគ្គលទាំង

ឡាយណាដែលជាទាហានសម្ព័ន្ធមិត្តនោះទេ។ ទោះបីជាគេបានដឹងឮជាទូទៅថា ក្រុមទាហានសម្ព័ន្ធមិត្តបានប្រព្រឹត្តឧក្រិដ្ឋកម្មដូចគ្នានឹងទៅនឹងពួកបក្សសម្ព័ន្ធយោធានៅអឺរ៉ុប និងឧក្រិដ្ឋជនសង្គ្រាមនៅអាស៊ីបូព៌ាយ៉ាងណាក៏ដោយ។ ព្រោះតែយុត្តាធិការលើសាលាជម្រះក្តីបានដាក់កំហិតលើសិទ្ធិអំណាចរបស់អង្គជំនុំជម្រះត្រឹមត្រូវតែលើបក្សឧបសម្ព័ន្ធយោធានៅអឺរ៉ុប និងឧក្រិដ្ឋជនសង្គ្រាមនៅអាស៊ីបូព៌ាតែប៉ុណ្ណោះ។ ហើយគ្មានអ្នកទទួលខុសត្រូវសាខាបក្សណាហ្ស៊ី ថ្នាក់មូលដ្ឋានណាម្នាក់ ត្រូវបានអង្គជំនុំជម្រះចោទប្រកាន់ ឬធ្វើការជំនុំជម្រះនោះទេ។ គឺមានតែមេបក្សណាហ្ស៊ី និងអ្នកទទួលខុសត្រូវជាន់ខ្ពស់បំផុតនៃរាល់បណ្តាឧត្តមសេនីយ៍យោធារបស់បក្សសម្ព័ន្ធយោធានៅអឺរ៉ុបប៉ុណ្ណោះដែលរងការចោទប្រកាន់ និងផ្តន្ទាទោស។

[១១:២៩:២៣]

អង្គជំនុំជម្រះក៏មិនធ្លាប់ ឬមិនអនុញ្ញាតឲ្យប្រើប្រាស់ប្រព័ន្ធស្វ័យពង្រីកអំណាច ដើម្បីពង្រីកនូវសិទ្ធិអំណាចរបស់ខ្លួន ដើម្បីធ្វើការចោទប្រកាន់លើក្រុមទាហានសម្ព័ន្ធមិត្តដែលប្រព្រឹត្តឧក្រិដ្ឋកម្មដូចគ្នានឹងបក្សម្ព័ន្ធយោធានៅអឺរ៉ុប និងក្រុមឧក្រិដ្ឋជនសង្គ្រាមយោធានៅអាស៊ីបូព៌ានោះទេ បើទោះបីជាគេឃើញថាឧក្រិដ្ឋកម្មបង្កើតឡើងដោយសម្ព័ន្ធមិត្តមានកម្រិតធ្ងន់ធ្ងរដូចគ្នា ឬក៏ធ្ងន់ជាងក៏ដោយ។ វាមានន័យថា អង្គជំនុំជម្រះត្រូវតែគោរពតាមច្បាប់ដែលកំណត់នូវសិទ្ធិនិងអំណាចរបស់ខ្លួន ដែលមានត្រឹមតែច្បាប់កំណត់តែប៉ុណ្ណោះ។ បើទោះបីជាអង្គជំនុំជម្រះយល់ឃើញថា អ្នកផ្សេងទៀតបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរដូចតែគ្នាក៏ដោយ។ នោះគឺមានន័យថាច្បាប់រឹងត្អឹង ប៉ុន្តែវាជាច្បាប់ *ដូឡូរ៉ាឡិច ស៊ិកឡិច* (ប្រកបតាមសំឡេងដើម) តាមជាភាសាឡាតាំង។

[១១:២០:០៨]

តែ អ.វ.ត.ក ធ្វើផ្ទុយពីនេះ ហើយធ្វើការចោទប្រកាន់ក្រុមមនុស្សដែលនៅក្រៅយុត្តាធិការរបស់ខ្លួន មិនបង្ហាញភស្តុតាងចងភ្ជាប់នឹងមាត្រា១ និងមាត្រា២ របស់ច្បាប់បង្កើត អ.វ.ត.ក ទេ។

សាលាដំបូង អ.វ.ត.ក បានប្រើប្រាស់ទំនៀមទម្លាប់អន្តរជាតិ ដោយប្រមើលមើលសេចក្តីសម្រេចចិត្ត អាយ.ស៊ី.ធី.វ៉ាយ និង អាយ.ស៊ី.ធី.អ័រ ដែលកំហិតយុត្តាធិការលើបទឧក្រិដ្ឋ តែមិនដាក់កំហិតលើឋានៈបុគ្គលទេ។ តាមមាត្រា៥ ដូចនៅ នូរឹមប៊ឹក និងតូក្យូ និង អ៊ុ.ស៊ី.ស៊ី.ស៊ី ទេ បានន័យថាលក្ខន្តិកៈនៃសាលាក្តីនៃ អាយ.ស៊ី.ធី.វ៉ាយ និង អាយ.ស៊ី.ធី.អ័រ មិនដូចគ្នានោះទេទៅនឹងសាលាជម្រះក្តី អ.វ.ត.ក នេះ។ ពីព្រោះថា វាខុសគ្នាត្រង់ការកំហិតលើយុត្តាធិការបុគ្គលនូវ អាយ.ស៊ី.ធី.វ៉ាយ

អាយ.ស៊ី.ធី.អ័រ, នូរឹមប៊ឺក និង តូក្យូ មិនដាក់កំហិតលើឋានៈបុគ្គលទេ។

[១១:២១:១៧]

តាមពិតទៅ អ.វ.ត.ក មានច្បាប់កំណត់យុត្តាធិការគ្រប់គ្រាន់ដោយមិនចាំបាច់ទាមទារឲ្យអង្គជំនុំជម្រះព្យាយាមប្រើប្រភពច្បាប់ផ្សេងទៀតមកបង្គ្រប់ទេ ហើយបើមានតម្រូវការមែននោះ ត្រូវតែស្របគ្នាទាំងស្រុងទៅនឹងរាល់ឧបករណ៍ច្បាប់ដែលមានស្រាប់នៅ អ.វ.ត.ក និងនៅក្នុងប្រព័ន្ធច្បាប់ដែលប្រើប្រាស់ដោយប្រទេសកម្ពុជា និងរាល់ឧបករណ៍ច្បាប់កម្ពុជាទាំងឡាយតាមមាត្រា១២(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា។

[១១:២១:៤៣]

ការប្រើប្រាស់ឧបករណ៍ច្បាប់អន្តរជាតិនានាមកបង្គ្រប់ឲ្យការបង្កើតច្បាប់ អ.វ.ត.ក លុះត្រាតែច្បាប់ប្រើប្រាស់នៅ អ.វ.ត.ក នៅខ្វះចន្លោះយ៉ាងជាក់លាក់ និងថាឧបករណ៍ច្បាប់អន្តរជាតិ ដែល អ.វ.ត.ក យកមកប្រើប្រាស់បន្ថែម ត្រូវតែស្របជាមួយនឹងប្រព័ន្ធច្បាប់ អ.វ.ត.ក ដែលប្រព័ន្ធច្បាប់ដែល អ.វ.ត.ក ឋិតនៅដែនអធិបតេយ្យនៅរដ្ឋមួយដែលប្រើប្រាស់ប្រព័ន្ធច្បាប់នោះ ព្រោះថា អ.វ.ត.ក មិនមែនជាសាលាជម្រះក្តីឯករាជ្យដូច អាយ.ស៊ី.ស៊ី នោះទេ។

[១១:២២:១៣]

តាមការចង្អុលបង្ហាញមាត្រា១២(១) នៃកិច្ចព្រមព្រៀងរវាងនៃអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។ ជាលទ្ធផល អ.វ.ត.ក ស្ថិតនៅក្នុងដែនអធិបតេយ្យភាពនៃរដ្ឋប្រើប្រាស់ប្រព័ន្ធស៊ីវិលឡ។ តាមព្រឹត្តិហេតុ ហើយទទួលយកយុត្តាធិការនៃរដ្ឋនោះផងដែរ។ ការយកមកប្រើប្រាស់នូវប្រព័ន្ធច្បាប់ខំមិនឡ របស់អង្គជំនុំជម្រះនៅ អ.វ.ត.ក គឺជាការបំផ្លាញចោលទាំងអស់នូវបទដ្ឋានច្បាប់សំខាន់ៗនៃច្បាប់ស៊ីវិលឡ ដែលកំពុងប្រើប្រាស់ដោយរដ្ឋដែល អ.វ.ត.ក ស្ថិតនៅក្នុងយុត្តាធិការនេះ និងបទដ្ឋានច្បាប់ដែលបង្កើតឡើងដោយអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាដែលទទួលយកយុត្តាធិការច្បាប់នេះ។

[១១:២២:៥៥]

សរុបសេចក្តីទៅ អ.វ.ត.ក ប្រើប្រាស់ប្រព័ន្ធច្បាប់ស៊ីវិលឡ យ៉ាងពេញលេញដោយឥតប្រកែកបានឡើយ។ ហេតុនេះគោលការណ៍ដែលថា គ្មានច្បាប់ គឺគ្មានបទល្មើសត្រូវតែគោរពតាម-- *ណូឡាកាំស៊ិងលីក* (ប្រកបតាមសំឡេងដើម) តាមន័យនេះ អង្គជំនុំជម្រះធ្វើផ្ទុយនឹងវិធានពីរនៃវិធានផ្ទៃក្នុងរបស់

អ.វ.ត.ក។ ការប្រើប្រាស់ប្រព័ន្ធស្វ័យពង្រីកអំណាចរបស់អង្គជំនុំជម្រះសាលាដំបូង អ.វ.ត.ក បាន ប្រឆាំងមាត្រា៥១ (ថ្មី) ជំពូក៤ នៃរដ្ឋធម្មនុញ្ញកម្ពុជាដែលកំណត់ថា អំណាចទាំងបីត្រូវចែកឲ្យដាច់ពីគ្នា ហើយអង្គជំនុំជម្រះមិនមានសិទ្ធិបង្កើត និងបកស្រាយច្បាប់នេះទេ។

[១១:២៣:៣៧]

ការប្រើប្រាស់នូវឧបករណ៍ច្បាប់អន្តរជាតិតាមទំនៀមទម្លាប់ គឺមិនត្រឹមត្រូវតាមអត្ថន័យនៃពាក្យថា ករណីយុត្តិសាស្ត្រ ព្រោះថាករណីយុត្តិសាស្ត្រទាមទារឲ្យពិនិត្យមើលឲ្យច្បាស់លាស់ ល្អិតល្អន់នូវនៃចរិតលក្ខណៈ និងបុព្វហេតុនៃការកកើតនៃបទឧក្រិដ្ឋ គឺវាដូចគ្នាខ្លាំងណាស់។ នេះជាជម្រើសមួយ។

និងជម្រើសទីពីរ គឺត្រូវពិនិត្យមើលប្រព័ន្ធច្បាប់ និងច្បាប់កំពុងមានអត្ថិភាព ថាតើវាមានលក្ខណៈដូចគ្នាទាំងស្រុងដែរឬទេ?

[១១:២៤:០៣]

ឯជម្រើសទីបី នោះគឺការកំណត់ថាច្បាប់មានចន្លោះប្រហោង គឺវាដូចគ្នាទៅនឹងសាលាជម្រះក្តីមុនដែលប្រព្រឹត្តចេញនូវសាលក្រមស្ថាពរមួយ ដែលស្របបំផុតតាមជម្រើសមួយ និងជម្រើសពីរខាងលើ។ តាមពិតទៅ ច្បាប់ អ.វ.ត.ក ដាក់កំហិតលើយុត្តាធិការបុគ្គល ផ្ទុយពីលក្ខន្តិកៈរបស់ អាយ.ស៊ី.ធី.វ៉ាយ, អាយ.ស៊ី.ធី.អ័រ, អាយ.ស៊ី.ធី.អេស, តូក្យូ និង នូរឹមប៊ឺក ដែលមិនកំណត់យុត្តាធិការលើឋានៈបុគ្គលនោះទេ។ នោះគឺសំអាងលើមាត្រា១ មាត្រា២ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

[១១:២៤:៤០]

ផ្ទុយទៅវិញ នៅអ.វ.ត.ក សាលាដំបូងមិនបានពិនិត្យមើលជម្រើសទាំងបីនេះទេ ដែលជាធម្មតាវាជាបង្រៀនយ៉ាងរត់មាត់ នៃសាលាបង្រៀនច្បាប់ប្រកបដោយស្តង់ដារនៃបណ្តារដ្ឋនានាលើពិភពលោក ក្នុងការកត់សម្គាល់ឲ្យឃើញថា ប្រព័ន្ធច្បាប់ស៊ីវិលឡូ និង ខំមិនឡូ មិនដូចគ្នាទេ។ ក្នុងការអនុញ្ញាតឲ្យចៅក្រមបកស្រាយច្បាប់តាមតែចំណេះដឹងច្បាប់ស៊ីវិលឡូ គ្រប់គ្នាសុទ្ធតែបង្រៀនឲ្យដឹងថា ចៅក្រមគ្មានសិទ្ធិអំណាចបង្កើតច្បាប់ដោយខ្លួនឯងឡើយ។ ហើយមិនអាចពង្រីកវិសាលភាពទៅតាមសទិសសភាពណាមួយបានឡើយ គឺការប្រើប្រាស់ករណីយុត្តិសាស្ត្រ។

[១១:២៥:១៦]

តាមមាត្រា៥ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ បានគាំទ្រអំណះអំណាងខាងលើនេះ ឬទទួលយកនូវការបង្រៀននៃសាលាច្បាប់ស៊ីវិលឡូ ដោយហាមប្រាមការប្រើប្រាស់តាមសទិសសភាពតាម

ករណីយុត្តិសាស្ត្រ ហើយតាមសទិសភាពនេះ វាកើតមានឡើងតែចំពោះតុលាការណាដែលទទួលយកយុត្តាធិការនៃប្រព័ន្ធច្បាប់ ខំមិនឡ តែប៉ុណ្ណោះ។

អ.វ.ត.ក ស្ថិតនៅក្រោមអធិបតេយ្យភាពនៃរដ្ឋដែលប្រើប្រាស់ប្រព័ន្ធច្បាប់ស៊ីវិលឡ ដែលបង្ហាញយ៉ាងច្បាស់តាមមាត្រា១២ មាត្រា១៣ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា និងមាត្រា៥ នៃក្រមព្រហ្មទណ្ឌកម្ពុជា។

[១១:២៦:00]

តាមកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា១២ អនុញ្ញាតឲ្យ អ.វ.ត.ក ប្រើប្រាស់ឲ្យអស់លទ្ធភាពនៃប្រភពច្បាប់នៃកម្ពុជា ហើយករណីប្រភពច្បាប់កម្ពុជាខ្វះខាតទើបអនុញ្ញាតឲ្យប្រើប្រាស់ប្រភពច្បាប់អន្តរជាតិ។ ដែលតាមន័យនេះគេមិនអាចប្រើប្រាស់ប្រព័ន្ធច្បាប់អន្តរជាតិណាមួយដែលប្រឆាំងនឹងច្បាប់កម្ពុជាបានទេ។ និយាយឲ្យចំគឺមិនអាចប្រើប្រាស់ ខំមិនឡ ដែលផ្ទុយនឹងប្រព័ន្ធច្បាប់ ស៊ីវិលឡ បានឡើយ។

ហេតុនេះ ការប្រើប្រាស់តាមសទិសភាព គឺការប្រើប្រាស់ករណីយុត្តិសាស្ត្រដ៏ច្រើនលើសលប់របស់ អ.វ.ត.ក គឺប្រឆាំងនឹងមាត្រា៥ នៃក្រមព្រហ្មទណ្ឌកម្ពុជា និងជាចំណុចទាញនៃការចាប់អារម្មណ៍របស់សាលាជម្រះក្តី អ.វ.ត.ក ដែលប្រើប្រាស់ប្រព័ន្ធស្វ័យពង្រីកអំណាចរបស់ខ្លួនតាមបែប ខំមិនឡ ដែលជាការកាត់ក្តីតាមទំនើងចិត្ត។

[១១:២៦:៥២]

ការកាត់ក្តីតាមទំនើងចិត្តនេះ យើងបានរកឃើញនូវការកាត់ក្តីតាមបែបជម្រើសមួយទៀត ដែលជ្រើសរើសជាភស្តុតាង ដែលត្រូវបានដាក់ជូនដោយសហមេធាវីការពារជនជាប់ចោទទៅដល់អង្គជំនុំជម្រះតុលាការកំពូល ហើយដែលលោកប្រធានតុលាការកំពូលបានប្រកាសថា បានទទួលស្គាល់នោះគឺឯកសារទទួលបានពី ឌី.ស៊ី.ខេម។ គឺឯកសារដែលចុះលេខ F14.2.4 ERN 00626210 ដែលមានចំណងជើងថា *សេឡិចសិ៍ធីវ៍ន បាយអ្វក្រាហ្វី ខិសខ្មែររ៉ូលីតដឺ អេន អាណាដឺ* (និយាយភាសាអង់គ្លេស) គឺមានសេចក្តីសន្និដ្ឋាននិងជ្រើសរើសហើយជាស្រេចនូវបុគ្គលទាំងឡាយត្រូវយកមកកាត់ក្តី។

[១១:២៧:៤៨]

ការអះអាងថា មាត្រា១ មាត្រា២ នៃច្បាប់ អ.វ.ត.ក មិនផ្តល់និយមន័យច្បាស់លាស់របស់សាលាដំបូង នោះគឺមិនត្រឹមត្រូវទេ ព្រោះតាមវិធាន៨៧ តាមវិធានផ្ទៃក្នុងនៃ អ.វ.ត.ក គឺតម្រូវឲ្យព្រះ

រាជអាជ្ញាពិនិត្យមើលភស្តុតាង និងប្រើឆន្ទានុសិទ្ធិប្រកបដោយវិជ្ជាជីវៈ និងមនសិការរបស់ខ្លួនក្នុងការកំណត់ការវាយតម្លៃពីភស្តុតាងចងជាប់បុគ្គលរូបណាមួយទៅនឹងមាត្រា១ មាត្រា២ នៃច្បាប់ អ.វ.ត.ក។ ហើយមាត្រា២៨ នៃក្រមព្រហ្មទណ្ឌកម្ពុជាបានកំណត់និយមន័យនៃអ្នកផ្ដើមគំនិត គឺត្រូវចាត់ទុកថា ជាអ្នកផ្ដើមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិមចំពោះបុគ្គលណា។

[១១:២៨:២១]

១) បានជំរុញឲ្យប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬមជ្ឈិម តាមការណែនាំ ឬបញ្ជា។

២) បង្កឲ្យមានបទឧក្រិដ្ឋ ឬមជ្ឈិមនោះដែលផ្ដល់អំណោយ ដោយសន្យា ឬការគំរាមកំហែងការញុះញង់ ការលួងលោម ឬដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន។

មាត្រានេះ គឺស៊ីគ្នាណាស់ទៅនឹងសេចក្ដីសម្រេចចិត្តចុះថ្ងៃទី៣០ មីនា ឆ្នាំ១៩៧១ របស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាដែលលើកឡើងដោយសហមេធាវី ដែលជាសហភាតារបស់ខ្ញុំបាទរួចហើយបាទ។ គឺកំណត់អំពីអ្នកណាចេញបញ្ជា ឬអ្នកផ្ដើមគំនិត។

ដូច្នេះ ការកំណត់និយមន័យអំពីអ្នកណាជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម គឺអត់លំបាកនឹងទៅរកយុត្តាធិការនៃសាលាជម្រះក្ដីផ្សេងទៀតមកប្រើទេ គឺវាចែងនៅក្រមព្រហ្មទណ្ឌកម្ពុជារួចរាល់អស់ទៅលើហើយ ដោយគ្រាន់តែលើកភស្តុតាងមកផ្គុំឲ្យមានលក្ខណៈជាប្រព័ន្ធ ហើយនិងពិនិត្យលើអង្គច្បាប់គឺគ្រប់គ្រាន់ណាស់ទៅហើយក្នុងការកំណត់។

[១១:២៩:២៦]

អ្នកផ្ដើមគំនិតនឹងត្រូវផ្ដន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង។ អ្នកផ្ដើមគំនិតអាចនឹងត្រូវផ្ដន្ទាទោសនឹងចារីដែរ។ ប៉ុន្តែ មាត្រា១ និងមាត្រា២ នៃច្បាប់ អ.វ.ត.ក ក៏ដូចជាចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះសារណាបណ្ដឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ។ សហព្រះរាជអាជ្ញាបានលើកឡើងថា គ្មានច្បាប់ណាចងភ្ជាប់កាតព្វកិច្ចខ្លួនឲ្យចោទប្រកាន់ទៅលើមន្ទីរឃុំឃាំងដ៏មានសក្តានុពលនានាដែលជាចារីនោះទេ។ ហេតុនេះហើយបានយើងទាញសេចក្ដីសន្និដ្ឋានបានថា ចារីមិនត្រូវបានស្ថិតនៅក្នុងយុត្តាធិការនៃសាលាជម្រះក្ដីនេះទេ។

[១១:៣០:១១]

តាមមាត្រា២៨ នៃក្រមព្រហ្មទណ្ឌកម្ពុជាបាននិយាយអំពីអ្នកផ្ដើមគំនិត គឺស៊ីគ្នាណាស់ គឺថាផ្ដន្ទាទោសតែទៅលើអ្នកផ្ដើមគំនិត។ បើយើងនិយាយពីមាត្រា២៨ ប្ដូកជាមួយមាត្រា១ មាត្រា២ នៃ

អ.វ.ត.ក យើងបានរកឃើញហើយថា អ្នកណាជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលកើតឡើងនៅគុកទួលស្លែង។ នោះគឺនិយមន័យដែលស្របតាមច្បាប់កម្ពុជា ហើយស្របតាមប្រព័ន្ធច្បាប់ស៊ីវិលឡផងដែរ។

ហេតុនេះជនទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មតាមមាត្រា១ និងមាត្រា២ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា គឺសំដៅលើអ្នកផ្តើមគំនិត អ្នកមានចេតនាផ្តួចផ្តើមគំនិតប្រព្រឹត្តបទល្មើស គឺជាអ្នកដាក់ចេញនូវបទបញ្ជាឲ្យប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា២៨ នៃក្រមព្រហ្មទណ្ឌកម្ពុជា និងវិធាន៨៧ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក គឺព្រះរាជអាជ្ញានិងអង្គជំនុំជម្រះសាលាដំបូង ត្រូវតែពិនិត្យមើលភស្តុតាងដែលដាក់ដោយគូភាគី និងជាពិសេសភស្តុតាងដែលរកបានដោយសហព្រះរាជអាជ្ញា និងសេចក្តីសម្រេចជាសម្ងាត់របស់បក្សកុម្មុយនីស្តកម្ពុជា ចុះថ្ងៃទី៣០ មីនា ១៩៧៦ ស្តីពីការកំណត់សិទ្ធិក្រុមមនុស្សដែលអាចផ្តើមគំនិតក្នុងការកម្ទេចក្នុងជួរ និងក្រៅជួរ ហើយបទបញ្ជានេះត្រូវបានអនុវត្តដោយចារីដែលជាប្រធានមន្ទីរសន្តិសុខទូទាំងប្រទេសជាង១៩៦។ គុកនេះនៅតិចណាស់បាទ។

[១១:៣១:៤៤]

បទឧក្រិដ្ឋកើតឡើងនៅក្នុងប្រទេសកម្ពុជាមានលក្ខណៈចម្លែកជាងគេ ទាំងសហព្រះរាជអាជ្ញា ទាំងសហចៅក្រមជនជាតិកម្ពុជា និងទាំងមេធាវីការពារជនជាប់ចោទ និងមេធាវីការពារ ដែលតំណាងឲ្យជនរងគ្រោះ សុទ្ធតែជាជនរងគ្រោះពីរបបនេះ ហើយនរណាៗក៏ដឹងដែរថា មន្ទីរឃុំឃាំងនៅទូទាំងប្រទេសកម្ពុជាមិនអាចត្រឹម១៩៦ ទេ។ គ្រាន់តែមន្ទីរឃុំឃាំងដែលឃុំឃាំងបងស្រីខ្ញុំ និងសម្លាប់គ្រួសារខ្ញុំនោះ គេអត់រាប់បញ្ចូលក្នុងនេះផង។ ដូច្នេះ ខ្ញុំសន្និដ្ឋានថា មន្ទីរឃុំឃាំងដ៏មានសក្តានុពលផ្សេងៗទៀតនោះ ប្រហែលជាមានលើសពី២០០ ក្នុងនោះមានមន្ទីរឃុំឃាំងរបស់មជ្ឈិមមួយទៀត ដែលសំខាន់ជាង ស-២១ មួយទៀត គឺ ស-៧១ នៅវត្តបុទុម ក៏អត់រាប់បញ្ចូលក្នុងបញ្ជីឈ្មោះនៃមន្ទីរឃុំឃាំងដែលដាក់ដោយ ឌី.ស៊ី.ខេម ដែរ។

[១១:៣២:៤៥]

ច្បាប់អន្តរជាតិក៏មិនអនុវត្តលើរូបវន្តបុគ្គលទេ គឺអនុវត្តតែទៅលើរដ្ឋ អង្គការអន្តរជាតិ និងក្រុមហ៊ុនពហុជាតិតែប៉ុណ្ណោះ។ ហេតុដូច្នេះ គឺមានតែសមាជិកជាន់ខ្ពស់ និងប្រមុខរដ្ឋាភិបាលប៉ុណ្ណោះ ដែលត្រូវដាក់ឲ្យទទួលខុសត្រូវក្រោមច្បាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ព្រោះជាក្រុមមនុស្សដែលតំណាង

ឲ្យរដ្ឋាភិបាល។ វាក៏ដូចគ្នាដែរថា បណ្តាមេដឹកនាំបក្សកាន់អំណាចជាន់ខ្ពស់ ដែលផ្តល់សេចក្តីសម្រេច គោលនយោបាយនាំដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី១២ សីហា ១៩៤៩ តែប៉ុណ្ណោះដែល--

**អ្នកបកប្រែ៖**

លោកចៅក្រមប្រធាន *ខោនស៊្វែល* សូមបន្ថយល្បឿនបន្តិចទាន។

**លោក កង ឫទ្ធារី៖**

ជាប់មាត់ទៅវាលឿនបន្តិច សូមអធ្យាស្រ័យដែរ។ អរគុណច្រើនចំពោះការរំឭករបស់លោក ព្រោះម៉ោងហ្នឹងខ្ញុំខ្លីពេក ហើយវាវែង របស់ខ្ញុំត្រូវថ្លែងនេះវាវែង។ បាទ អរគុណ។

[១១:៣៣:៣៦]

...តែប៉ុណ្ណោះ ដែលត្រូវបានចងភ្ជាប់ដោយមាត្រា១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា មាត្រា១ មាត្រា២ នៃច្បាប់ អ.វ.ត.ក មាត្រា២៤ មាត្រា២៨ នៃក្រមព្រហ្មទណ្ឌកម្ពុជា។ ឯលោក កាំង ហ្កេកអ៊ាវ ហៅឌុច គ្រាន់តែជាប្រធានឆ្មាំគុកម្នាក់ ក្នុងចំណោមប្រធានឆ្មាំគុកនៃមន្ទីរសន្តិសុខទាំង១៩៦ នៅទូទាំងប្រទេសកម្ពុជា គឺមិនត្រូវបានចងភ្ជាប់នឹងមាត្រា១ នៃកិច្ចព្រមព្រៀងនោះរវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា មាត្រា១ មាត្រា២ នៃច្បាប់ អ.វ.ត.ក ទេ។ ហេតុនេះ គឺមិនមែនមានន័យថា ចៅក្រមត្រូវតែធ្វើឲ្យប្រាកដថា ខ្លួនសម្រេចសេចក្តីត្រឹមត្រូវតាមតែការយកតម្រាប់តាមសាលាជម្រះក្តីមុនៗណាមួយនោះឡើយ។ គឺការប្រើប្រាស់ករណីយុត្តិសាស្ត្រ។

[១១:៣៤:២៧]

ម្យ៉ាងវិញទៀត ទាំងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា និងទាំងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក គ្មានមាត្រាណាមួយចងភ្ជាប់កាតព្វកិច្ចព្រះរាជអាជ្ញាឲ្យប្តឹង ហើយឲ្យអង្គជំនុំជម្រះទៀតសោត ក៏គ្មានកាតព្វកិច្ចផ្លូវច្បាប់ឲ្យជំនុំជម្រះចារីជាប្រធានសន្តិសុខទូទាំងប្រទេសដែលរួមបញ្ចូលទាំងប្រធានស-២១ ផងដែរនោះទេ។

ការប្រើប្រាស់ឧបករណ៍ច្បាប់អន្តរជាតិនានាមកបង្គ្រប់ឲ្យច្បាប់បង្កើត ស្តីពីការបង្កើត អ.វ.ត.ក លុះត្រាច្បាប់ប្រើប្រាស់នៅ អ.វ.ត.ក មានការខ្វះចន្លោះយ៉ាងជាក់លាក់ និងថាឧបករណ៍ច្បាប់អន្តរជាតិដែល អ.វ.ត.ក យកមកប្រើប្រាស់បន្ថែម ត្រូវតែស្របជាមួយនឹងប្រព័ន្ធច្បាប់ដែល អ.វ.ត.ក ស្ថិតនៅ

ក្នុងដែនអធិបតេយ្យនៃរដ្ឋដែលប្រើប្រាស់ប្រព័ន្ធច្បាប់នោះ។ ព្រោះថា អ.វ.ត.ក មិនមែនជាសាលាជម្រះក្តីឯករាជ្យដូច អាយ.ស៊ី.ស៊ី នោះទេ។ តាមការចង្អុលបង្ហាញមាត្រា១២(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា។

[១១:៣៥:២៨]

ជាលទ្ធផល អ.វ.ត.ក ស្ថិតនៅក្នុងដែនអធិបតេយ្យភាពនៃរដ្ឋប្រើប្រាស់ប្រព័ន្ធច្បាប់ស៊ីវិលឡ។ តាមព្រឹត្តិហេតុ ហើយទទួលយកដែនយុត្តាធិការនៃរដ្ឋនោះផងដែរ។ ការយកមកប្រើប្រាស់នូវប្រព័ន្ធខំមិនឡ របស់អង្គជំនុំជម្រះសាលាដំបូង គឺជាការបំផ្លាញចោលទាំងអស់នៃបទដ្ឋានច្បាប់សំខាន់ៗនៃប្រព័ន្ធច្បាប់ស៊ីវិលឡ ដែលកំពុងប្រើប្រាស់ដោយរដ្ឋដែល អ.វ.ត.ក ស្ថិតនៅក្នុងយុត្តាធិការ និងបទដ្ឋានច្បាប់ ដែលបង្កើតដោយអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដែលទទួលយកយុត្តាធិការនេះ។

[១១:៣៦:០២]

សរុបសេចក្តីទៅ អ.វ.ត.ក ប្រើប្រាស់ប្រព័ន្ធច្បាប់ស៊ីវិលឡ យ៉ាងពេញលេញ ដោយឥតប្រកែកបាន។ ហេតុនេះគោលការណ៍ដែលថា គ្មានច្បាប់ គឺគ្មានបទល្មើសត្រូវតែគោរព។ តាមន័យនេះ អង្គជំនុំជម្រះធ្វើផ្ទុយនឹងវិធាន២ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។

ការប្រើប្រាស់ប្រព័ន្ធសិទ្ធិស្វ័យពង្រីកអំណាចរបស់អង្គជំនុំជម្រះសាលាដំបូងបានប្រឆាំងមាត្រា៥១(ថ្មី) ជំពូក៤ នៃរដ្ឋធម្មនុញ្ញកម្ពុជា ដែលចែងអំពីការចែកអំណាច ហើយអង្គជំនុំជម្រះមិនមានសិទ្ធិបង្កើត និងបកស្រាយច្បាប់នោះទេ។ សិទ្ធិនៅក្នុងការបង្កើតច្បាប់នេះ មានតែស្ថាប័ននីតិបញ្ញត្តិតែមួយគត់ ហើយរាល់ការបកស្រាយច្បាប់ គឺជាភារកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

[១១:៣៦:៥៦]

ហេតុនេះការបកស្រាយថា មាត្រា១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ មាត្រា១ មាត្រា២ នៃច្បាប់ អ.វ.ត.ក ដោយសាលាដំបូងថា មិនច្បាស់លាស់ ហើយអង្គជំនុំជម្រះមានសិទ្ធិក្នុងការបកស្រាយ និងបង្កើតបញ្ញត្តិបន្ថែម ដោយប្រើប្រាស់ទំនៀមទម្លាប់អន្តរជាតិដែលកើតចេញពីសាលាជម្រះក្តី អាយ.ស៊ី.ធី.វ៉ាយ, អាយ.ស៊ី.ធី.អ័រ គឺមិនត្រឹមត្រូវទេ វាបានប្រឆាំងនឹងគោលការណ៍ជាសាកលនៃច្បាប់ ដែលកំណត់ថា គ្មានច្បាប់ គឺគ្មានបទល្មើស។

[១១:៣៧:៣៣]

តាមប្រព័ន្ធច្បាប់ស៊ីវិលឡ នោះមានន័យថា បើសិនជាលោក កាំង អ៊ាវហ្កេក ហៅ ឌុច មិនមែនជាជនដែលស្ថិតនៅក្នុងមាត្រា១ មាត្រា២(ថ្មី) នៃច្បាប់បង្កើត អ.វ.ត.ក ទេ គេគ្មានសិទ្ធិអ្វីនឹងយកច្បាប់ផ្សេងទៀតមកចោទប្រកាន់គាត់ដែរ។

ការប្រើប្រាស់ប្រព័ន្ធស្វ័យពង្រីក-- សិទ្ធិពង្រីកអំណាចរបស់អង្គជំនុំជម្រះសាលាដំបូង នាំឲ្យអន្តរាយដល់រាល់គោលជំហរយ៉ាងម៉ឺងម៉ាត់ នៃការបង្កើតសាលាជម្រះក្តី អ.វ.ត.ក តាមមាត្រា១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា និងមាត្រា១(២) នៃច្បាប់បង្កើត អ.វ.ត.ក ហើយវាក្លាយជាគំរូនៃកំហុសឆ្គងដ៏ធ្ងន់ធ្ងរក្នុងប្រព័ន្ធសាលាជម្រះក្តីទូទៅនៅកម្ពុជា និងអន្តរជាតិសម្រាប់បច្ចុប្បន្ននិងអនាគត។ ហើយបំពានគោលការណ៍ *បក្សកាសឹង សឺវិនដា* (ប្រកបតាមសំឡេងដើម) ដែលទទួលស្គាល់ដោយមាត្រា២៦ នៃអនុសញ្ញាក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា ហើយក៏មានចែងក្នុងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា។ គឺថា ការបកស្រាយមិនត្រូវស្ថិតនៅក្រៅពីអត្ថន័យនៃសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងដែលចុះហត្ថលេខារវាងរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិនោះទេ។

[១១:៣៨:៤៣]

នៅតូក្យូ ក៏ដូចនៅ នូរឹមប៊ឺក ដែរ សាលាជម្រះក្តីអន្តរជាតិទាំងពីរនេះហាមឃាត់ និងដាក់កំហិតយ៉ាងតឹងរ៉ឹង និងប្រកបដោយប្រសិទ្ធភាព មិនអនុញ្ញាតឲ្យអង្គជំនុំជម្រះប្រើប្រាស់ប្រព័ន្ធស្វ័យពង្រីកអំណាចរបស់ខ្លួនជាដាច់ខាត។ ជាលទ្ធផល គេបានឃើញថា តុលាការនេះបានអនុវត្តយ៉ាងម៉ឺងម៉ាត់ចំពោះការមិនអនុញ្ញាតឲ្យចៅក្រមធ្វើការពង្រីកអំណាចទៅចាប់យកកងទ័ពសម្ព័ន្ធមិត្តមកកាត់ទោសទេ។ ទោះបីជាមានការទម្លាក់គ្រាប់បែកនៅទីក្រុងណាហ្គាសាគី និងហ៊ីរ៉ូស៊ីម៉ា ដែលសម្លាប់ជនស៊ីវិលស្លូតត្រង់ជប៉ុនអស់រាប់សែន រាប់លាននាក់ក៏ដោយ។

[១១:៣៩:៣១]

យុត្តាធិការនៃបទឧក្រិដ្ឋនៅ អាយ.ស៊ី.ធី.វ៉ាយ និង អាយ.ស៊ី.ធី.អ័រ មិនដូចគ្នានឹងយុត្តាធិការបទឧក្រិដ្ឋនៅ អ.វ.ត.ក ទេ។ ដ្បិតយុត្តាធិការ អាយ.ស៊ី.ធី.វ៉ាយ និង អាយ.ស៊ី.ធី.អ័រ គ្របដណ្តប់ទាំងស្រុងលើបទឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយមិនដាក់កំហិតលើយុត្តាធិការឋានៈបុគ្គលទេ ព្រោះបទឧក្រិដ្ឋនៅទីនោះ ក៏កើតចេញពីការរើស

អើងជាតិសាសន៍ សាសនា និងចលនាបំបែករដ្ឋ។ ឯនៅក្នុងប្រទេសកម្ពុជាមូលហេតុនៃការកកើតបទឧក្រិដ្ឋ គឺកើតចេញពីមនោគមវិជ្ជានយោបាយ។

[១១:៤០:១០]

តែនៅ អ.វ.ត.ក បានដាក់កំហិតលើឋានៈបុគ្គលយ៉ាងច្បាស់ ហើយឧក្រិដ្ឋកម្មកើតឡើង គឺដោយមូលហេតុនយោបាយសុទ្ធសាធ ដែលជាដើមហេតុធ្វើឲ្យច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក បានដាក់កំហិតនូវក្រុមមេដឹកនាំជាន់ខ្ពស់ និងអ្នកទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម។

ហេតុនេះ ការប្រើប្រាស់ឧបករណ៍ច្បាប់អន្តរជាតិ មកពីទំនៀមទម្លាប់អន្តរជាតិ គឺផ្ទុយពីច្បាប់ដែលបង្កើតឡើងដោយសាលាដំបូង អ.វ.ត.ក។

[១១:៤០:៤១]

ទឡ្ហីករណ៍ទី២៖ ចំពោះការភ័ន្តច្រឡំក្នុងការផ្ដន្ទាទោស។

តាមកថាខណ្ឌ៣០, ៣១ បាននៃសាលក្រមបានលើកឡើងថា តាមព្រឹត្តន័យគោលការណ៍ជាទូទៅនៃច្បាប់ *គុយជុ ខូជិន* ដែលតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ បានហាមប្រាមមិនឲ្យរំលោភបំពានបាន។ បានន័យថា យើងទទួលស្គាល់លើបទឧក្រិដ្ឋដែលបានចែងនៅ អ.វ.ត.ក គឺជាបទឧក្រិដ្ឋដែលបានដកចេញនូវបុព្វសិទ្ធិ អភ័យឯកសិទ្ធិទាំងឡាយ សម្រាប់ជនទាំងឡាយដែលបានប្រព្រឹត្តវា។ ប៉ុន្តែ អ.វ.ត.ក បានដាក់កំហិត ផ្ទុយទៅវិញ អ.វ.ត.ក មានដាក់កំហិតទៅលើទៅលើឋានៈបុគ្គលដូចដែលបានពន្យល់រួចហើយ។

[១១:៤១:៣១]

ផ្ទុយទៅវិញ តាមពាក្យប្រារព្ធនៃនៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា គឺមហាសន្និបាតអង្គការសហប្រជាជាតិបានរំឭកនៅក្នុងសេចក្ដីសម្រេចចិត្តរបស់ខ្លួនលេខ ៥៧-២២៨ ចុះថ្ងៃទី១៨ ធ្នូ ២០០២ ថាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរចំពោះច្បាប់កម្ពុជា និងច្បាប់មនុស្សធម៌អន្តរជាតិក្នុងរយៈពេលកម្ពុជាប្រជាធិបតេយ្យ ៧៥ ដល់ ៧៩ នៅតែជាបញ្ហាបង្កឲ្យមានការព្រួយបារម្ភយ៉ាងធ្ងន់ធ្ងរដល់សហគមន៍អន្តរជាតិទាំងមូល។

[១១:៤១:៥៦]

ដោយហេតុថា នៅក្នុងសេចក្ដីសម្រេចចិត្តដដែលនេះ មហាសន្និបាតបានទទួលស្គាល់ការព្រួយបារម្ភពេញច្បាប់របស់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការស្វែងរកយុត្តិធម៌ និងការបង្រួបបង្រួម

ជាតិ ស្ថិរភាព សន្តិភាព និងសន្តិសុខ និងដោយហេតុថា អាជ្ញាធរកម្ពុជាបានស្នើសុំជំនួយពីអង្គការសហប្រជាជាតិ ដើម្បីកាត់ក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌកម្ពុជា។

ការរំលោភលើច្បាប់មនុស្សធម៌ និងទំនៀមទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយប្រព្រឹត្តក្នុងអំឡុងពេល ១៧ មេសា ៧៥ ដល់ ៦ មករា ៧៩ ពាក្យប្រារព្ធនេះបានបង្ហាញច្បាស់ថា ការកំណត់ជនជាប់ចោទត្រឹមតែមនុស្សពីរក្រុមតែប៉ុណ្ណោះ បើទោះបីតាមគោលការណ៍ជាសាកល គឺបុគ្គលគ្រប់រូបឲ្យតែបំពានបទឧក្រិដ្ឋតាមពាក្យប្រារព្ធខាងលើត្រូវតែទទួលទោស។

[១១:៤២:៥៤]

ដោយហេតុនេះអង្គការសហប្រជាជាតិមានតួនាទីត្រឹមតែជួយកម្ពុជាប៉ុណ្ណោះ ហើយការកាត់ក្តីត្រូវតែស្របតាមច្បាប់កម្ពុជា និងតាមទំនៀមទម្លាប់អន្តរជាតិ អត់សំដៅលើការប្រើប្រាស់ប្រព័ន្ធខំមិនឡូឡើយ។ ដូចដែលមានចែងនៅក្នុងមាត្រា៣១ នៃកិច្ចព្រមព្រៀងរបស់អង្គការសហប្រជាជាតិដែលប្រកាសថា សាលាជម្រះក្តីនេះប្រើប្រាស់ច្បាប់ដូចទៅនឹងច្បាប់កម្ពុជា។

តាមគោលការណ៍ស៊ីវិលឡូដែលថា គ្មានច្បាប់ គឺគ្មានបទឧក្រិដ្ឋ គឺតែងតែប្រកាន់យកតាមអត្ថបទច្បាប់ជាធរមានទាំងជាតិ និងអន្តរជាតិ។ បើច្បាប់បង្កើត អ.វ.ត.ក បង្គាប់ឲ្យកាត់ទោសតែទៅលើបុគ្គលពីរក្រុមដូចពោលខាងលើនេះ គេគ្មានសិទ្ធិស្វះស្វែងរកសេចក្តីសម្រេចចិត្តរបស់ចៅក្រមផ្សេងៗពីសាលាក្តីដទៃទៀតមកបង្គ្រប់ ដើម្បីកំណត់និយមន័យទាញយកបុគ្គលក្រៅយុត្តាធិការរបស់ខ្លួនមកកាត់ទោសនោះទេ។

សុំទោស ដោយសារពេលវេលាខ្លី ខ្ញុំសូមបង្រួញឲ្យលឿនបន្តិច សូមអ្នកបកប្រែអធ្យាស្រ័យ។

[១១:៤៥:៥១]

នៅក្នុងសេចក្តីផ្តើមរបស់ខ្លួនសាលក្រមសំណុំរឿង០០១ អ.ត.វ.ក មិនបានបង្ហាញពីនីត្យានុកូលភាពនៃភស្តុតាង ដែលត្រូវទាញចេញពីអត្ថបទច្បាប់ អ.វ.ត.ក ឬក្រមព្រហ្មទណ្ឌកម្ពុជាដូចជាមាត្រា៤ មាត្រា៥, ២៤, ២៥, ២៦, ២៨, ៣២, ៣៥, ៣៦ និង ៤៦ នោះទេ។ ផ្ទុយទៅវិញ សាលក្រមនេះសម្បូរបែបដោយករណីយុត្តាសាស្ត្រ ដែលបង្កើតឡើងដោយសេចក្តីសម្រេចនៃសាលាជម្រះក្តី អាយ.ស៊ី.ធី.វ៉ាយ, អាយ.ស៊ី.ធី.អ័រ, អាយ.ស៊ី.ធី.អេស, តូក្យូ, នូរឹមប៊ឺក ទៅវិញ។

ការកាត់ក្តីបែបនេះមិនមែនកំណត់សិទ្ធិត្រឹមជួយពីអន្តរជាតិប៉ុណ្ណោះទេ តែជាការពង្រីកតាមសទិសភាព គឺការពង្រីកអំណាចរបស់សាលាជម្រះក្តី ដោយប្រើទស្សីករណ៍ជាករណីយុត្តិសាស្ត្រ នោះគឺជាតុលាការដែលទទួលយកប្រព័ន្ធខំមិនឡូ ទាំងស្រុងតែម្តង ដែលផ្ទុយពីប្រព័ន្ធច្បាប់ស៊ីវិលឡូដែលកម្ពុជាទទួលយកមកប្រើប្រាស់ទាំងស្រុង និងជាយូរមកហើយ។

[១១:៤៥:00]

អំពីភស្តុតាងដោះបន្ទុកដែលមិនទាន់យកមកបង្ហាញដោយអង្គជំនុំជម្រះ។

ទីមួយ របាយការណ៍ដែលផ្តល់ដោយអ្នកជំនាញការ ក្រេក អេតឆេសាន់ អ្នកស៊ើបអង្កេតនៃការិយាល័យសហព្រះរាជអាជ្ញា។ ទោះបីភស្តុតាងត្រូវបានគេចុះបញ្ជីនៅក្នុងសំណុំរឿងក៏ដោយ ក៏ភស្តុតាងនោះមិនត្រូវបានលើកមកជជែកដេញដោលនៅឯអង្គជំនុំជម្រះសាលាដំបូងឡើយ។

ទីពីរ គឺបញ្ហាអំពី-- ឯកសារទីពីរ គឺឯកសារ F14.2.4 ERN 00626210 ដែលដាក់ជូនទៅគណៈកម្មការជំនាញការរបស់អង្គការសហប្រជាជាតិក្នុងឆ្នាំ១៩៩៨ ដោយអ្នកចងក្រងឯកសារឌី.ស៊ី.ខេម ដែលបានសន្និដ្ឋានថា លោក កាំង អ៊ាវហ្កេក ហៅ ឌុច គឺជាប្រធានសន្តិបាល គឺបានន័យថា ជាប្រធានឆ្មាំគុក មិនមែនជាប្រធានស-២១ ទេ ហើយអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតនៃស-២១ គឺសុន សេន និង ប៉ុល ពត។

[១១:៤៦:០៧]

តាមប្រតិចារឹក និងតាមសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញការ-- តាមប្រតិចារឹកដែលបានពីបទសម្ភាសរវាង កាំង អ៊ាវហ្កេក ហៅ ឌុច ជាមួយនឹងសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងតាមរយៈរបាយការណ៍របស់ ក្រេក អេតឆេសាន់ ក៏បានបង្ហាញថា មានវត្តមាន នួន ជា ផងដែរ ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតលើ ស-២១។ ហើយលោក កាំង អ៊ាវហ្កេក ហៅ ឌុច ក៏ធ្លាប់បានសម្ភាសជាមួយនិងខ្ញុំ ហើយបានបញ្ជាក់ថា នួន ជា ធ្លាប់ប្រកាសប្រាប់គាត់ថា “ប្រធានស-២១ ពិតប្រាកដ គឺគាត់មិនមែន ឌុច ឯងទេ” ពីព្រោះតែលោក កាំង អ៊ាវហ្កេក ហៅ ឌុច បានធ្វើការបដិសេធបញ្ជារបស់ នួន ជា ក្នុងការបន្តការសួរចម្លើយជនជាប់ចោទ-- អ្នកទោសនៅស-២១ បន្តទៀត ដោយសំអាងទៅលើការប្រជុំ និងប្រកាសជាសាកល ជាទូទៅរបស់ ប៉ុល ពត ថាឲ្យឈប់សួរដេញដោលតទៅទៀត។ ហេតុនេះ នួន ជា បានប្រកាសខ្លួនថា “ឌុច ឯងមិនមែនជាប្រធាននៃស-២១ ទេ គឺខ្ញុំ”។

ហេតុការណ៍នេះ វាកើតឡើង ក្រោយពី សុន សេន ត្រូវបានគេផ្លាស់ទៅសមរភូមិមុខ ហើយ

នួន ជា ត្រូវបានជំនួសឡើងវិញ ដោយ សុន សេន-- (អឺ! សូមទោស) សុន សេន ត្រូវបានបញ្ជូនទៅសមរភូមិមុខ ហើយជំនួសវិញ ដោយ នួន ជា។ ហើយ នួន ជា បានពោលអះអាងយ៉ាងច្បាស់ក្រឡែតអំពីបញ្ហានេះ។

[១១:៤៧:២៧]

នៅទីចុងបញ្ចប់ ខ្ញុំសូមធ្វើសេចក្តីសន្និដ្ឋានថា សាលក្រមរបស់សាលាដំបូង អ.វ.ត.ក គឺជាកាត់ក្តីខុស ការកាត់ក្តីយល់ច្រឡំ គឺកាត់ក្តីទៅលើសាក្សីដែលមានសក្តានុពលរបស់សាលាជម្រះក្តីនេះទៅវិញ។ ដោយមូលហេតុនៃការកាត់ក្តីច្រឡំនេះ គឺដោយសារមិនបានពិនិត្យមើលលើភស្តុតាងដោះបន្ទុក ហើយយើងមានភស្តុតាងមួយទៀត ដែលថាភស្តុតាងដោះបន្ទុកមិនត្រូវបានគេលើកយកមកបង្ហាញនៅទីនេះទេ។ មូលហេតុគឺថា តាមរបាយការណ៍របស់ ប៉ាស្ទីន ជាមន្ត្រីនគរបាលយុត្តិធម៌នៃ អ.វ.ត.ក បានប្រកាសថា លោកចៅក្រមស៊ើបអង្កេត ម៉ាកសែល ឡឺមុងដ៍ និងអ្នកស្រី អូសស្ទីន បានបង្គាប់គាត់មិនឲ្យដាក់ភស្តុតាងដាក់បន្ទុក-- ដោះបន្ទុក មិនឲ្យដាក់ភស្តុតាងដោះបន្ទុកមកសាលាជម្រះក្តីនេះទេ។ នេះគឺជាអំពើឆ្គួតលីលាមួយ ហើយវាត្រូវបានប្រឆាំងទៅនឹងនីតិវិធីត្រឹមត្រូវ ដែលត្រូវថា សហចៅក្រមស៊ើបអង្កេតត្រូវតែពិនិត្យ ត្រូវតែស្រាវជ្រាវ ហើយនឹងដាក់ជូនអង្គជំនុំជម្រះ ទាំងភស្តុតាងដោះបន្ទុក និងភស្តុតាងដាក់បន្ទុក។ នេះជាដើមហេតុដែលធ្វើឲ្យកូនក្តីខ្ញុំ មិនអាចទទួលបាននូវយុត្តិធម៌ពិតប្រាកដ។

ហើយសំណូមពររបស់ខ្ញុំ គឺស្របទៅនឹងសហភាតារបស់ខ្ញុំទីមួយដែរ។ សូមបញ្ចប់ត្រឹមប៉ុណ្ណេះ។

[១១:៤៨:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ, ជាបន្តសូមអញ្ជើញលោកចៅក្រមរបាយការណ៍ បើមានសំណួរសូមអញ្ជើញសួរ។

សូមអញ្ជើញៗ លោកចៅក្រម។

**ចៅក្រម ចាន់ដ្រា ចាយ៉ាស៊ីញហ៍៖**

លោក ការ សាវុត្ថ! លោកមេធាវីការពារក្តី ការ សាវុត្ថ ខ្ញុំសូមចង់ចោទសួរទៅកាន់លោក។ ទឡ្ហីករណ៍ចម្បងរបស់លោក គឺថាយុត្តាធិការរបស់ អ.វ.ត.ក គឺកម្រិតតែលើមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនៃរបបនេះ។ នេះជាទឡ្ហីករណ៍ចម្បងរបស់លោក។ ថាតើលោកមានមូលដ្ឋានផ្លូវច្បាប់ណាយកមកសំអាងថា មេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះ គឺជាក្រុមប្រភេទរួមគ្នាតែម្តង។ ដូច្នេះ ថាតើលោកមានមូលដ្ឋានផ្លូវ

ច្បាប់យ៉ាងណាខ្លះទៅលើចំណុចនេះ? ដូច្នេះ សូមឲ្យលោកជម្រាបមកយើងខ្ញុំអំពីមូលដ្ឋានផ្លូវច្បាប់ដែលលោកលើកឡើងអំពីយុត្តាធិការរបស់តុលាការនេះ។ សូមអរគុណ។

**លោក ការ សាវុត្ថៈ**

សូមគោរពឯកឧត្តមប្រធាន និងសូមគោរពលោកចៅក្រមជាតិ និងអន្តរជាតិ និងសូមគោរពអង្គសវនាការទាំងមូល។

ចំពោះសាលាជម្រះក្តីយើងនេះ ច្បាប់មាត្រា១ តម្រូវឲ្យកាត់ទោសតែមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម។ ដោយសារខ្ញុំមានឯកសារសំអាង ដែលខ្ញុំបាទលើកជូនតុលាការអម្បាញ់មិញនេះ។ ឯកសារនេះចេញពីមជ្ឈិមបក្សកុម្មុយនីស្ត ប៉ុល ពត ដែលអចិន្ត្រៃយ៍មជ្ឈិមបក្សជាអ្នកសម្រេច។ អ៊ីចឹង អចិន្ត្រៃយ៍មជ្ឈិមបក្សជាអ្នកសម្រេចថា មេដឹកនាំជាន់ខ្ពស់ គឺនៅក្នុងឯកសារនេះហើយ។ អ៊ីចឹង មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ គឺអចិន្ត្រៃយ៍មជ្ឈិមបក្សដែលមានចំនួនប្រាំពីររូប ដល់ឆ្នាំ៧៧ ថែមបីរូបទៀត គឺខ្ញុំបាទសរសេរជូនក្នុងសារណា-- ឈ្មោះនោះសរសេរជូនក្នុងសារណារបស់ខ្ញុំបាទអស់ហើយ។ នេះជាចំណុចទីមួយ។

[១១:៥២:១០]

ទីពីរ យើងឃើញថា ធម្មតារបបកុម្មុយនីស្ត គេថាបក្សដឹកនាំ រដ្ឋគ្រប់គ្រង ប្រជាជនជាម្ចាស់។ បក្សដឹកនាំឲ្យធ្វើអី យើងត្រូវតែធ្វើហ្នឹង។ បក្សដឹកនាំឲ្យធ្វើ បើយើងមិនធ្វើតាមបក្ស យើងកំបុតក។

អ៊ីចឹងឥឡូវនេះ យើងឃើញហើយបក្សដឹកនាំអចិន្ត្រៃយ៍មជ្ឈិមបក្សហ្នឹង ដឹកនាំឲ្យយ៉ាងម៉េច? ដឹកនាំឲ្យកាប់សម្លាប់ មានសិទ្ធិសម្រេចកម្ទេច គឺមានសិទ្ធិសម្លាប់ក្នុងជួរ និងក្រៅជួរ។ នេះច្បាស់ថែសមានសិទ្ធិកម្ទេចក្នុងជួរ និងក្រៅជួរ។ អ៊ីចឹង បក្សអចិន្ត្រៃយ៍មជ្ឈិមបក្សចាត់តាំងឲ្យមនុស្សបួនក្រុម ដូចខ្ញុំបានជម្រាបអម្បាញ់មិញអ៊ីចឹង។ ក្រុមទីមួយ គឺក្របខ័ណ្ឌមូលដ្ឋាន ត្រូវអចិន្ត្រៃយ៍ អចិន្ត្រៃយ៍ភាគសម្រេច។ អចិន្ត្រៃយ៍ភាគក្នុងស្រុកខ្មែរយើងមានប្រាំពីរភូមិភាគ។ អ៊ីចឹង លេខាភូមិភាគទាំងប្រាំពីរ គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម។ អ៊ីចឹង មានឈ្មោះអស់ហើយ លេខាភូមិភាគទាំងប្រាំពីរខ្ញុំដាក់ជូនទៅក្នុងសារណារបស់ខ្ញុំរួចហើយ។

[១១:៥៣:០៧]

ហើយក្រុមទីពីរ គឺមន្ទីរជុំវិញមជ្ឈិម ត្រូវគណៈមន្ទីរមជ្ឈិមសម្រេច។ គណៈមន្ទីរមជ្ឈិម គឺមន្ទីរ៨៧០។ អ៊ីចឹង លេខាមន្ទីរ៨៧០ ក៏ខ្ញុំបានដាក់ជូនហើយឈ្មោះអ្នកណា? រួចមកដល់តំបន់ឯករាជ្យ ត្រូវ

អចិន្ត្រៃយ៍សម្រេច--

**ប្រធានអង្គជំនុំ៖**

លោកមេធាវី គឺឯកសារហ្នឹងយើងមានហើយ ហើយនៅក្នុងសារណាមានហើយ។ ប៉ុន្តែ សំខាន់គឺសំណួររបស់លោកចៅក្រមគាត់ចង់ផ្តោតទៅលើចំណុចមួយដែលថា អ្នកដែលទទួលខុសត្រូវខ្ពស់បំផុតហ្នឹង ជាមួយនិងមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យហ្នឹង។ ទីមួយ តើអាចថា តើជាបុគ្គលត្រូវទាំងពីរនេះចងភ្ជាប់គ្នា ឬមួយ ហើយមានច្បាប់ផ្សេងទៀតមកបញ្ជាក់ទេ? អំមិញគឺលោកបានលើកហើយថា មានគឺមាត្រា១ នៃច្បាប់ អ.វ.ត.ក ប៉ុន្តែនៅក្នុងមាត្រា១ នេះ គឺគេបានចែងហើយ ហើយប៉ុន្តែវាមានច្បាប់ឯណាទៀតដែលមានទាក់ទងនឹងបញ្ហាហ្នឹងទេ? សូមអញ្ជើញលើកឡើងខ្លីៗទៅ កុំបាច់លើកវែងពេកទេ ពីព្រោះលោកបានបង្ហាញរួចអស់ហើយ។

[១១:៥៤:០៦]

**លោក ការ សាវុត្ថ៖**

ខ្ញុំបាទលើកជម្រាបជូនរួចហើយ ប្រហែលជាលោកចៅក្រមស្តាប់មិនទាន់។ គឺវិធាន១១ ស្ទួន។ វិធាន១១ ស្ទួន យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិយូហ្គោស្លាវី គេបានបកស្រាយថាមេដឹកនាំជាន់ខ្ពស់បំផុតនោះសំដៅទៅបុគ្គលទាំងឡាយ ដែលដោយសារមុខងារតំណែង ឋានានុក្រមរដ្ឋបាល ពោលគឺតាមផ្លូវច្បាប់ និងតាមព្រឹត្តិហេតុជាក់ស្តែង ត្រូវបានចោទថាឋិតក្នុងកម្រិតអំណាចដែលសមស្រប ចាត់ទុកជាអ្នកដឹកនាំខ្ពស់បំផុត នេះមិនមែនថ្នាក់កណ្តាលទេ។ នេះគឺខ្ញុំបាទសូមជម្រាបទៅតាមមាត្រា១១ ស្ទួន នៃយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ។

**ចៅក្រម ចាន់ដ្រា ចាយ៉ាស៊ីញហ៍៖**

មេធាវី លោកបានសង្កេតហើយថា នៅក្នុងឃ្លោងឃ្លាបទប្បញ្ញត្តិនោះមានប្រើពាក្យថា “និង” មេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត។ ដូច្នេះ ខ្ញុំចង់សួរថា ពាក្យថា “និង”នោះ ថាតើយើងគួរតែភ្ជាប់បុគ្គលពីរហ្នឹងរួមគ្នាតែម្តង ឬក៏យើងបែងចែកដាច់ពីគ្នាចំពោះមូលដ្ឋានផ្លូវច្បាប់ ដែលយើងយកមកយោងទៅលើពាក្យថា “និង” នោះ?

[១១:៥៥:៤០]

**លោក កង ឫទ្ធារី៖**

ដោយហេតុថាជាសហមេធាវី ខ្ញុំសូមឆ្លើយជំនួសថា ពាក្យថា ឃ្លោងឃ្លានេះ គឺត្រឹមត្រូវណាស់

គឺ "និង"។ ដូច្នេះ អ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ក៏ជាអ្នកទទួល-- ក៏ជាក្រុមមេដឹកនាំជាន់ខ្ពស់របស់របបកម្ពុជាប្រជាធិបតេយ្យដែរ ពីព្រោះគេពិនិត្យទៅលើស្ថានភាពផ្លូវចិត្ត *មែនវា* ពីព្រោះថា បើសិនជាយើងមិនពិនិត្យមើលស្ថានភាពផ្លូវចិត្ត បានន័យថា ការសម្រេចចិត្តនយោបាយ គឺអ្នកណាដែលមានឋានៈខ្ពស់ជាងគេ ទើបមានការសម្រេចចិត្តបាន ដាក់ឲ្យឧក្រិដ្ឋកម្មមួយប្រព្រឹត្តទៅដោយរលូន ឬអាចបញ្ឈប់វាបាន។ អ៊ីចឹង បើសិនជាគាត់ថ្នាក់ទាប គាត់ចេញសេចក្តីសម្លាប់មនុស្សអត់បានទេ បើចេញសេចក្តីសម្រេចចិត្តសម្លាប់មនុស្ស មានមេដឹកនាំថ្នាក់ខ្ពស់ទៀតនឹងបញ្ឈប់គាត់បាន។

[១១:៥៦:៣០]

ហេតុនេះ អត្ថបទច្បាប់របស់អង្គការសហប្រជាជាតិ ឬក៏អត្ថបទនៃ អ.វ.ត.ក បានបង្ហាញពាក្យថា "និង" ក្រុមមេដឹកនាំជាន់ខ្ពស់ និងពួកអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្ម។ ហេតុនេះ ត្រូវតែទាញចេញពួកអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្ម ត្រូវតែទាញចេញអំពីក្រុមមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យផងដែរ។ បាទ, អរគុណ។

**ចៅក្រម ចាន់ជ្រា ចាយ៉ាស៊ីញហ៍៖**

សូមលើកឡើងម្តងទៀត ថាចំណុចចុងក្រោយលោកលើកឡើងអម្បាញ់មិញនោះ គឺយ៉ាងម៉េច? សូមឲ្យលោកលើកឡើងម្តងទៀតនូវការលើកឡើងចុងក្រោយអម្បាញ់មិញ?

**លោក កង ឫទ្ធារី៖**

បាទ, បានន័យថា បើប្រើពាក្យថា "និង" គឺនៅតាមកិច្ចព្រមព្រៀង-- មាត្រា១ នៃកិច្ចព្រមព្រៀងរបស់អង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា និងមាត្រា១(២) នៃច្បាប់ អ.វ.ត.ក ដែលចែងថា "ក្រុមមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្ម" ពាក្យភាសានេះ បានន័យថាចងភ្ជាប់គ្នា។ អ្នកទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្ម បានន័យថាត្រូវតែជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យផងដែរ បើមិនដូច្នោះទេ គេមិនចាត់ទុកថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្មឡើយ។

តើបានទេលោក?

**ប្រធានអង្គជំនុំ៖**

បាទ, សូមអរគុណ។ ហើយឥឡូវនេះដល់ពេលសម្រាកហើយ សូមតុលាការប្រកាសសម្រាក ហើយសូមចូលវិញនៅវេលាម៉ោងដប់បីកន្លះ។

**លោក កង ឫទ្ធារី៖**

សូមលោកប្រធានអនុញ្ញាតឲ្យកូនក្តីខ្ញុំបាទ ទៅទទួលទានបាយផងបាទ។ គាត់ថាបើអត់មានបញ្ជាពីតុលាការ គាត់អត់អាចទៅបានទេ។

**ប្រធានអង្គជំនុំ៖**

បាទ, អ៊ីចឹង អញ្ជើញខាង-- ដើម្បីពិសារបាយ*(មិនឮសំឡេង)*

**លោក ផន ធឿន៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១១:៥៨នាទី ដល់ម៉ោង ១៣:២៧នាទី)*

[១៣:២៧:០៨]

**លោក ផន ធឿន៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញអង្គុយ!

តុលាការសប្រកាសបន្តសវនាការបន្តទៅទៀត ហើយព្រឹកមិញនេះ គឺយើងបានដល់ការសួរចម្លើយ-- អំ! ការសួររបស់ចៅក្រមទៅលើសហមេធាវីការពារជនជាប់ចោទ។ ហើយជាបន្តទៅទៀតនេះ យើងបន្តសំណួរពីព្រឹកមិញ។

អ៊ីចឹងហើយលោកចៅក្រម មានសំណួរអីបន្ថែមទៀត សូមអញ្ជើញ!

[១៣:២៨:២៧]

**ចៅក្រម ចាន់ដ្រា ចាយ៉ាស៊ីញហ៍៖**

លោក កង ឫទ្ធារី, លោកបានលើកឡើងថា មានការរំលោភបំពានទៅលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ថាតើលោកមើលឃើញនៅត្រង់ចំណុចណា ដែលថាមានការរំលោភបំពានទៅលើច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះ?

**លោក កង ឫទ្ធារី៖**

សូមអរគុណចំពោះលោកចៅក្រមដែលបានផ្តល់សំណួរដល់ខ្ញុំបាទ។ គឺថាការប្រើប្រាស់ទំនៀម

ទម្លាប់អន្តរជាតិ វាខុសនឹងប្រព័ន្ធច្បាប់ដែលប្រទេសកម្ពុជាបានប្រើ គឺ ស៊ីវិលឡ ហើយថាទំនៀមទម្លាប់អន្តរជាតិដែលកើតឡើងដោយការបង្កើតនូវករណីយុត្តិសាស្ត្រនោះ ក៏ត្រូវបានហាមប្រាមដោយក្រមព្រហ្មទណ្ឌកម្ពុជាដែរ។ ហើយការប្រើប្រាស់ទំនៀមទម្លាប់អន្តរជាតិខុសមួយទៀតនោះ គឺថាការទោះបីជាបកស្រាយតាម ខំមិនឡ ក៏ការបកស្រាយហ្នឹងខុសទៅទៀត។ បានន័យថា ករណីយុត្តិសាស្ត្រ ឬគឺថាទំនៀមទម្លាប់អន្តរជាតិហ្នឹង គឺគេត្រូវធ្វើការប្រៀបធៀបនូវមូលហេតុនៃការកកើតនៃបទឧក្រិដ្ឋដែលកំណត់បានជាបទល្មើសមួយ ហើយគេកំណត់នូវច្បាប់មួយដែលមានទម្រង់ដូចគ្នា សម្រាប់តុលាការដែលមានប្រព័ន្ធច្បាប់ដូចគ្នាក្នុងការផ្ទឹមគ្នាយកមកប្រើ។

[១៣:២៩:៥៦]

ប៉ុន្តែនៅទីនេះ គេបានប្រើប្រាស់ប្រព័ន្ធនេះច្របូកច្របល់បន្តិច វាអាចនិយាយបានថា គេប្រើទាំង ស៊ីវិលឡ និង ខំមិនឡ ទៅលើច្បាប់ ដែលតាមពិតទៅមិនមានចែងនៅលើប្រទេសកម្ពុជាទេ ហើយការប្រើប្រាស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលថាខុសនោះ គឺថាខុសត្រង់ហ្នឹងឯង។ ខុសត្រង់ថា យើងមិនបានពិនិត្យមើលបុព្វហេតុនៃការករកើតបទឧក្រិដ្ឋ និងបទឧក្រិដ្ឋដែលមានលក្ខណៈតាមសទិសភាព ឬលក្ខណៈថាស្រដៀងគ្នា។ បានន័យថា បើចង់យកបទឧក្រិដ្ឋនៅយូហ្គោស្លាវី ឬក៏នៅ រវ៉ាន់ដា យកមកប្រៀបធៀបទៅនឹងបទឧក្រិដ្ឋដែលកើតនៅក្នុងប្រទេសកម្ពុជា ដែលបង្កើតដោយរបបកម្ពុជាប្រជាធិប-តេយ្យ យើងត្រូវធ្វើម៉េចប្រៀបធៀបឲ្យឃើញថា បទឧក្រិដ្ឋនោះកើតឡើងប្រហែលគ្នា។ វាមិនមែនតែឈ្មោះដូចគ្នាទេ សភាពការណ៍នៃការកកើតបទឧក្រិដ្ឋនោះ គឺដូចគ្នាផងដែរ។ នេះជាទំនៀមទម្លាប់អន្តរជាតិដែលគេប្រើ។ មិនមែនចេះតែយកសេចក្តីសម្រេចចិត្តរបស់តុលាការផ្សេងៗមកហើយ មកប្រើហើយ ដោយឆ្លើយទៅវិញថា នេះជាទំនៀមទម្លាប់អន្តរជាតិនោះទេ វាខុសនឹងទំនៀមទម្លាប់អន្តរជាតិត្រង់ហ្នឹងឯង។ ត្រង់ថាការកំណត់និយមន័យនៃទំនៀមទម្លាប់អន្តរជាតិរបស់សាលាជម្រះក្តី អ.វ.ត.ក នៅពេលនេះ គឺមិនត្រឹមត្រូវ។

បាទ, អរគុណ។

[១៣:៣១:១២]

**ចៅក្រម ចាន់ដ្រា ចាយ៉ាស៊ីញហ៍៖**

លោកមេធាវី ការ សាវុត្ថ ខ្ញុំសូមអនុញ្ញាតសូមសួរលោក។ ឧទាហរណ៍ថា យើងសម្រេចថា ដើមបណ្តឹងសាទុក្ខ មិនមែនជាបុគ្គលម្នាក់នៅក្នុងប្រភេទអ្នកទទួលខុសត្រូវ មិនមែនជាមេដឹកនាំជាន់ខ្ពស់

ប៉ុន្តែគាត់ជាជនដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥។ តើថាលោកអាចពន្យល់បានយ៉ាងម៉េច? ថាតើលោកមានចំណុចការពារយ៉ាងម៉េចថាគាត់មិនមែនជាជនដែលទទួលខុសត្រូវបំផុតនោះទេ? ខ្ញុំសួរសំណួរនេះ ដោយសារតែលោកដឹងថាជនទទួលខុសត្រូវខ្ពស់បំផុត គឺមានកម្រិតនៃការទទួលខុសត្រូវរបស់វា។

[១៣:៣២:១៤]

ដូច្នេះ ថាតើលោកថ្លឹងថ្លែងទៅលើការទទួលខុសត្រូវរបស់គាត់យ៉ាងម៉េច? ដូច្នេះតើលោកអាចពន្យល់ទៅលើចំណុចនេះបានដែរឬទេ?

**លោក ការ សាវុត្ថ៖**

សូមគោរពលោកចៅក្រម, ក្នុងឆ្នាំ១៩៧៥ ដែលលោកចៅក្រមសួរខ្ញុំ។ ខ្ញុំសូមបញ្ជាក់សាថ្មីថា នៅឆ្នាំ១៩៧៥ កាំង ហ្គេកអ៊ាវ ហៅ ឌុច គាត់នៅ ម-១៣ នៅអមលាំង នៅស្រុកថ្ពង ខេត្តកំពង់ស្ពឺ។ គាត់អត់បានចូលរួមជម្លៀសប្រជាជន។ គាត់អត់បានកាប់សម្លាប់ប្រជាជនទេ ពីព្រោះនៅក្នុងកថាខណ្ឌរបស់សាលក្រម ក៏ដូចជាដីកាបញ្ជូនរឿងទៅដល់-- អ៊ូ! ទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតថា អ្នកដែលកាប់សម្លាប់ប្រជាជននៅពេលនោះ គឺអង្គភាពយោធា ហើយ តាឌុច ពេលនោះ គាត់ជានគរបាលនៅខេត្តកំពង់ស្ពឺ នោះទេ។

ដូច្នេះ គាត់អត់មានពាក់ព័ន្ធក្នុងឆ្នាំ១៩៧៥ ពីការសម្លាប់ប្រជាជនទេ។ បាទ ខ្ញុំសូមជម្រាបជូនតែប៉ុណ្ណឹង។

**ចៅក្រម ចាន់ដ្រា ចាយ៉ាស៊ីញហ៍៖**

ខ្ញុំចង់សួរលោក ការ សាវុត្ថ។ នៅពេលដែលដើមសាទុក្ខផ្តល់ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដើមបណ្តឹងបានលើកឡើងថា វាមានចំនួនដែលមនុស្សស្លាប់រួចទៅហើយនៅក្នុងស-២១។ ដូច្នេះ គាត់បដិសេធចោល។

[១៣:៣៤:០១]

ខ្ញុំគឺជាបុគ្គលម្នាក់ដែលទទួលខុសត្រូវទៅលើបទល្មើសនេះ ហើយខ្ញុំនៅតែរក្សាជំហរហ្នឹងដដែល។ ថាតើលោកអាចពន្យល់ដែរឬទេនៅត្រង់ចំណុចហ្នឹង? ថាតើហេតុអ្វីបានជាដើមបណ្តឹងសាទុក្ខបានធ្វើការសារភាពដូច្នេះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង?

**លោក ការ សាវុត្ថ៖**

សូមគោរពលោកចៅក្រម, អ្វីដែលខ្ញុំបានលើកឡើងនៅក្នុងសារណារបស់ខ្ញុំពីព្រឹកមិញ ខ្ញុំថា ឌុច ជាចារី។ ១៩៥គុក តុលាការចាត់ទុកជាចារី ត្រូវនៅក្រោយុត្តាធិការរបស់ អ.វ.ត.ក ហើយបុគ្គលិករបស់ ស-២១ ក៏ជាចារីដែរ ពីព្រោះទទួលបញ្ជាពី ឌុច។ ហើយ ឌុច ក៏ទទួលបញ្ជាតពីមជ្ឈិមបក្ស។

ដូច្នេះ ឌុច ក៏ជាចារីដែរ។ ត្រង់ហ្នឹងដែលត្រូវ ឌុច នៅក្រោយុត្តាធិការរបស់ អ.វ.ត.ក។ បាទ, ខ្ញុំសូមជម្រាបប៉ុណ្ណឹង។

[១៣:៣៥:១៤]

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញលោកចៅក្រម។

**ចៅក្រម សោម សិរីវឌ្ឍ៖**

សំណួរខ្ញុំសួរចំពោះលោកសហមេធាវីការពារក្តី។ គឺថានៅក្នុងកថាខណ្ឌ១០១ ចំណុច(ខ) នៃសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ឯកសារលេខ F14 ក៏ដូចជានៅក្នុងពេលសវនាការនេះ គឺថាលោកមេធាវីការពារក្តីបានស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលកំណត់ថា ការឃុំខ្លួនរបស់ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច គឺជាការកិច្ចការក្នុងការថែរក្សាការពារសាក្សី ដែលមានសក្តានុពលសម្រាប់ចង្អុលបង្ហាញមេដឹកនាំជាន់ខ្ពស់ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតលើឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅ ស-២១។ តើលោកមេធាវីអាចបញ្ជាក់បានទេ អំពីសំអាងផ្នែកផ្លូវច្បាប់ជុំវិញបញ្ហាដែលលោកលើកឡើងនេះ? សូមអរគុណ។

[១៣:៣៦:២១]

**លោក កង ឫទ្ធារី៖**

បាទ, សូមអរគុណ សូមគោរពចំពោះតុលាការ។ ខ្ញុំសហមេធាវីសូមឆ្លើយតបថា ដោយមូលហេតុដែលយើងខ្ញុំបានសន្និដ្ឋានថា ការឃុំខ្លួនមួយរយៈនេះចាត់ទុកថាជាការការពារសាក្សីដែលមានសក្តានុពលនោះ ពីព្រោះថារដ្ឋាភិបាលបានចាប់ខ្លួនគាត់មកដោយខុសនិតិវិធីរួចទៅហើយ។ ទីមួយ។

ទីពីរ គាត់បានធ្វើសក្ខីកម្មប្រឆាំងទៅនឹងការលុបបំបាត់ភស្តុតាងនៃស-២១ ដោយ ប៉ុល ពត ដែលសម្ភាសជាមួយនឹង នេត ថាយ័រ ថាស-២១ នេះមានអាទិភាពឡើង គឺជាការក្លែងក្លាយទេ គឺបង្កើតឡើងដោយពួកយួន ទាហានយួន។ ហើយ កាំង អ៊ាវហ្គេក ហៅ ឌុច គាត់បានចេញមកសារភាព ហើយ

ប្រាប់ថា ស-២១ នេះ គឺកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងពិតប្រាកដ ដែលមានខ្លួនគាត់ជាប្រធានសន្តិបាល ហើយមាន សុន សេន និង នួន ជា ជាចៅហ្វាយនាយគាត់។

[១៣:៣៧:១៩]

ម្យ៉ាងវិញទៀត បើយើងសិក្សាទៅលើនីត្យានុកូលភាពនៃភស្តុតាង យើងអាចសម្លឹងមើលឯកសារដែលបង្ហាញព្រឹកមិញដោយសហមេធាវីការពារជនជាប់ចោទ គឺសេចក្តីសម្រេចសម្ងាត់ចុះថ្ងៃទី៣០ មីនា ឆ្នាំ១៩៧៦ ដែលបង្ហាញឲ្យឃើញថា អ្នកណាខ្លះដែលមានសិទ្ធិសម្រេចចិត្តឲ្យកម្ទេចក្នុងជួរ និងក្រៅជួរ គឺក្រុមមេដឹកនាំជាន់ខ្ពស់ទាំងអស់ គឺមានពីរខ្សែ។ ខ្សែទីមួយ គឺខ្សែដែលចេញមកពីខ្សែបក្ស គឺអចិន្ត្រៃយ៍កម្ទេចជុំវិញអចិន្ត្រៃយ៍ និងតំបន់ឯករាជ្យ ហើយនិងតាមភូមិភាគ គឺអចិន្ត្រៃយ៍ភូមិជាអ្នកកម្ទេច។

[១៣:៣៧:៥៥]

ឯកតាមខ្សែទីពីរ គឺខ្សែរដ្ឋាភិបាល គឺប្រគល់ការងារនេះទៅឲ្យគណៈយោធាមជ្ឈិម ដែលមាន សុន សេន ជាប្រធានអគ្គសេនាធិការក្នុងការដឹកនាំប្រតិបត្តិការពីរផ្នែក គឺការពារជាតិនិងរក្សាសន្តិសុខ។

ដូច្នេះ សុន សេន ហ្នឹងឯងជាអ្នកគ្រប់គ្រងស-២១ ហើយបន្ទាប់មកទៀត បន្ទាប់ពី សុន សេន ផ្លាស់ទៅសមរភូមិមុខ វាយទល់នឹងកងទ័ពវៀតណាម នួន ជា ខ្លួនឯងជំនួស ហើយប្រកាសប្រាប់លោក កាំង អ៊ាវហ្គេក ហៅ ឌុច ដដែលហ្នឹងថា គាត់ជាប្រធាន ស-២១ មិនមែន ឌុច ទេ។ ព្រោះ ឌុច តែងតែប្រកែកនឹងបទបញ្ជាខ្លះដែលនាំដល់ការសម្លាប់មនុស្ស ការរំលោភសេពសន្ថវៈ ហើយនិងការធ្វើទារុណកម្ម។

[១៣:៣៨:៣១]

ហើយហេតុនេះហើយបានជា នួន ជា គាត់ប្រកាសថា គឺមិនមែន គឺគាត់ជាប្រធានស-២១ មិនមែន កាំង អ៊ាវហ្គេក ហៅ ឌុច ឯងនេះទេ ជាប្រធានសន្តិសុខនៃស-២១។ ហេតុនេះហើយបានជា យើងបញ្ជាក់ថា នេះជាភស្តុតាង និងចងភ្ជាប់ទៅនឹងអង្គច្បាប់ដែលថា កាំង អ៊ាវហ្គេក ហៅ ឌុច គឺមានគុណភាពជាសាក្សី។ នេះទីមួយ។

[១៣:៣៨:៥៦]

ទីពីរទៀត គឺថា លោក កាំង អ៊ាវហ្គេក ហៅ ឌុច តែងសហការជាមួយតុលាការជានិច្ច ហើយសំណួររបស់តុលាការមិនបានសួរជុំវិញនូវបទឧក្រិដ្ឋដែលកើតឡើងគុកទួលស្លែង ជាជាងការសួរចង្អុលបង្ហាញពីថ្នាក់ដឹកនាំជាន់ខ្ពស់លើ កាំង អ៊ាវហ្គេក ហៅ ឌុច ហ្នឹងទៅទៀត។ នេះហើយដែលមាន

គុណភាពជាសាក្សី។ ហើយការឃុំខ្លួនរយៈពេលយូរនោះ យើងមានការយល់គ្នាទៅវិញទៅមកដោយសារស្ថានភាពពិសេសនៃប្រទេសកម្ពុជា។ ដូច្នេះហើយទើបយើងកំណត់ថា ការឃុំខ្លួនមួយរយៈនេះចាត់ទុកជាកិច្ចការពារសាក្សីដ៏មានសក្តានុពល។ បាទ, អរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញលោកចៅក្រម ណូហ្គូជិ។

**ចៅក្រម ម៉ូតូ ណូហ្គូជិ៖**

ខ្ញុំចង់សួរសំណួរមួយសំណួរទៅកាន់ក្រុមមេធាវីការពារក្តី។ នៅក្នុងការផ្តល់ទឡ្ហីករណ៍របស់លោកកាលពីព្រឹកមិញ លោកបានគូសបញ្ជាក់សង្កត់ធ្ងន់ថា ជនជាប់ចោទមិនមែនជាមេដឹកនាំជាន់ខ្ពស់មួយរូបនោះឡើយ។ ប៉ុន្តែ ជនជាប់ចោទជាអ្នកទទួលបញ្ជាពីថ្នាក់លើរបស់គាត់។

[១៣:៤០:០៨]

ខ្ញុំចង់សួរសំណួរនិងការសង្កេតរបស់លោកសហមេធាវីការពាក្តី។ សូមមើលមាត្រា២៩ នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក។ នៅក្នុងប្រយោគទីពីរ នៃមាត្រា២៩ នៃច្បាប់ អ.វ.ត.ក បានចែងថា "តួនាទីនិងឋានៈរបស់ជនសង្ស័យមិនអាចជួយសម្រាលនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជននោះបានឡើយ ឬក៏មិនអាចជួយបន្ថយនូវការដាក់ទោសទណ្ឌកម្មបានឡើយ"។

នៅក្នុងប្រយោគទីបួន នៃមាត្រាដដែលចែងថា "ករណីដែលជនសង្ស័យបានប្រព្រឹត្តតាមបញ្ជារបស់រដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យ ឬក៏តាមបញ្ជាមេរបស់ខ្លួននោះ មិនអាចជួយបន្ថយជនសង្ស័យចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនបានឡើយ"។

[១៣:៤១:១៤]

ខ្ញុំចង់សួរទៅកាន់សហមេធាវីការពារក្តី សូមឲ្យលោកធ្វើការបញ្ជាក់បំភ្លឺត្រង់មាត្រានេះ។ សូមឲ្យលោកបង្ហាញជំហររបស់លោកដោយលើកឡើងនូវមាត្រានេះ។ សូមអរគុណ។

**លោក ការ សាវុត្ថ៖**

សូមគោរពលោកចៅក្រម, ខ្ញុំសូមអនុញ្ញាតបញ្ជាក់ថា"ជនសង្ស័យ" ពាក្យថា "ជនសង្ស័យ" នេះបើនៅតាមមាត្រា២ នៃច្បាប់ អ.វ.ត.ក គឺគេបញ្ជាក់ច្បាស់ថា មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត គេឲ្យឈ្មោះហៅថា "ជនសង្ស័យ"។ នេះជាចំណុចទីមួយ។

[១៣:៤២:០២]

ទីពីរ នៅក្នុងនេះ ដែលថាអ្នកដែលបានប្រព្រឹត្តបទឧក្រិដ្ឋរួចហើយនេះ គឺថាមិនអាចជួយជនសង្ស័យនោះឲ្យរួចផុតពីបទល្មើស។ ជម្រាបថាច្បាប់នេះ គេចែងចងក្រងជាទូទៅ។ ដូចនៅប្រទេសគេក៏ដោយ គេកាត់ទោសជាទូទៅ ឲ្យតែប្រព្រឹត្តបទល្មើស គេចាប់អូសក យកមកកាត់ទោស។

ដោយឡែកនៅកម្ពុជា ច្បាប់ អ.វ.ត.ក បានបញ្ជាក់ច្បាស់ហើយថា យកតែពីរប្រភេទទេ គឺមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតយកមកកាត់ទោស។

[១៣:៤២:៤៩]

អ៊ីចឹងអ្នកដទៃទៀត ជាចារីត្រូវរួច-- ចារី អ្នកដៃដល់ អ្នករួមប្រព្រឹត្ត អ្នកសមគំនិត គឺនៅក្រៅយុត្តាធិការរបស់ អ.វ.ត.ក។ ហើយខ្ញុំបានបញ្ជាក់ជូនលោកចៅក្រមអម្បាញ់មិញហើយថា មេគុកទាំងអស់ ១៩៥គុក ជាចារី។ កូនចៅរបស់ស-២១ របស់ តាឌុច ក៏ជាចារី ត្រូវរួចផុតពីការចោទប្រកាន់ដោយសារទទួលបញ្ជាពី តាឌុច។

អ៊ីចឹង តាឌុច ទទួលបញ្ជាពី នួន ជា ទទួលបញ្ជាពី សុន សេន ទទួលបញ្ជាពីមជ្ឈិមបក្ស ក៏ជាចារីត្រូវតែរួចផុតពីការចោទប្រកាន់ដូចគ្នា។ ខ្ញុំសូមអនុញ្ញាតជម្រាបប៉ុណ្ណឹងសិន។

[១៣:៤៣:៣០]

**លោក កង ឫទ្ធារី៖**

ខ្ញុំសូមបន្តបន្តិចបាទ។ ក្នុងមាត្រា២៩ ដែលលើកឡើងដោយចៅក្រម គឺថាសំដៅលើការយកឋានៈតួនាទីរបស់បុគ្គលប្រព្រឹត្តមក ឬអភ័យឯកសិទ្ធិដូចដែលខ្ញុំបានលើកពីព្រឹកមិញយកមកការពារ គឺហាមប្រាមដោយច្បាប់ជាតិនិងទំនៀមទម្លាប់អន្តរជាតិយើងទទួលស្គាល់។ ប៉ុន្តែ លោកក៏ត្រូវពិនិត្យមើលអំពីមាត្រា១ នៃគោលបំណងរបស់ អ.វ.ត.ក ច្បាប់បង្កើត អ.វ.ត.ក និងមាត្រា១(២) នៃច្បាប់ អ.វ.ត.ក ដែលដាក់កំហិតទៅលើសិទ្ធិអំណាចរបស់អង្គជំនុំជម្រះថា ឲ្យជំនុំជម្រះតែទៅលើបុគ្គលពីរក្រុមទេ គឺក្រុមមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្ម។ បានន័យថា បើសិនថាយើងរកឃើញថាគាត់នៅក្នុងជំពូកនៃក្រុមពីរនេះហើយ ទោះបីជាគាត់ប្រើករណី *ដូរ៉េស* ការយកមកការពារខ្លួន ការកៀបសង្កត់ ឬក៏ការស្តាប់បញ្ជាថ្នាក់លើ គឺយើងមិនអាចទទួលយកបានទេ។

[១៣:៤៤:៣០]

ផ្ទុយទៅវិញ យើងបានរកឃើញថា លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច នេះមិនស្ថិតនៅក្នុងក្រុមជំពូកក្រុមទាំងពីរខាងលើនេះទេ។ ហេតុនេះជាទូទៅ ពលរដ្ឋទូទៅ និងគោលករណ៍ជាទូទៅ អាចយកករណីការង្ខិតបង្ខំ ឬការការពារខ្លួន នោះគឺថាជម្រើសរវាងកាតព្វកិច្ច និងសីលធម៌មកប្រើប្រាស់ និងកិច្ចការពារខ្លួនបាន។

[១៣:៤៤:៥២]

អ្វីដែលយើងលើកនៅពេលនេះ មិនមែនលើកអំពីយុត្តាធិការលើបទល្មើសទេ គឺយើងលើកអំពីយុត្តាធិការលើបុគ្គល។ ប្រសិនបើបុគ្គលនោះ មិនស្ថិតនៅក្នុងក្រុមទាំងពីរទេ គឺសាលាជម្រះក្តីគ្មានសិទ្ធិលើកឡើងនូវរឿងអ្វីផ្សេងពីនោះមកទៀតបានទេ។ បានន័យថា មិនអាចធ្វើការជំនុំជម្រះ ឬធ្វើការសម្រេចសេចក្តីណាមួយបានទេ។ អរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, ជាបន្តសូមអញ្ជើញសហព្រះរាជអាជ្ញាធ្វើសេចក្តីថ្លែងឆ្លើយតបទៅនឹងសហមេធាវីការពារជនជាប់ចោទ។ សូមអញ្ជើញ!

**លោកស្រី ជា លាង៖**

ជាដំបូង សូមគោរពអង្គជំនុំជម្រះតុលាការកំពូលជាទីគោរព ក៏ដូចជាគោរពអង្គសវនាការទាំងមូល។

ក្រោយពីបានស្តាប់សារណារបស់សហមេធាវីការពារក្តីរបស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច និងសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ សហព្រះរាជអាជ្ញា សូមធ្វើការឆ្លើយតបដូចតទៅ៖

ថ្ងៃនេះ អង្គសវនាការតុលាការកំពូល នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការជាសាធារណៈ ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខរបស់គូភាគី។ ចាប់តាំងពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ដែលជាថ្ងៃអង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រម សហព្រះរាជអាជ្ញា ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បានប្តឹងសាទុក្ខប្រឆាំងនឹងសាលដីកា ឬក៏សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។

[១៣:៤៦:៥៨]

សហព្រះរាជអាជ្ញាបានដាក់សារណានៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០ រីឯខាងមេធាវីការពារក្តីរបស់ជនជាប់ចោទ បានដាក់សារណាបណ្តឹងឧទ្ធរណ៍នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០។

នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០ សហព្រះរាជអាជ្ញា បានដាក់ចម្លើយតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី ឌុច នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១។

មេធាវីការពារក្តី ឌុច បានដាក់ចម្លើយតបមកវិញនូវចម្លើយរបស់សហព្រះរាជអាជ្ញា ដែលដាក់នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០ និងចុងក្រោយសហមេធាវីការពារក្តីបានដាក់ឯកសារភស្តុតាងថ្មីបន្ថែមនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០១១។

សហព្រះរាជអាជ្ញាសូមធ្វើការឆ្លើយតបទៅនឹងសារណារបស់មេធាវីការពារក្តី និងការឆ្លើយតបរបស់មេធាវីការពារក្តីនូវចម្លើយតបរបស់សហព្រះរាជអាជ្ញានៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០ ដោយមានអំណះអំណាងដូចខាងក្រោម៖

[១៣:៤៨:០៩]

អំពីយុត្តាធិការបុគ្គល ឌុច។ មេធាវីបានលើកឡើងនៅក្នុងសារណាលាយលក្ខណ៍អក្សរ របស់មេធាវីការពារក្តី ដោយយោងទៅលើមាត្រា២៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ អ.វ.ត.ក ថា ឌុច មិនចូលក្នុងយុត្តាធិការទេ។ ឌុច ត្រូវតែបានដោះលែង ហើយការឃុំខ្លួន ឌុច កន្លងមក គឺជាការឃាត់ខ្លួនក្នុងនាមសាក្សីសក្តានុពលសម្រាប់ចង្អុលបង្ហាញពីការទទួលខុសត្រូវរបស់មេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់នៅក្នុងក្របខ័ណ្ឌមន្ទីរសន្តិសុខស-២១។

ក្នុងខ្លឹមសារដូចដែលបានលើកឡើងដោយមេធាវីការពារក្តី ឌុច ខាងលើនេះ សហព្រះរាជអាជ្ញាសូមបញ្ជាក់ថា ការលើកយោងយកមាត្រា២៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងច្បាប់ អ.វ.ត.ក ដែលថា ឌុច មិនចូលក្នុងយុត្តាធិការរបស់ អ.វ.ត.ក គឺជាការបកស្រាយផ្ទុយនឹងខ្លឹមសារមាត្រា១ នៃច្បាប់ អ.វ.ត.ក ដែលជាច្បាប់ពិសេសសម្រាប់នៅក្នុងការអនុវត្តនៅ អ.វ.ត.ក យើងនេះ។

[១៣:៤៩:២៥]

ម៉្យាងទៀត ឌុច មិនអាចចាត់ជាទុកជាសាក្សីសក្តានុពលនៅក្នុងសំណុំរឿង០០១ បានទេ ពីព្រោះ ឌុច បានទទួលស្គាល់អំពីតួនាទីនិងសិទ្ធិអំណាចរបស់ខ្លួន ជាពិសេសទទួលស្គាល់ចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅមន្ទីរស-២១ ក្នុងនាមជាប្រធានមន្ទីរសន្តិសុខស-២១។ ដូច្នេះ ឌុច ត្រូវតែជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងក្របខ័ណ្ឌមន្ទីរសន្តិសុខស-២១ ដែលជាមន្ទីរសន្តិសុខមានលក្ខណៈពិសេសតែមួយគត់ ក្នុងរចនាសម្ព័ន្ធមន្ទីរសន្តិសុខក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

[១៣:៥០:០៧]

ចំពោះការកំណត់ការទទួលខុសត្រូវរបស់ ឌុច ឋិតនៅក្នុងក្របខ័ណ្ឌមន្ទីរសន្តិសុខស-២១ សហចៅក្រមស៊ើបអង្កេតបានបំបែកសំណុំរឿង ដែលនៅក្នុងសំណុំរឿង០០១ ឌុច ត្រូវបានអង្គជំនុំជម្រះសាលាដំបូងបានប្រកាសផ្ដន្ទាទោសដាក់ពន្ធនាគារ កំណត់រយៈពេល៣៥ឆ្នាំ។ ចំណែកឯសំណុំរឿង០០២ ឌុច អាចក្លាយទៅជាសាក្សីមានសក្ដានុពល ដែលអាចផ្ដល់សក្ខីកម្មបង្ហាញឲ្យឃើញអ្នកទាំងឡាយណាដែលជាមេដឹកនាំកំពូលជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម ដែលបានកើតឡើងនៅក្នុងក្របខ័ណ្ឌមន្ទីរសន្តិសុខស-២១ ហើយ ឌុច ត្រូវបានសហចៅក្រមស៊ើបអង្កេតលើកលែងការចោទប្រកាន់ ឌុច រួចហើយ។

[១៣:៥០:៥៩]

សហព្រះរាជអាជ្ញា សូមជម្រាបជូនអង្គជំនុំជម្រះតុលាការកំពូលថា កាលនៅដំណាក់កាលដំបូងនៃសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង មេធាវីការពារក្ដី ឌុច បានលើកឡើងតែអញ្ញត្រកម្ម អំពីការហួសអាជ្ញាយុកាលនៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ អំពីបទល្មើសមនុស្សឃាត និងទារុណកម្ម ដែលមានចែងនៅក្នុងមាត្រា៣ នៃច្បាប់ អ.វ.ត.ក តែប៉ុណ្ណោះ ដែលកាលនោះបទល្មើសពីរនេះ សហចៅក្រមស៊ើបអង្កេតបដិសេធមិនដាក់បញ្ចូលនៅក្នុងដីកាដំណោះស្រាយ ហើយសហព្រះរាជអាជ្ញាបានប្ដឹងឧទ្ធរណ៍នឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត។

[១៣:៥១:៤៨]

ជាចុងក្រោយ អង្គបុរេជំនុំជម្រះបានសម្រេចគាំទ្រនូវបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាដោយដាក់បញ្ចូលនូវបទល្មើសមនុស្សឃាត និងទារុណកម្មនៅក្នុងដីការបស់ខ្លួន។ ដូច្នេះ ការលើកឡើងរបស់សហមេធាវីការពារក្ដីអំពីយុត្តាធិការបុគ្គល នៅក្នុងសារណាបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅពេលនេះ គឺមិនអាចទទួលយកបានឡើយ ពីព្រោះមិនស្របតាមខ្លឹមសារនៃមាត្រា៨៩ នៃវិធានផ្ទៃក្នុង ដែលតម្រូវឲ្យភាគីត្រូវលើកអញ្ញត្រកម្មនៅពេលសវនាការបឋម។ បើមិនដូច្នេះទេ គឺមិនអាចទទួលយកបានឡើយ។

[១៣:៥២:២៨]

ជាមួយគ្នានឹងដែរ មេធាវីការពារក្ដីមិនបានប្ដឹងឧទ្ធរណ៍អំពីទោសទេ ដែលអង្គជំនុំជម្រះសាលាដំបូងបានផ្ដន្ទាទោស កំណត់រយៈពេល៣៥ឆ្នាំ មកលើ ឌុច តែមេធាវីការពារក្ដីបានលើកអំពីការភ័ន្តច្រឡំក្នុងការកំណត់យុត្តាធិការបុគ្គល ឌុច ខុស ដែលនាំឲ្យមានការដោះលែង ឌុច។

[១៣:៥២:៥០]

ចំពោះការកំណត់យុត្តាធិការបុគ្គល អង្គជំនុំជម្រះសាលាដំបូងបានសម្រេចត្រឹមត្រូវហើយ ដោយអង្គជំនុំជម្រះយល់ឃើញថា ឌុច គឺស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ជាលក្ខណៈបុគ្គល ក្នុងឋានៈជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនានាក្នុងក្របខ័ណ្ឌមន្ទីរសន្តិសុខស-២១ ដែលបានប្រព្រឹត្តឡើងក្នុងអំឡុងថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ ហើយម៉្យាងទៀត ឌុច ខ្លួនឯងជារឿយៗ តែងតែបានទទួលស្គាល់ការទទួលខុសត្រូវរបស់ខ្លួនចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងក្របខ័ណ្ឌមន្ទីរសន្តិសុខស-២១ ក្នុងនាមជាប្រធានតាំងពីដំណាក់កាលស៊ើបអង្កេតមកម្ល៉េះ។

[១៣:៥៣:៤៧]

ចុងបញ្ចប់នៃថ្ងៃសវនាការ ដែលសវនាការបានប្រព្រឹត្តឡើងអស់រយៈពេលចំនួនប្រាំបួនខែ ចាប់តាំងពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ ដល់ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលជាថ្ងៃត្រូវធ្វើសេចក្តីសន្និដ្ឋានបិទការពិភាក្សាដេញដោល។

ក្នុងការធ្វើសេចក្តីសន្និដ្ឋានបិទពិភាក្សាការដេញដោលនេះ មេធាវីការពារក្តី ឌុច បានលើកអំពីការកំណត់យុត្តាធិការលើរូប ឌុច ទៅវិញ ហើយការកំណត់យុត្តាធិការខុស គឺនាំឲ្យ ឌុច ត្រូវបានដោះលែង ហើយ ឌុច ខ្លួនឯងផ្ទាល់ក៏បាននិយាយសម្តីចុងក្រោយរបស់ខ្លួន ដោយសុំឲ្យអង្គជំនុំជម្រះសាលាដំបូងដោះលែងខ្លួនដែរ។

ផ្ទុយទៅវិញ មេធាវីការពារ ឌុច ផ្នែកខាងអន្តរជាតិដែលបានសន្និដ្ឋានបង្ហាញឲ្យឃើញថា គ្រាន់តែចង់សម្រាលទោស ឌុច តែប៉ុណ្ណោះ។ មេធាវី ឌុច បានលើកឡើងថា ការជំទាស់របស់ចៅក្រម ឡាវែន៍ នៅក្នុងការផ្តន្ទាទោសកំណត់មិនឲ្យលើស៣០ឆ្នាំ បានបង្ហាញឃើញថា អង្គជំនុំជម្រះសាលាដំបូង រកសំឡេងមិនបានគ្រប់គ្រាន់ក្នុងការកំណត់យុត្តាធិការទៅលើ ឌុច។

[១៣:៥៥:០២]

ក្នុងន័យនេះ សហព្រះរាជអាជ្ញា សូមឆ្លើយតបវិញថា ការលើកឡើងនូវអំណះអំណាងខាងលើនេះ ជាការយល់ច្រឡំ ពីព្រោះអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ឌុច គឺស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ជាលក្ខណៈបុគ្គលក្នុងឋានៈជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ក្នុងក្របខ័ណ្ឌមន្ទីរសន្តិសុខស-២១។ ប៉ុន្តែ តាមពិតចៅក្រម ឡាវែន៍ និងចៅក្រម ខាតរ៉ាយថ៍ បានជំទាស់ទៅនឹងការអនុវត្តក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ដែលមានចែងនៅក្នុងមាត្រា៣ នៃច្បាប់ អ.វ.ត.ក អំពីបទ

មនុស្សឃាត និងទារុណកម្មតែប៉ុណ្ណោះ ដែលបានបន្តអាជ្ញាយុកាល ដោយរំលោភលើគោលការណ៍អប្រតិសកម្ម ដូចដែលបានលើកឡើងក្នុងអញ្ញត្រកម្មរបស់មេធាវីការពារ ឌុច នាពេលសវនាការបឋម។

[១៣:៥៦:១៤]

សហព្រះរាជអាជ្ញាសូមបញ្ជាក់ជូនដែរចំពោះអង្គជំនុំជម្រះតុលាការកំពូលថា អំពីការបកស្រាយច្បាប់ដែលមានចែងនៅក្នុងមាត្រា៣ នៃ អ.វ.ត.ក យោងតាមមាត្រា១២ និងមាត្រា៣១ នៃកិច្ចព្រមព្រៀង គឺតុលាការនេះ គឺប្រើច្បាប់កម្ពុជា ក្នុងករណីច្បាប់ជាតិគ្មានទើបយកច្បាប់អន្តរជាតិមកជំនួស។

ដូច្នេះ ត្រង់មាត្រា៣ អ.វ.ត.ក ត្រូវបានសភាជាតិអនុម័តរួចហើយ កម្ពុជាប្រើច្បាប់ប្រព័ន្ធស៊ីវិលឡ នោះមានន័យថា គ្មានចៅក្រមមកបកស្រាយច្បាប់ដែលសភាអនុម័តរួចហើយនោះឡើយ។ ការលើកឡើងរបស់មេធាវីការពារក្តី ដែលថា ឌុច មានឋានានុក្រមទាបជាងគេបង្អស់ ដែលនៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា និងទាំងក្នុងអាជ្ញាធររបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដោយដកស្រង់ពីឯកសារបង្ហាញរបស់អ្នកស៊ើបអង្កេតរបស់ការិយាល័យសហព្រះរាជអាជ្ញា ក្រេក ហើយថា ឌុច មានឋានៈស្មើនឹងកងវរសេវនាធំ។

[១៣:៥៧:១៩]

ការទាញអំណះអំណាងនេះ ដោយសារ ឌុច មិនមែនជាសមាជិកអចិន្ត្រៃយ៍ ឬជាសមាជិកមជ្ឈិមបក្សនៅក្នុងជួរបក្ស ហើយក៏មិនមែនជារដ្ឋមន្ត្រីក្នុងក្រសួង ឬគណៈកម្មការណាមួយដែរ។ ប៉ុន្តែផ្ទុយទៅវិញ ឌុច មានឋានៈស្មើនឹងកងវរសេនាធំនៃកងទ័ពបដិវត្តកម្ពុជាប្រជាធិបតេយ្យ ដែលនៅក្នុងកងទ័ពវរសេនាធំនេះ មានចំនួនកងកម្លាំងប៉ុន្មាននាក់នោះ វាពិបាកដឹងណាស់។

ចំពោះការណ៍សម្ងាត់អំពីចំនួនកម្លាំងពិតប្រាកដនៅក្នុងកងទ័ពកម្រមានព័ត៌មានជាក់លាក់។ ប៉ុន្តែតាមចម្លើយរបស់ ឌុច នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត បានបញ្ជាក់ថា កម្លាំងចូលរួមបង្កើតបានជាសមាសភាពរបស់មន្ទីរសន្តិសុខស-២១ មានកម្លាំងមកពីកងពល៧០៣ របស់ ណាត មានចំនួនប្រហែល៣00នាក់ កម្លាំងមកពីមន្ទីរសន្តិសុខម-១៣ មានចំនួន១០នាក់ និងកម្លាំងមួយចំនួនទៀត ដែលដឹកនាំដោយឈ្មោះ សុខ។ ជាងនេះទៀត យោងតាមឯកសារកម្លាំងរបស់មន្ទីរសន្តិសុខស-២១ មានចំនួន ២.៣២៧ នាក់ នៅក្នុងខែមីនា ឆ្នាំ១៩៧៧។

[១៣:៥៨:៤០]

ដូច្នេះ ទោះបីមេធាវីការពារ ឌុច បានលើកឡើងថា ឌុច មានឋានៈទាបក៏ដោយ ប៉ុន្តែតាមពិត

ឌុច បានគ្រប់គ្រងដំណើរការប្រកបដោយប្រសិទ្ធភាពនូវប្រតិបត្តិការរបស់មន្ទីរស-២១ ក្នុងនាមជាប្រធានមន្ទីរសន្តិសុខ ដែលមានវិសាលភាពទូទាំងប្រទេស និងមានលក្ខណៈពិសេសតែមួយគត់ក្នុងចំណោមមន្ទីរសន្តិសុខនានានៅសម័យរបបកម្ពុជាប្រជាធិបតេយ្យ ដែលទាំងសហព្រះរាជអាជ្ញា ទាំងសហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាគឺស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដែលជាលក្ខណៈបុគ្គលក្នុងឋានៈជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ក្នុងក្របខ័ណ្ឌមន្ទីរសន្តិសុខស-២១ ដោយពិចារណាលើអង្គហេតុដែលទាក់ទងនឹងលក្ខណៈពិសេសរបស់មន្ទីរសន្តិសុខស-២១។

[១៣:៥៩:៤៨]

មុនពេលអង្គជំនុំជម្រះសាលាដំបូងសម្រេចចេញសាលក្រមរបស់ខ្លួន កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូងបានដំណើរការនីតិវិធី ដោយមានការសវនាការបឋម ដើម្បីទុកសិទ្ធិឲ្យភាគីលើកអំពីអញ្ញត្រកម្ម ដូចដែលបានកំណត់នៅក្នុងវិធានផ្ទៃក្នុង។

[១៤:០០:០១]

សវនាការលើអង្គសេចក្តីពេញលេញ បានចាប់ដំណើរការអស់រយៈពេលប្រាំមួយខែ គឺចាប់តាំងថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ រហូតដល់ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ និងភាគីមានរយៈជិតបីខែ សម្រាប់ធ្វើសេចក្តីសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោល ដែលការធ្វើសេចក្តីបិទកិច្ចពិភាក្សាដេញដោលត្រូវបានធ្វើឡើងនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១០។

[១៤:០០:៤០]

ចុងក្រោយ សាលក្រមត្រូវបានប្រកាសជាសាធារណៈនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០។ ចាប់តាំងពីជនជាប់ចោទ ឌុច ត្រូវបានចាប់ខ្លួន និងចូលខ្លួនមកចំពោះមុខ អ.វ.ត.ក ដំបូងនៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ជនជាប់ចោទខ្លួនឯងផ្ទាល់ និងមេធាវីការពារក្តីបានចូលរួមក្នុងនីតិវិធិជាច្រើន ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ដូចជា ការចូលរួមក្នុងនីតិវិធីសួរយកចម្លើយជនជាប់ចោទ ការចូលរួមក្នុងនីតិវិធីនៃការចុះធ្វើការស៊ើបអង្កេតដល់ទីកន្លែងកើតហេតុ ទាំងវាលពិឃាដជើងឯក និងទីតាំងមន្ទីរស-២១ ដែលយើងហៅថា សារមន្ទីរទួលស្លែង និងការចូលរួមក្នុងនីតិវិធីនៃការសួរតទល់ ដែលនីតិវិធីទាំងអស់នេះត្រូវការការស៊ើបអង្កេតអស់រយៈជាងមួយឆ្នាំ គិតមកត្រឹមសហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយនៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៨។

[១៤:០១:៤៨]

នៅពេញរយៈពេលនៃការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត លោកមេធាវីការពារក្ដីរបស់ជនជាប់ចោទ ឌុច ខកខានមិនបានដាក់សំណើស្នើសុំបំពេញកិច្ច ដែលទាក់ទងនឹងការកំណត់យុត្តាធិការបុគ្គល ឌុច ដោយកោះហៅ នួន ជា ដែលជាអ្នកឋានៈខ្ពស់ជាង ឌុច ទោះបីជាមេធាវីការពារក្ដី ឌុច ខ្លួនបានអះអាងថា សហព្រះរាជអាជ្ញាមានការភ័ន្តច្រឡំនៅក្នុងការកំណត់យុត្តាធិការ ឌុច តាំងពីដំបូងមកហើយក៏ដោយ។

ជាងនេះទៀត នៅក្នុងដំណើរនីតិវិធីលើអង្គសេចក្ដី ជាពិសេសនៅក្នុងដំណើរការនីតិវិធីអង្គសវនាការបឋម លោកមេធាវីការពារក្ដី ឌុច គួរតែលើកអញ្ញត្រកម្មអំពីយុត្តាធិការបុគ្គល ជាជាងលើកអញ្ញត្រកម្មអំពីអាជ្ញាយុកាលនៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ ក្រៅពីនេះទៀត មេធាវីការពារក្ដីទាំងជាតិ និងអន្តរជាតិបានទទួលស្គាល់នូវអង្គហេតុជាច្រើន ដែលសហព្រះរាជអាជ្ញាបានស្នើឡើង ហើយជនជាប់ចោទខ្លួនឯងផ្ទាល់ បានទទួលការទទួលខុសត្រូវរបស់ខ្លួនចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងក្របខ័ណ្ឌមន្ទីរស-២១ ដែរ។ ដូចនេះ ការខកខានមិនបានអនុវត្តសិទ្ធិរបស់ខ្លួនក្នុងនាមជាមេធាវីការពារក្ដីឲ្យបានត្រឹមត្រូវតាំងពីដំណាក់កាលស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត និងតាំងពីដំណាក់កាលដំបូងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែលបានតម្រូវដោយវិធានផ្ទៃក្នុង។ ជាពិសេស ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែលតម្រូវឲ្យមេធាវីការពារ ឬភាគីលើកអញ្ញត្រកម្មនៅសវនាការបឋម។

[១៤:០៣:៣៨]

នៅពេលនេះ នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ការលើកអញ្ញត្រកម្មរបស់មេធាវីការពារ ឌុច អំពីយុត្តាធិការបុគ្គល ដែលមិនអនុវត្តតាមវិធានផ្ទៃក្នុង មិនអាចទទួលយកបានឡើយ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល គួរតែបដិសេធចោល។

[១៤:០៤:០១]

អង្គសវនាការជាទីគោរព, មេធាវីការពារក្ដី ឌុច នៅប្រកាន់ជំហរប្រឆាំងនឹងការបកស្រាយរវាងខ្លឹមសារនៃវិធាន៨៩ និង៨៧ នៃវិធានផ្ទៃក្នុងដដែល។ តាមខ្លឹមសារនៃវិធាន៨៩ ដែលបាននិយាយអំពីអញ្ញត្រកម្មដែលតម្រូវឲ្យភាគីលើកនៅសវនាការបឋម ហើយតាមខ្លឹមសារនៃវិធាន៨៧ នៃវិធានផ្ទៃក្នុងបានផ្ដល់ការអនុញ្ញាតឲ្យភាគីទាំងអស់បង្ហាញភស្តុតាងបានគ្រប់ពេលវេលាទាំងអស់ក្នុងអំឡុងពេលសវនាការដេញដោល។ ដើម្បីឲ្យជនជាប់ចោទរួចផុតពីការចោទប្រកាន់ មេធាវីការពារក្ដីត្រូវបង្ហាញ

ភស្តុតាងដោះបន្ទុក អំពីអង្គហេតុដូចដែលបានចោទប្រកាន់នៅដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាដំណោះស្រាយ ឬសាលក្រមរបស់អង្គបុរេជំនុំជម្រះសាលដីកា មិនមែនក្រោយពេលសវនាការអស់រយៈពេលប្រាំបួនខែ គ្រាន់តែថា អង្គជំនុំជម្រះសាលាដំបូងមិនបានត្រួតពិនិត្យភស្តុតាងលើយុត្តាធិការបុគ្គល ហើយ ទាមទារឲ្យមានការដោះលែងជនជាប់ចោទ ឌុច នោះទេ។ ដូច្នេះ ការបកស្រាយលើវិធាន៨៩ មានខ្លឹមសារដូចនឹងវិធាន៨៧ នៃវិធានផ្ទៃក្នុង នាំឲ្យវាមានការប៉ះពាល់ដល់សុខដុមវិធានរបស់ អ.វ.ត.ក។

[១៤:០៥:២៤]

ជាងនេះទៀត មេធាវីការពារជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានចុងក្រោយបង្អស់ ទាក់ទងនឹងអញ្ញត្រកម្ម ដោយបានលើកយោងការអនុវត្តនៅថ្នាក់ជាតិ គឺជាការមិនត្រឹមត្រូវទេ។ ពីព្រោះថា តាមពិតមេធាវីការពារជនជាប់ចោទ ធ្វើសេចក្តីសន្និដ្ឋានចុងក្រោយប្រាកដមែន។ ប៉ុន្តែ ការធ្វើសេចក្តីចុងក្រោយនេះមិនអាចលើកយកបញ្ហាទាំងទងនឹងអញ្ញត្រកម្មបានទេ។

ការលើកអញ្ញត្រកម្មត្រូវបានកំណត់ដោយមាត្រា៣៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលចែងថា "អញ្ញត្រកម្មត្រូវតែលើកឡើងឲ្យបានមុនដំណាក់កាលការពារដល់អង្គសេចក្តី បើពុំដូច្នេះទេ ពុំអាចទទួលយកបានឡើយ"។

ជាមួយគ្នាហ្នឹងដែរសហមេធាវីការពារក្តីបានលើកឡើងក្នុងសារណារបស់ខ្លួនអំពីច្បាប់ដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យនៅក្រៅច្បាប់។ នៅក្នុងសារណា ក៏ដូចជាការការលើកឡើងកាលពីព្រឹកមិញនេះមេធាវីការពារក្តី ឌុច បានលើកឡើងអំពីមាត្រា៥ នៃច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យនៅក្រៅច្បាប់។ នៅក្នុងកថាខណ្ឌទី១៥ នៃសារណាបណ្តឹងសាទុក្ខរបស់ខ្លួនថា "ច្បាប់នេះបានទុករយៈពេលប្រាំមួយខែ ដើម្បីឲ្យពួកខ្មែរក្រហមចុះចូលមករស់ក្នុងសង្គមជាតិ ជាមួយរាជរដ្ឋាភិបាលវិញដោយមិនយកទោស"។

[១៤:០៦:៥៦]

សហព្រះរាជអាជ្ញាយល់ឃើញថា ការមិនអនុវត្តការចុះចូល ឬមិនចុះចូល មិនមែនជាសមត្ថកិច្ចរបស់ អ.វ.ត.ក ទេ។ ពេលនេះសំណុំរឿងនេះ សហព្រះរាជអាជ្ញាបានចោទប្រកាន់ ឌុច ដោយយោងទៅលើច្បាប់ អ.វ.ត.ក ហើយនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ក៏ដូចជាដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា រួមទាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត គឺគ្មានពាក់ព័ន្ធនឹងអង្គហេតុ ឬអង្គច្បាប់ ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ដែរ។ ដូច្នេះ ការលើក

ឡើងរបស់មេធាវីការពារក្តីប្រាសចាកពីអង្គហេតុ និងអង្គច្បាប់ ដែលបានចោទទៅលើ ឌុច។

[១៤:០៧:៤៩]

ជាមួយគ្នានឹងដែរ គប្បីអង្គជំនុំជម្រះសាលាតុលាការកំពូល កុំលើកយកបញ្ហានេះមកពិចារណា។ ការណ៍ដែលមេធាវីការពារក្តីលើកឡើងថា មានការដោះលែងអ្នកទោស ដូចមានចែងក្នុងកិច្ចព្រមព្រៀងទីក្រុងបារីសនោះ គឺមានការដោះលែងតែអ្នកទោសសង្គ្រាម និងអ្នកទោសនយោបាយប៉ុណ្ណោះ ពីព្រោះនៅពេលនោះ គឺមានការប្រយុទ្ធគ្នារវាងបក្ខពួកខ្មែរទាំងអស់ រវាងរដ្ឋាភិបាលនិងចលនាប្រឆាំង។ តែចំពោះអ្នកបានប្រព្រឹត្តបទឧក្រិដ្ឋនៅក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក មិនមានចែងទេ។ ដូច្នេះ សូមសហមេធាវីការពារក្តី ឌុច ពិនិត្យឡើងវិញអំពីកិច្ចព្រមព្រៀងនៅទីក្រុងបារីស ត្រង់ចំណុចការដោះលែង និងនៅពិសេសត្រង់ចំណុចបុព្វកថា នៃកិច្ចព្រមព្រៀងនោះ។

[១៤:០៨:៥៦]

ចំណុចមួយទៀត ដែលមេធាវីការពារក្តីបានលើកយោងនៅក្នុងសារណារបស់ខ្លួនដែរ គឺយោងនៅក្នុងមាត្រា៩៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ គឺវាផ្ទុយនឹងមាត្រា១០០ ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។

ដូចដែលមេធាវីការពារ ឌុច បានលើកឡើងនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួនហើយ គឺក្នុងកថាខណ្ឌទី៣៥ ថា "ដោយយោងតាមមាត្រា៩៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលមានចែងថា "អំពើទាំងឡាយដែលនឹងមិនចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ នៅពេលដែលអំពើនោះត្រូវបានធ្វើឡើងតាមបញ្ជាច្បាប់ ហើយអ្នកដែលចេញបញ្ជានោះ គឺជាអាជ្ញាធរស្របច្បាប់"។

ចំពោះមាត្រាដែលមេធាវី ឌុច បានលើកឡើងនេះ បាននាំឲ្យយើងអាចលើកការចោទសួរថា តើរបបកម្ពុជាប្រជាធិបតេយ្យដែលដឹកនាំដោយបក្សកុម្មុយនីស្តកម្ពុជា មានបានយកច្បាប់មកអនុវត្តដែរឬទេ? ចម្លើយឆ្លើយថា គឺគ្មានច្បាប់ទេ។ ដោយសាររបបនេះបានបង្ហាញឲ្យសាធារណជន ទាំងជាតិ និងអន្តរជាតិថាជារបបឧក្រិដ្ឋមួយដោយផ្តើមចេញពីការកាប់សម្លាប់អតីតមន្ត្រីរដ្ឋាភិបាលសាធារណរដ្ឋខ្មែរនៅដំណាក់កាលដំបូងនៃថ្ងៃជ័យជម្នះ ១៧ មេសា ៧៥ ដែលបានជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែលជាយុទ្ធវិធីមួយក្នុងការចាប់ ការសម្លាប់អតីតមន្ត្រីរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ដោយយកលេសថាអាមេរិកាំងនឹងទម្លាក់គ្រាប់បែក។ ហើយបន្តបន្ទាប់ទៀត ដោយចាប់ផ្តើមសម្រិតសម្រាំងនៅក្នុងជួររបស់ខ្លួន ដោយចោទថាជាខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង។

[១៤:១០:៥៤]

ម្យ៉ាងទៀត នួន ជា ជាប្រធានសភាតំណាងប្រជាជន ដែលជាទូទៅគេដឹងគ្រប់ៗគ្នាហើយថា សភាជាស្ថាប័នធ្វើច្បាប់។ ដូចនេះយើងឃើញថា នៅក្នុងអំណាចរបស់ខ្លួន សភាតំណាងប្រជាជនមិនបានបង្កើតច្បាប់សម្រាប់អនុវត្ត ក្រៅពីអនុវត្តគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីកម្ពុជា។

ជាងនេះទៅទៀត នៅពេលសហចៅក្រមស៊ើបអង្កេតសួរពាក់ព័ន្ធនឹងមន្ទីរស-២១ ដែលបង្កើតឡើងដោយបក្សកុម្មុយនីស្តកម្ពុជាក្នុងគោលបំណងសម្រិតសម្រាំង និងវែកមុខជនក្បត់ក្នុងជួរបក្ស ក្នុងជួរកងទ័ព និងក្នុងជួររដ្ឋអំណាចរបស់ខ្លួន និងទទួលផងដែរ គិញបរទេសដែលត្រូវចាប់ខ្លួននៅក្នុងស្រុក ព្រមទាំងជនស៊ីវិល និងទាហានដែលនៅក្រៅការប្រយុទ្ធ ហើយដែលអ្នកទាំងអស់នោះត្រូវបានការពារ និងទទួលការវិនិច្ឆ័យដោយច្បាប់។ ឌុច បានឆ្លើយថា ខ្លួនមិនមានការអធិប្បាយលើចំណុចនេះទេ។

[១៤:១២:០២]

ទោះបីរបបកម្ពុជាប្រជាធិបតេយ្យ មានអាសនៈធម្មានុរូបនៅក្នុងអង្គការសហប្រជាជាតិក៏ដោយ ប៉ុន្តែ ចុងក្រោយរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានគេដឹងឮគ្រប់ៗគ្នាថា ជារបបមួយដែលគ្មានច្បាប់ គឺមានតែចេតនាឧក្រិដ្ឋ និងមានពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើង នៅក្នុងយុត្តាធិការដែលបានចែងនៅក្នុងច្បាប់ អ.វ.ត.ក។

ផ្ទុយទៅវិញ ការលើកយោងមាត្រាខាងលើរបស់មេធាវីការពារ ឌុច ខ្លឹមសារមាត្រា១០០ នៃច្បាប់ក្រមព្រហ្មទណ្ឌនៃច្បាប់ឆ្នាំ១៩៥៦ បានចែងយ៉ាងច្បាស់ថា "អ្នកក្រោមបង្គាប់ដែលទទួលបញ្ជា ហើយដឹងថាបញ្ជានោះខុសច្បាប់ មិនអាចគេចពីការទទួលការខុសត្រូវបានទេ"។ ក្នុងខ្លឹមសារមាត្រា ១០០ នេះ ដោយផ្សារភ្ជាប់នឹងអង្គហេតុជាក់ស្តែងរបស់ ឌុច ដែលស្ថិតនៅក្រោមក្របខ័ណ្ឌនៃការស៊ើបសួរទាក់ទងនឹងមន្ទីរស-២១ យើងឃើញថា ឌុច បានដឹងអំពីឧក្រិដ្ឋនៃការអនុវត្តនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាចាប់តាំងពីឆ្នាំ១៩៧៣ ក្នុងនាមខ្លួនជាប្រធានមន្ទីរម-១៣ នៅក្នុងឆ្នាំ១៩៧៥ និងក្រោយទទួលបរាជ័យរបប លន់ នល់ តាមរយៈការជម្លៀសប្រជាជន ការដកហូតកម្មសិទ្ធិ និងការសម្លាប់ជាឈុតៗ។

[១៤:១៣:៣៣]

ដូចនេះ យើងសន្និដ្ឋានថា ឌុច ពិតជាបានដឹងអំពីបទបញ្ជារបស់ថ្នាក់លើរបស់ខ្លួន ឲ្យអនុវត្តគោលមាគ៌ានយោបាយរបស់បក្សនៅក្នុងការកម្ទេចខ្មាំង ទោះបីថាខ្លួនចង់ដកខ្លួនចេញពីការងារសន្តិបាល

នេះ ក៏ដកមិនរួចដែរ។ ឌុច មិនអាចគេចចេញពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងក្របខ័ណ្ឌនៅក្នុងមន្ទីរសន្តិសុខស-២១ បានឡើយ ទោះបីខ្លួនអះអាងថា ខ្លួនធ្វើការងារនេះក្រោមបញ្ជារបស់ថ្នាក់លើក៏ដោយ។ ម៉្យាងទៀត មាត្រា២៩ នៃច្បាប់ អ.វ.ត.ក ចែងថា "ប្រការដែលថាជនសង្ស័យបានប្រព្រឹត្តអំពើឧក្រិដ្ឋទៅតាមបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬរបស់ថ្នាក់លើណាមួយ មិនអាចជួយជនសង្ស័យនេះ ឲ្យរួចផុតពីការទទួលខុសត្រូវជាបុគ្គល ចំពោះបទឧក្រិដ្ឋនេះបានឡើយ"។

[១៤:១៤:៤២]

ជាបន្ទាប់នេះ ខ្ញុំបន្តទៅទៀត ខ្ញុំសូមជម្រាបជូនអង្គជំនុំជម្រះតុលាការកំពូលថា សហព្រះរាជអាជ្ញានឹងលើកបញ្ជាក់ ដែលទាក់ទងទៅនឹងឯកសារពីរ ក្នុងនោះគឺ ឯកសារមន្ទីរគុកៗខ្មែរក្រហម ហើយនិងការ *សីឡិច* អា១៣១ ប្រវត្តិរូប។ ដូច្នេះ ដោយសារមានការ អង្គជំនុំជម្រះទទួលស្គាល់នូវឯកសារនេះ សហព្រះរាជអាជ្ញានឹងធ្វើការបកស្រាយខ្លះៗទាក់ទងទៅនឹងឯកសារទាំងពីរនេះ។

សហព្រះរាជអាជ្ញា ក៏សូមជម្រាថាគោលនយបោយរបស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹង គឺត្រូវអនុវត្តដោយមន្ទីរសន្តិសុខ ហើយបរិធានមន្ទីរសន្តិសុខហ្នឹង គឺជាបេះដូងនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការបោសសម្អាតខ្មាំងជាក់ស្តែង និងអ្នកដែលគេគិតថាជាខ្មាំង។

[១៤:១៥:៣២]

ចំពោះមន្ទីរសន្តិសុខស-២១ គឺជាមន្ទីរសន្តិសុខសំខាន់បំផុតនៅក្នុងបរិធាននេះ ទោះបីជាភស្តុតាងមិនបានបង្ហាញជាក់លាក់ថា មន្ទីរសន្តិសុខស-២១ មានតួនាទីត្រួតត្រាទៅលើមន្ទីរសន្តិសុខផ្សេងៗទៀតនៅទូទាំងប្រទេសក៏ដោយ ប៉ុន្តែវាច្បាស់ណាស់ថា មន្ទីរសន្តិសុខស-២១ គឺស្ថិតនៅលើគេបង្អស់នៃឋាននុក្រមមន្ទីរសន្តិសុខរបស់បក្សកុម្មុយនីស្តកម្ពុជា និងមានលក្ខណៈពិសេសតែមួយគត់ដែលសហព្រះរាជអាជ្ញាបានរកឃើញនូវចំណុចពិសេសៗដូចខាងក្រោម៖

[១៤:១៦:០៦]

ទីមួយ ដោយមន្ទីរសន្តិសុខស-២១ ជាមន្ទីរមួយតែមួយគត់នៅក្នុងប្រទេសកម្ពុជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលចាត់ទុកថានៅក្នុងថ្នាក់មជ្ឈិម ដែលទាក់ទងនឹងទំនាក់ទំនងផ្ទាល់ជាមួយនឹងគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ដែលមន្ទីរនេះបានផ្តល់យោបល់ និងរាយការណ៍ដោយផ្ទាល់អំពី

ការបោសសម្អាតខ្មាំងទៅថ្នាក់លើ មាន សុន សេន និងក្រោយមក នួន ជា ដែល ឌុច ត្រូវរាយការណ៍ជាប្រចាំតាមរយៈទូរស័ព្ទសម្ងាត់ចំពោះ សុន សេន ឬតាមរយៈនីរសារចំពោះ នួន ជា។

[១៤:១៦:៤៩]

ទីពីរ លក្ខណៈពិសេស គឺថាស-២១ គឺជាមន្ទីរសន្តិសុខថ្នាក់មជ្ឈិមតែមួយគត់ ដែលមានភារកិច្ចក្នុងការចាប់ខ្លួន ឃុំខ្លួន សួរចម្លើយ និងប្រហារជីវិតកម្មាភិបាលដឹកនាំជាន់ខ្ពស់ក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងក្រសួងគណៈកម្មាធិការស្ថាប័នរដ្ឋបាល កងទ័ពបដិវត្តន៍កម្ពុជា និងថ្នាក់ភូមិភាគ ថ្នាក់តំបន់របស់កម្ពុជាប្រជាធិបតេយ្យ។

សហព្រះរាជអាជ្ញា សូមជូនឧទាហរណ៍ជាក់ស្តែងមួយចំនួនដូចជា វន វ៉េត ហៅ ពេញ ធួកជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកខាងសេដ្ឋកិច្ច។ កុយ ធួនហៅ ធុច រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។ ហ៊ូ នឹម ហៅ ភាស់ រដ្ឋមន្ត្រីក្រសួងឃោសនាការ និងព័ត៌មាន។ តូច ភឿន ហៅ ភិន រដ្ឋមន្ត្រីក្រសួងសាធារណៈការ។ សួស វ៉ាស៊ី ហៅ ឌឿន អតីតប្រធានមន្ទីរ៨៧០ និងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។ នង សួន ហៅ ជ័យ ហៅ សែន លេខាគណៈកម្មាធិការកសិកម្ម។ ឈឹម សំអោក ហៅ ប៉ង់ មន្ទីររដ្ឋាភិបាល។ ឆាយ គឹមហ៊ំ ហៅ ហុក សេនាធិការក្រសួងការពារជាតិ។ សៀត ឆែ ហៅ ទុំ សេនាធិការក្រសួងការពារជាតិ។ ចេង អន រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម។ ណៃ សារ៉ាន ហៅ សាន លេខាភូមិភាគឦសាន។ មូល សម្បត្តិ ហៅ រស់ ញ៉ឹម លេខាភូមិភាគពាយព្យ។ ជូ ជេត ហៅ ស៊ី លេខាភូមិភាគបស្ចិម។ ទិត សុន ហៅ ញ៉ែម គណៈកម្មាធិការពាណិជ្ជកម្ម។ សួស នៅ ហៅ ឈូក លេខាតំបន់២៤ ភូមិភាគបូព៌ា។ កែ គឹមហួត ហៅ សុត លេខាតំបន់៧ ភូមិភាគពាយព្យ។ ចាន់ ចក្រី ហៅ ព្រំបាត់ លេខាកងពល១៧០។ អ៊ិន លន ហៅ ណាត អតីតលេខកងពល៧០៣។ អ៊ឹង សុខ ប្រធានពាណិជ្ជកម្មប្រចាំក្រុងហុងកុង។ ញ៉ែម ថូ លេខាមន្ទីរសន្តិសុខតំបន់៣២ ភូមិភាគមជ្ឈិម។

ឈ្មោះទាំងអស់នេះ ដែលបានលើកឡើងអម្បាញ់មិញ សហព្រះរាជអាជ្ញាគ្រាន់តែលើកដោយសង្ខេបខ្លីបំផុត ដើម្បីបង្ហាញថា មានកម្មាភិបាលជាន់ខ្ពស់ជាច្រើននាក់ត្រូវបានសម្លាប់នៅមន្ទីរស-២១ ដែលមន្ទីរសន្តិសុខផ្សេងៗទៀតគ្មាន ហើយមន្ទីរសន្តិសុខចុងជ្រោយរឹតតែគ្មានទៅទៀត។

[១៤:១៩:២៧]

ចំពោះចំនួននិងឈ្មោះអ្នកទោសលម្អិត គឺមាននៅក្នុងបញ្ជីអ្នកទោសរបស់មន្ទីរសន្តិសុខស-២១ ដែលការិយាល័យសហព្រះរាជអាជ្ញាបានធ្វើឡើង ហើយ ឌុច ក៏បានព្រមព្រៀងនឹងបញ្ជីឈ្មោះនោះដែរ

នៅក្នុងដំណាក់កាលស៊ើបអង្កេត។ ក្រៅពីនេះទៅទៀត មន្ទីរសន្តិសុខស-២១ ក៏បានដំណើរការជាឧបករណ៍មួយសម្រាប់ការបោសសម្អាតសមាសភាពសន្តិសុខផ្ទៃក្នុងខ្លួនឯងផងដែរ។ ដោយសារតែ ឌុច បានផ្តួចផ្តើមជ្រោមជ្រែងឲ្យមានការចាប់ខ្លួន និងកម្ទេចអ្នកនៅក្រោមបង្គាប់របស់ខ្លួនអស់ជាច្រើនរយនាក់។

នៅមន្ទីរស-២១ និងព្រៃស ដែលនៅព្រៃស ឌុច បានទទួលស្គាល់មានការយកអ្នកទោសពីព្រៃសទៅសម្លាប់នៅជើងឯក។ ឌុច បានអានឯកសារ ERN លេខ00006728 ដែលជាឯកសារនេះ បានបញ្ជាក់ថាមនុស្ស១៧នាក់ ត្រូវបានបញ្ជូនទៅសម្លាប់ដោយដឹកពីព្រៃសទៅជើងឯក និងបញ្ជាក់ផងដែរនៅចំនួនកុមារ១៦០នាក់ ត្រូវបានបញ្ជូនទៅសម្លាប់នៅជើងឯក។

[១៤:២០:៥៤]

មនុស្សទាំងនោះ បើសិនជាគ្មានការជ្រោមជ្រែងពី ឌុច ទេនោះ ថ្នាក់លើមិនដឹងពីទោសកំហុសរបស់បុគ្គលិកទាំងនោះឡើយ ហើយក៏គ្មានការចាប់ខ្លួន និងសម្លាប់អ្នកទាំងនោះដែរ។ ករណីនេះ ឌុច ក៏បានទទួលស្គាល់ដែរថា រាល់ការស្នើរបស់គាត់ទៅថ្នាក់លើមិនដែលមានការបដិសេធទេ។ ការណ៍នេះបង្ហាញឲ្យឃើញថា ឌុច ជាអ្នកមានអំណាចដ៏ធំធេងក្នុងការសម្រេចលើវាសនាអ្នកក្រោមបង្គាប់របស់ខ្លួនផ្ទាល់ ដែលមិនអាចប្រកែកបានឡើយ។

វាផ្ទុយទៅនឹងការលើកឡើងរបស់មេធាវីការពារក្តី ដោយអះអាងកូនក្តីរបស់ខ្លួនគ្មានអំណាចក្នុងការចាប់ចងជនណាឡើយ ដែលផ្ទុយពីចម្លើយរបស់សាក្សី ហ៊ឹម ហ៊ុយ ដែលបានឆ្លើយថា ជនជាប់ចោទមានពេលខ្លះបានទៅចាប់ទៅអ្នកទោសដោយផ្ទាល់។

[១៤:២១:៤៥]

ចំណុចទីបី ដែលជាលក្ខណៈពិសេសនោះ គឺមន្ទីរស-២១ ជាមន្ទីរសន្តិសុខតែមួយគត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលមានវិសាលភាពប្រតិបត្តិការទូទាំងប្រទេស និងបានជ្រៀតចូលដល់គ្រប់ថ្នាក់ទាំងអស់នៃរបបនេះ។ មន្ទីរនេះបានផ្តល់យោបល់ និងសម្របសម្រួលការបោសសម្អាតយ៉ាងទូលំទូលាយ ជាមួយនឹងរដ្ឋអំណាច ផ្នែករដ្ឋបាល និងយោធាទូទាំងប្រទេសកម្ពុជា។

ជាឧទាហរណ៍ជាក់ស្តែង ឌុច បានចូលរួមប្រជុំនៅកងពល២៩០ និងកងពល១៧០ ស្នើយកឈ្មោះ២៨នាក់ទៀត ឲ្យមានការសហការរវាង ឌុច ប្រធានមន្ទីរស-២១ និងកងពលទាំងពីរខាងលើ។ មន្ទីរសន្តិសុខស-២១ ទទួលអ្នកទោសពីគ្រប់ទីកន្លែងអស់ដែលគេបញ្ជូនមក។

[១៤:២២:៣៦]

ចំណុចទីបួន លក្ខណៈពិសេសនេះដែរ មន្ទីរនេះបានប្រើប្រាស់ធនធានយ៉ាងទូលំទូលាយ និងបានបង្កើតនូវទម្រង់ដ៏ប៉ិនប្រសប់បំផុតសម្រាប់ដំណើរការ ដូចជាការគ្រប់គ្រង ការឃុំឃាំង ការសួរចម្លើយ និងការសម្លាប់អ្នកទោស។ ការគ្រប់គ្រងបង្កើតបានជាអង្គការលេខដែលមានសមាសភាព និងតួនាទីច្បាស់លាស់។ ការឃុំឃាំងបានដាក់ចេញនូវសារាចរច្បាស់លាស់សម្រាប់អ្នកយាម ដើម្បីត្រួតពិនិត្យអ្នកទោសជាប់ឃុំឃាំង។ ការសួរចម្លើយបង្កើតឲ្យមានក្រុមសួរចម្លើយបី គឺក្រុមត្រជាក់ ក្រុមអង្គាម និងក្រុមក្តៅ ដែលទទួលបានការបណ្តុះបណ្តាល និងបំពាក់បំប៉នស្មារតីពី ឌុច ព្រមទាំងបង្កើតឲ្យមានក្រុមសួរចម្លើយអ្នកទោសពិសេស។ ការសម្លាប់ បានបង្កើតឲ្យមានវិធីនៃការសម្លាប់ តាមរបៀបបូមឈាម និងការដឹកយកទៅសម្លាប់នៅជើងឯក ដោយមានចំណារ ឌុច ចារបញ្ជាដាច់ខាត់ថា ពូ ប៉េង វាយឲ្យហ្មត់។

[១៤:២៣:៤២]

មន្ទីរស-២១ ជាមន្ទីរសន្តិសុខរបស់កម្ពុជាប្រជាធិបតេយ្យដ៏ធំបំផុតផងដែរ បើនិយាយពីចំនួនបុគ្គលិកដែលមានរហូតទៅដល់ជាង ២.៣២៧នាក់ ដែលគ្មានមន្ទីរសន្តិសុខ ឬគុកណាមួយនៅទូទាំងប្រទេសមានបុគ្គលិកយ៉ាងច្រើនសម្បើមបែបនេះទេ។

ចំណុចទីប្រាំ ដែលជាលក្ខណៈពិសេសដែរ គឺមន្ទីរស-២១ បានទទួលអ្នកទោសឈ្លើយសឹកវៀតណាម និងជនស៊ីវិលវៀតណាម អ្នកទោសជាជនបរស្ទិមប្រទេសដែលចាប់បាន។ ឧទាហរណ៍ ជនបរស្ទិមប្រទេសបីនាក់ ដែលបានចាប់មកពីសមុទ្រកំពង់សោម ហើយត្រូវបញ្ជូនត្រង់មកស-២១ ដែរ គឺមិនមែនបញ្ជូនទៅតំបន់ ឬគុកស្វយ័តកំពង់សោមជាមុននោះទេ។

[០៩:២៤:២៩]

ដូចនេះ វាច្បាស់ណាស់ថា មន្ទីរស-២១ ពិតជាមានសិទ្ធិអំណាចធំជាងមន្ទីរសន្តិសុខដទៃទៀត និងលាតសន្ធឹងទូទាំងប្រទេស។

ដូចតាមការរៀបរាប់ និងការឃើញនូវចំណុចពិសេសៗរបស់មន្ទីរសន្តិសុខស-២១ ដែលបានរៀបរាប់អំម្បាញ់មិញនេះ សហព្រះរាជអាជ្ញា មេធាវីការពារក្តីខកខានមិនបង្ហាញ ឬមិនបានរកឃើញចំណុចពិសេសរបស់មន្ទីរសន្តិសុខចុងជ្រោយ ដូចសហព្រះរាជអាជ្ញាបានរកឃើញចំណុចពិសេសរបស់មន្ទីរសន្តិសុខស-២១ នោះទេ។ ការណ៍ដែលមេធាវីការពារក្តីលើកឡើង នៅក្នុងកថាខណ្ឌ៤៣ នៃការ

ឆ្លើយតបរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច នោះ ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញានៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០ ថាប្រសិនបើ កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតដែលបានកើតឡើងនៅក្នុងក្របខ័ណ្ឌមន្ទីរសន្តិសុខស-២១ ក៏ត្រូវចោទប្រកាន់ប្រធានមន្ទីរសន្តិសុខផ្សេងៗទៀតដែរ។

[១៤:២៥:៣៨]

ផ្ទុយទៅវិញ ប្រសិនបើដូចការយល់ឃើញរបស់សហព្រះរាជអាជ្ញាថា គ្មានយុត្តាធិការបុគ្គលលើប្រធានសន្តិសុខនានាទូទាំងប្រទេស ទាំង១៩៥ នោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាប្រធានមន្ទីរសន្តិសុខក៏គ្មានដែរ។

ត្រង់ចំណុចនេះ ដូចបានលើកដោយមេធាវីការពារក្តីខាងលើ សហព្រះរាជអាជ្ញាសូមបញ្ជាក់ជូនមេធាវីការពារក្តីជាតិទាំងពីររូបថា លោកមេធាវីបានលើកយកឯកសារដែលមានចំណងជើងថា "គុកខ្មែរក្រហម"។ ផេង ពង្សរ៉ាស៊ី បានពិពណ៌នាអំពីទីតាំងមន្ទីរសន្តិសុខទាំងអស់នៅក្នុងប្រទេស ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេសបានដកស្រង់យកមន្ទីរសន្តិសុខចុងជ្រោយមកប្រៀបធៀបជានឹងមន្ទីរសន្តិសុខស-២១ ដើម្បីភ្ជាប់យុត្តាធិការបុគ្គលដែរនោះ។ ប៉ុន្តែ មេធាវីការពារក្តីមិនបានសិក្សាវិភាគអំពីរចនាសម្ព័ន្ធឋានានុក្រម ថាតើមន្ទីរសន្តិសុខចុងជ្រោយស្ថិតនៅក្នុងឋានានុក្រមថ្នាក់ណានៃរចនាសម្ព័ន្ធមន្ទីរសន្តិសុខ មុននឹងទាញយកសេចក្តីសន្និដ្ឋានអំពីយុត្តាធិការបុគ្គល ឌុច ដែលជាប្រធានមន្ទីរសន្តិសុខស-២១ ជាមួយនឹងប្រធានមន្ទីរសន្តិសុខចុងជ្រោយ។

[០៩:២៦:៥៨]

យោងតាមឯកសារដែលមានចំណងជើងថា "ខ្សែចង្វាក់នៃការភ័យខ្លាច" ដែលរៀបរាងដោយ អៀ ម៉េងទ្រី បានបញ្ជាក់អំពីរចនាសម្ព័ន្ធមន្ទីរសន្តិសុខក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានមន្ទីរសន្តិសុខប្រាំប្រភេទនៅក្នុងថ្នាក់នោះ។ គឺថ្នាក់ទាបជាងគេ គឺហៅថាមន្ទីរឃុំបឃុំ បន្ទាប់មកមាននៅស្រុក គឺនិងតំបន់ គឺមានមន្ទីរសន្តិសុខស្រុកនិងតំបន់ រីឯនៅក្នុងភូមិភាគ មានមន្ទីរសន្តិសុខភូមិភាគ និងនៅថ្នាក់ខ្ពស់ជាងគេបង្អស់ គឺមន្ទីរសន្តិសុខស-២១ ដែលជាមន្ទីរសន្តិសុខស្ថិតនៅក្នុងថ្នាក់មជ្ឈិម។

[១៤:២៧:៤៥]

ចំពោះមន្ទីរសន្តិសុខចុងជ្រោយ ដែលលោកមេធាវីការពារក្តីបានលើកឡើងជាមន្ទីរសន្តិសុខថ្នាក់ស្រុកស្ថិតនៅក្នុងស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង តំបន់៣១ ភូមិភាគបស្ចិម។ ឯកសារដែលពាក់ព័ន្ធនឹង

មន្ទីរសន្តិសុខចុងជ្រោយ ដែលសហមេធាវីបានលើកឡើង គឺនៅក្នុងពាក្យស្នើសុំភស្តុតាងថ្មី ហើយសម្រេចដោយអង្គជំនុំជម្រះតុលាការកំពូលថាជាភស្តុតាងថ្មីនោះ សហព្រះរាជអាជ្ញានៅតែថាជាភស្តុតាងដែលមាននៅក្នុងសំណុំរឿងរួចហើយ ពីព្រោះឯកសារនេះ សហព្រះរាជអាជ្ញាធ្លាប់បានឃើញកន្លងមកជាមួយគ្នាហ្នឹងដែរ។ ហើយមន្ទីរសន្តិសុខចុងជ្រោយនេះ សហមេធាវីបានលើកឡើងមិនអាចយកជាឧបកិច្ចថាពិរុទ្ធជន កាំង ហ្គេកអ៊ាវ ហៅ ឌុច ប្រាសចាកពីយុត្តាធិការរបស់ អ.វ.ត.ក ដែលមានចែងនៅក្នុងមាត្រា១ នៃច្បាប់ អ.វ.ត.ក បានឡើយ។

[១៤:២៨:៤៣]

ឯកសារទីពីរ ពាក់ព័ន្ធនឹងឯកសារអំពីប្រវត្តិរូប ៣១នាក់។ ចំពោះឯកសារស្តីពីប្រវត្តិរូបនេះ ឌុច ដែលសហមេធាវីបានស្នើឡើងនៅក្នុងសំណុំរឿងបន្ថែមភស្តុតាងថ្មី ហើយត្រូវបានអង្គជំនុំជម្រះតុលាការកំពូលទទួលយកនេះ សហព្រះរាជអាជ្ញានៅតែប្រកាន់ជំហរដដែលថា ជាភស្តុតាងដែលមានក្នុងសំណុំរឿង។ ពីព្រោះឯកសារភស្តុតាងចំនួនបីទំព័របែបហ្នឹង ពិតជាគ្មាននៅក្នុងសំណុំរឿងប្រាកដមែន ហើយសហព្រះរាជអាជ្ញាមិនមានអ្វីភ្ញាក់ផ្អើលនោះទេ ចំពោះឯកសារភស្តុតាងចំនួនបីទំព័របែបនេះ។

[១៤:២៩:១៧]

ដោយហេតុថា សហព្រះរាជអាជ្ញាធ្លាប់បានដឹងរួចហើយអំពីខ្លឹមសារ ដែរថាជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាប្រធានមន្ទីរសន្តិសុខស-២១ រៀបចំចម្លើយសារភាពឲ្យមានការពាក់ព័ន្ធ ចក្រី, ឈ្មួក, លី ផែន ដើម្បីធ្វើការបោសសម្អាត។ ថ្នាក់លើមាន ប៉ុល ពត និង នួន ជា និង សុន សេន។ ថ្នាក់ក្រោមបង្គាប់មាន ហ៊ី, ម៉ម ណៃ ហៅ ចាន់, ប៊ុន សម្លាប់ កុយ ធួន, វន វ៉េត, ហ៊ូ នឹម និងចំណារថាវាយចោលឲ្យហ្មត់។ ដូចមាននៅក្នុងកំណត់ហេតុយកចម្លើយ ឌុច នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត និងការពិភាក្សាដេញដោលនៅចំពោះអង្គជំនុំជម្រះសាលាដំបូងរួចហើយដែរ។

[០៩:៣០:១០]

នៅចុងក្រោយនេះ សហព្រះរាជអាជ្ញាសូមធ្វើការកត់សម្គាល់នូវអ្វីដែលមេធាវីការពារក្តី ឌុច ដែលបានលើកឡើងនៅសវនាការសាលាដំបូងជូនអង្គជំនុំជម្រះតុលាការកំពូលឲ្យបានជ្រាបថា៖

នៅដំណាក់កាលសវនាការនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ ហ្នឹងគឺនៅពេលដែលសហព្រះរាជអាជ្ញាសួរថា តើលោកមេធាវីការពារក្តីប្រឆាំងនឹងយុត្តាធិការដែរឬទេ? លោកមេធាវីការពារក្តីបានឆ្លើយថា “អត់ប្រឆាំងទេ។ បើលើក ខ្ញុំលើកតាំងពីសវនាការបឋម” ខ្ញុំលើកនេះ គឺគ្រាន់តែចង់ឲ្យតុលាការ

ពិចារណា ហើយជាចុងក្រោយលោកមេធាវីបញ្ជាក់ថា "មិនប្រឆាំងនឹងយុត្តាធិការទេ"។

[១៤:៣០:៥៩]

នៅពេលនេះ គឺនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល លោកមេធាវីមានចេតនាលើកឡើងវិញនូវយុត្តាធិការបុគ្គល ដោយសំអាងថា ឌុច មិនស្ថិតនៅក្នុងក្រោមយុត្តាធិការរបស់ អ.វ.ត.ក ទេ ហើយស្នើសុំឲ្យដោះលែងជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច។ ការលើកឡើងដូច្នេះ មានភាពផ្ទុយគ្នារវាងខ្លឹមសារនៃមាត្រា៨៩ និងមាត្រា៨៧ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដែលមានខ្លឹមសារនៃវិធាន ៨៩ មានចែងថា "អញ្ញត្រកម្មដែលទាក់ទងនឹងយុត្តាធិការ ការរំលត់បណ្តឹងអាជ្ញា និងមោឃភាពនីតិវិធី ត្រូវលើកឡើងនៅពេលសវនាការបឋម។ បើមិនដូច្នេះទេ មិនអាចទទួលយកបានឡើយ"។

ភស្តុតាងបន្ថែម ដែលភស្តុតាងបន្ថែមនេះ ត្រូវបានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងការសំអាងហេតុផលជាក់លាក់ដែលអង្គជំនុំជម្រះសាលាដំបូងបានលើក។ ដូច្នេះ ចំពោះភស្តុតាងបន្ថែមដែលសហមេធាវីការពារក្តី ឌុច បានដាក់នូវអង្គជំនុំជម្រះសាលាដំបូង ដែលមិនបានលើកយកមកពិភាក្សានោះ គឺមានតែខ្លឹមសារនៃភស្តុតាងបន្ថែមរបស់សហមេធាវីការពារក្តី ដែលមាននៅក្នុងសំណុំរឿងអស់ហើយ។

[១៤:៣២:២២]

ហើយភស្តុតាងបន្ថែម ដែលមេធាវីការពារក្តីបានលើកឡើងនេះ សហព្រះរាជអាជ្ញានឹងស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលមេត្តាបដិសេធចោល ហើយសុំអង្គជំនុំជម្រះតុលាការកំពូលសម្រេច យុត្តា-ធិការបុគ្គលជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច គឺស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដែលមានចែងនៅក្នុងមាត្រា០១ នៃច្បាប់ អ.វ.ត.ក។

ជាមួយគ្នាហ្នឹងដែរ ខ្ញុំសូមបង្ហាញអង្គជំនុំជម្រះតុលាការកំពូល អ្វីដែលការកត់សម្គាល់របស់សហព្រះរាជអាជ្ញាពេលនេះ គឺវាពាក់ព័ន្ធទៅនឹងប្រតិចារឹក នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ ត្រង់ទំព័រ ១៣ និង១៤ គឺមេធាវីការពារក្តីគាត់បានឆ្លើយយ៉ាងច្បាស់នៅក្នុងប្រតិចារឹក គឺគាត់មិនតវ៉ាអំពីយុត្តាធិការបុគ្គលទេ។ គឺគាត់តវ៉ាតែក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ តែប៉ុណ្ណោះ។ នេះជាប្រតិចារឹកដែលតុលាការបានកត់ត្រានូវសវនាការនៅដំណាក់កាលដំបូង។

[១៤:៣៣:១៩]

ជាចុងក្រោយ ដោយមេធាវីការពារក្តី ឌុច បានបកស្រាយថា ឌុច មិនចូលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ហើយមន្ទីរសន្តិសុខស-២១ មានឋានានុក្រមស្មើនឹងមន្ទីរសន្តិសុខទូទាំងប្រទេសនោះ

ជាពិសេស មន្ទីរសន្តិសុខចុងជ្រោយ ដែលមេធាវីបានលើកឡើង ដែលជាហេតុនាំឲ្យមានការដោះលែង ឌុច។ ការបកស្រាយរបស់សហមេធាវីការពារក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច សហព្រះរាជអាជ្ញាមិនអាចទទួលយកបានឡើយ ហើយសូមឲ្យអង្គជំនុំជម្រះតុលាការកំពូលមេត្តាបដិសេធបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីចោលជាអសារបង់។

ចា៎ស, សូមអរគុណ។

[១៤:៣៤:០៥]

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញាអន្តរជាតិមានអ្វីបន្ថែមទៀតទេ? បើមានសូមអញ្ជើញ!

**លោក អាន់ឌ្រូ ខេលី៖**

បាទ, អត់មានទេលោកប្រធាននៅពេលនេះ។

**ប្រធានអង្គជំនុំ៖**

បើអត់មានសំណួរទេ ហើយអត់មានអ្វីបន្ថែមទេ សូមចៅក្រមរបាយការណ៍អាចមានសំណួរសួរទៅខាងព្រះរាជអាជ្ញា។ សូមអញ្ជើញ!

**ចៅក្រម ចាន់ដ្រា ចាយ៉ាស៊ីញហ៍៖**

ខ្ញុំសូមឲ្យលោក លោកស្រីជួយបន្តិចទៅលើករណីនេះ ដែលវាពាក់ព័ន្ធទៅនឹងការលើកឡើងរបស់មេធាវីការពារក្តី។

មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃរបបនោះគួរតែមានការជាប់ពាក់ព័ន្ធគ្នា។ បានន័យថា វាមិនអាចបែងចែកដាច់ដោយឡែកពីចេញពីគ្នានោះទេ។ មូលដ្ឋានរបស់មេធាវីការពារក្តីបានលើកឡើងថា ដើមបណ្តឹងសាទុក្ខមិនមែនជាជនម្នាក់ក្នុងចំណោមជនដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ។ ដូច្នេះ សូមឲ្យលោក អាន់ឌ្រូ ខេលី ឬក៏ លោកស្រី ជា លាង បញ្ជាក់ ជួយបញ្ជាក់ទៅលើចំណុចហ្នឹងបានដែរឬទេ?

[១៤:៣៦:០៤]

**លោកស្រី ជា លាង៖**

សូមអរគុណ។ ហើយសំណួរដែលលោកចៅក្រមបានលើកឡើងនេះ ជាសំណួរមួយដែលគិតថា វាមានសារៈសំខាន់ចំពោះយុត្តាធិការបុគ្គល។ សហព្រះរាជអាជ្ញាសូមធ្វើការឆ្លើយនឹងសំណួរនេះគឺ៖

ទីមួយ ដោយសហព្រះរាជអាជ្ញាយល់ឃើញថា នៅក្នុងមាត្រា០១ នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាហ្នឹង បានកាត់ក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈពេលកម្ពុជាប្រជាធិបតេយ្យដែលបានកំណត់ច្បាប់យ៉ាង-- មានគោលបំណងវិនិច្ឆ័យទោសមនុស្សពីរក្រុម គឺថាមនុស្សមួយក្រុម គឺជាមេដឹកនាំជាន់ខ្ពស់ និងមួយក្រុមទៀតជាអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត។

[១៤:៣៦:៥០]

ដូច្នេះ សហព្រះរាជអាជ្ញាយល់ឃើញថា ក្នុងករណីនេះ នៅក្នុងសំណុំរឿងនេះ សហព្រះរាជអាជ្ញាសូមផ្តោតយកតែមួយក្រុមទេគឺ "ក្រុមអ្នកទទួលខ្ពស់បំផុត" មកបកស្រាយ ហើយនិងប្រើទៅលើឆន្ទានុសិទ្ធិរបស់សហព្រះរាជអាជ្ញាក្នុងការចោទប្រកាន់ ហើយក៏វាមានការពាក់ព័ន្ធទៅនឹងច្បាប់ជាតិដែរ ដែលមានចែងនៅក្នុងមាត្រា៤០។ ដូច្នេះ សហព្រះរាជអាជ្ញាសុំប្រើនូវឆន្ទានុសិទ្ធិនេះ ដោយផ្អែកទៅលើអង្គហេតុ និងអង្គច្បាប់ដែលនៅជាធរមាន។

[១៤:៣៧:២៨]

តាមនីតិវិធីច្បាប់ សហព្រះរាជអាជ្ញាហ្នឹងអាចវាយតំលៃទៅលើភស្តុតាងដែលប្រមូលបាននៅដំណាក់កាលស៊ើបអង្កេតបឋម ហើយដើម្បីចង្អុលជនសង្ស័យ និងសម្រាប់ឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការស៊ើបអង្កេត។ ដូច្នេះ សហព្រះរាជអាជ្ញាហ្នឹងក្រោយពីការប្រមូលនូវភស្តុតាងនានា សហព្រះរាជអាជ្ញាបានកំណត់នូវគោលដៅមួយដែលគិតថា ជនសង្ស័យ ឬក៏ជនជាប់ចោទ ឌុច នេះស្ថិតនៅក្នុងឋានៈមួយថា "ជាអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត" ដោយផ្អែកទៅលើអង្គហេតុ និងអង្គច្បាប់ ដែលនៅជាធរមាននេះ។

[១៤:៣៨:០៣]

ដូច្នេះ ខ្ញុំសូមធ្វើការពាក់ព័ន្ធអំពីឆន្ទានុសិទ្ធិនេះ ហើយនិងការ-- ហេតុ មូលហេតុដែលធ្វើឲ្យសហចៅក្រមស៊ើបអង្កេត ក៏ដូចជាសហព្រះរាជអាជ្ញា ក៏ដូចជាអង្គជំនុំជម្រះសាលាដំបូងមានការឯកភាពគ្នាទៅលើលក្ខណៈពិសេស ឬយ៉ាងដូចម្តេចក្នុងការប្រើឆន្ទានុសិទ្ធិក្នុងការចោទប្រកាន់ ឌុច ទៅលើជនសង្ស័យនេះ។ បើសិនជាចៅក្រមអាចឲ្យខ្ញុំបកស្រាយបាន ខ្ញុំនឹងត្រូវការពេលប្រហែលជាអាចប្រាំបីនាទីដែលខ្ញុំអាចបកស្រាយជូនអំពីបញ្ហានេះលម្អិត។ សូមអរគុណ។

**ចៅក្រម ចាន់ដ្រា ចាយ៉ាស៊ីញហ៍៖**

ខ្ញុំសូមសួរខាងសហព្រះរាជអាជ្ញាឡើងវិញថា តើសេចក្តីច្បាប់និងកិច្ចព្រមព្រៀងនៃ អ.វ.ត.ក

បានថែងអំពីការចោទប្រកាន់ទៅលើមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ ដែលគាត់ពាក់ព័ន្ធទៅនឹងពិរុទ្ធភាព។ ដូច្នេះ ប្រសិនបើខាងសហព្រះរាជអាជ្ញាលើកឡើងថា "មេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត" នេះគឺវាទាល់តែប្រភេទហ្នឹងរួមគ្នា ឬក៏យ៉ាងម៉េច? ហើយថាតើការទទួលខុសត្រូវពាក់ព័ន្ធទៅនឹងពិរុទ្ធភាពនេះ គឺវាពាក់ព័ន្ធទៅនឹងប្រភេទនេះតែមួយ ឬក៏យ៉ាងណានៅក្នុងឆ្នាំ១៩៧៥ នោះ?

[១៤:៣៩:៥០]

**លោកស្រី ជា លាង៖**

អឺ! ខ្ញុំអំមិញនេះដោយសារខ្ញុំមានការឆ្លើយ វាមានពាក់ព័ន្ធទៅនឹងការបកស្រាយទៅលើអ្វីដែលសហព្រះរាជអាជ្ញាមានការ បំណងក្នុងការបកស្រាយទៅលើសំណួរដែលចៅក្រមបានសួរនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១១ នេះ។ ដូច្នេះ អ្វីដែលខ្ញុំគិតថានៅពេលនេះ គឺសហព្រះរាជអាជ្ញា គឺថាមិនមានចំណងចាំបាច់ត្រូវតែទាំងពីរនោះទេ។ វាអាចក្នុងមួយផ្នែក ក្រុមទីមួយថា "ជាមេដឹកនាំជាន់ខ្ពស់" ឬក៏បុគ្គលណាមួយស្ថិតនៅក្នុងអ្នកទទួលខុសត្រូវខ្ពស់បំផុត។ ដូច្នេះ វាមិនអាចទំនាក់ទំនង វាត្រូវតែជាប់គ្នានោះទេ។

[១៤:៤០:៣៩]

ដូច្នេះ ខ្ញុំគិតថា ខ្ញុំនឹងសូមបកស្រាយនូវសំណួរដែលថា "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" តែប៉ុណ្ណោះនៅក្នុងករណីនេះ ហើយបង្ហាញជូននូវឆន្ទានុសិទ្ធិ និងឯកសារអង្គហេតុជាច្រើនដែលសហព្រះរាជអាជ្ញាបានប្រើដើម្បីចំណាត់ថ្នាក់ ឌុច ឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងក្របខ័ណ្ឌមន្ទីរស-២១។ នៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ហ្នឹង គឺសហព្រះរាជអាជ្ញាបានកំណត់យ៉ាងច្បាស់ហើយថា នូវអ្វីដែលយើងបានពិនិត្យទៅតាមភស្តុតាងនិងច្បាប់ជាធរមាននោះ។ ឌុច ស្ថិតនៅក្នុងអ្នកទទួលខុសត្រូវបំផុត។

[១៤:៤១:២០]

សហព្រះរាជអាជ្ញាប្រើឆន្ទានុសិទ្ធិក្នុងការចោទប្រកាន់នេះ ដោយសារ ឌុច ឋិតក្នុងប្រភេទមួយគោលដៅនៃជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត។ ហើយដោយសារមានអង្គហេតុជាក់លាក់ជាច្រើន នេះខ្ញុំសូមបកស្រាយនូវអ្វីដែលសហព្រះរាជអាជ្ញា និងហេតុផលដែលថាហេតុអ្វីបានយើងចាត់ទុកថា ឌុច ស្ថិតនៅក្នុងអ្នកទទួលខុសត្រូវខ្ពស់បំផុត?

តើលោកចៅក្រមអនុញ្ញាតឲ្យខ្ញុំបកស្រាយអំពីចំណុច និងហេតុផលនៃការចោទប្រកាន់ និងការប្រើឆន្ទានុសិទ្ធិនេះដែរឬអត់?

[១៤:៤១:៥០]

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញ!

**លោកស្រី ជា លាង៖**

ដូច្នេះសហព្រះរាជអាជ្ញាយល់ឃើញថា សហព្រះរាជអាជ្ញាមានហេតុផលជឿថា ឌុច ហ្នឹងពិតជាបានប្រព្រឹត្តនូវបទឧក្រិដ្ឋកម្មជាច្រើននៅក្នុងក្របខ័ណ្ឌនៃមន្ទីរស-២១។

ក្នុងនាមជាប្រធានមន្ទីរសន្តិសុខនេះ នៅក្នុងកំណត់មុខសញ្ញាដើម្បីបើកការស៊ើបសួរ ដោយដីកាបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ផ្អែកទៅលើកត្តាពីរសំខាន់ដែលមិនអាចផ្តាច់ចេញពីគ្នាបាន គឺឆន្ទានុសិទ្ធិក្នុងការចោទប្រកាន់ និងភស្តុតាងជាអង្គហេតុ។

[១៤:៤២:៣៤]

ក្នុងការជ្រើសរើសជនសង្ស័យដាក់ឲ្យបើកការស៊ើបសួរនេះ ជាគោលការណ៍គ្រឹះ សហព្រះរាជអាជ្ញាប្រកាន់ខ្ជាប់នូវស្មារតីនៃមាត្រា១ នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងស្មារតីនៃបុព្វកថានៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ មហាសន្និបាតទទួលស្គាល់ការព្រួយបារម្ភពេញច្បាប់របស់រដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុងការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថិរភាព សន្តិភាព និងសន្តិសុខ។

ការចោទប្រកាន់ ឌុច នៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរនោះ គឺសហព្រះរាជអាជ្ញាបានកំណត់ថាជនសង្ស័យ ឌុច ក្នុងឋានៈជាប្រធានមន្ទីរស-២១ ដែលជាមន្ទីរសន្តិសុខមួយស្ថិតនៅក្នុងថ្នាក់មជ្ឈិម ហើយស្ថិតក្នុងលំដាប់ខ្ពស់ជាងគេបង្អស់ក្នុងលំដាប់ ក្នុងចំណោមរចនាសម្ព័ន្ធសន្តិសុខនានារបស់របបកម្ពុជាប្រជាធិបតេយ្យ។

[១៤:៤៣:៣៤]

ការអនុវត្តឆន្ទានុសិទ្ធិដូចគ្នា ដូចបានរៀបរាប់ខាងលើនេះ សហព្រះរាជអាជ្ញាបានពិចារណាលើអំពីកាលៈទេសៈពិសេស ដែលបទល្មើសត្រូវបានប្រព្រឹត្តនៅទីកន្លែងដែលអង្គជំនុំជម្រះវិសាមញ្ញនេះតាំងនៅ ហើយដែលការចោទប្រកាន់នោះមិនប៉ះពាល់ដល់ស្ថិរភាព និងសន្តិសុខនយោបាយសង្គម។

ជាមួយគ្នាហ្នឹងដែរ សហព្រះរាជអាជ្ញាក៏បានពិចារណាអំពីទស្សនៈរបស់អតីតរដ្ឋអាជ្ញារបស់តុលាការអន្តរជាតិនានា ដូចជាតុលាការពិសេសនៅសម្រាប់ប្រទេស សៀរ៉ាឡេអូន បានទទួលស្គាល់

ច្បាស់ណាស់ថា នូវភាពចាំបាច់ក្នុងការពិចារណាដល់វិសាលភាពនៃការចោទប្រកាន់ដែលពាក់ព័ន្ធនឹងស្ថិរភាព និងសន្តិសុខនយោបាយ ហើយការចោទប្រកាន់មិនត្រូវឲ្យប៉ះពាល់ដល់ការបង្រួបបង្រួមជាតិសន្តិភាពក្នុងប្រទេសឡើយ។

[១៤:៤៤:៣១]

ក្រៅពីការសម្រេចបើកការឲ្យស៊ើបសួរ តាមរយៈដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ដោយពិចារណាលើបុព្វកថានៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនៃព្រះរាជាណាចក្រកម្ពុជាជាមួយនឹងអង្គការសហប្រជាជាតិនោះ (សូមទោស) រដ្ឋាភិបាលកម្ពុជាជាមួយនឹងអង្គការសហប្រជាជាតិនោះ សហព្រះរាជអាជ្ញាក៏បានពិចារណាផងដែរថា អំពីខ្លឹមសារនៃមាត្រា១ នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលនៅក្នុងមាត្រា១ នៃច្បាប់នេះមិនបានតម្រូវឲ្យសហព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ជនសង្ស័យទាំងអស់នោះទេ។ ជាពិសេស នៅក្នុងករណីដែលលើកឡើងដោយសហមេធាវី គឺមន្ទីរសន្តិសុខទាំងអស់នៅក្នុងមន្ទីរសន្តិសុខ ១៩៥ នោះ។ ប្រសិនបើមានយុត្តាធិការលើប្រធានសន្តិសុខមន្ទីរស-២១ ក៏ត្រូវមានយុត្តាធិការទៅលើប្រធានមន្ទីរសន្តិសុខទាំងអស់នោះដែរ។ ការលើកឡើងនេះជាការមិនត្រឹមត្រូវទេ ព្រោះថាមន្ទីរសន្តិសុខដែលសហមេធាវីការពារក្តី បានលើកនោះ ដូចជាមន្ទីរសន្តិសុខចុងជ្រោយ ដែលស្ថិតក្នុងស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំងហ្នឹង ហើយនៅស្ថិតក្នុងភូមិភាគបស្ចិម ត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អចិន្ត្រៃយ៍ភូមិភាគ ដោយយោងតាមសេចក្តីសម្រេចរបស់មជ្ឈិមបក្ស ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦។ ហើយផ្ទុយទៅវិញ មន្ទីរសន្តិសុខស-២១ ជាមន្ទីរសន្តិសុខមួយដែលស្ថិតនៅក្នុងជុំវិញមន្ទីរមជ្ឈិម ហើយត្រូវគណៈ មជ្ឈិមជាអ្នកទទួលខុសត្រូវយោងតាមសេចក្តីសម្រេចរបស់គណៈមជ្ឈិមខាងលើ។

[១៤:៤៦:០៧]

ដូច្នេះ យុត្តាធិការ ឌុច ត្រូវស្ថិតនៅក្រោមច្បាប់ អ.វ.ត.ក យ៉ាងពិតប្រាកដ មិនអាចប្រកែកបានឡើយ។ ចំណុចមួយដែរ គឺការសម្រេចយក ឌុច ឲ្យស្ថិតនៅក្រោមយុត្តាធិការនៃច្បាប់ អ.វ.ត.ក សហព្រះរាជអាជ្ញាមិនគ្រាន់តែផ្អែកទៅលើយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិទេ។ ដូចជានៅតុលាការនៅ-- តែមិនផ្អែកតែទៅលើយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិនៅ សៀរ៉ាឡេអូន ប៉ុណ្ណោះទេ គឺសហព្រះរាជអាជ្ញាផ្អែកទៅលើលក្ខណៈពិសេសៗ ដូចមួយចំនួនទៀត នៅមន្ទីរសន្តិសុខស-២១ ហ្នឹងដូចជានូវអំពីតួនាទី អំពីសិទ្ធិអំណាចជាក់ស្តែងរបស់ជនជាប់ចោទ ឌុច ហើយដំណើរការនៃការប្រតិបត្តិប្រកប

ដោយប្រសិទ្ធភាពរបស់ជនជាប់ចោទ និងមានផ្អែកជាច្រើនជាពិសេសផ្នែកសួរចម្លើយ និងសម្លាប់ និងឯកសារភស្តុតាងបន្សល់ទុកជាច្រើន។ ជាពិសេសផ្នែកសួរចម្លើយ និងសម្លាប់ ដែលឯកសារនេះ មាននៅសហព្រះរាជអាជ្ញាបានដាក់ចូលនៅក្នុងសំណុំរឿងហើយ។ ប៉ុន្តែផ្ទុយទៅវិញ សហមេធាវីការពារក្តីមិនបានរកឃើញនូវឯកសារភស្តុតាងជាក់លាក់ណាមួយដែលបន្សល់ទុកអំពីមន្ទីរសន្តិសុខចុងក្រោយនោះទេ។

[១៤:៤៧:២២]

មួយទៀត គោលការណ៍នៃការចោទប្រកាន់ដោយប្រើឆន្ទានុសិទ្ធិនេះ របស់សហព្រះរាជអាជ្ញាក្រៅពីស្មារតីនៃច្បាប់ អ.វ.ត.ក បុព្វកថានៃកិច្ចព្រមព្រៀង និងអនុសាសន៍ទាក់ទងនឹងការពិចារណារបស់អតីតរដ្ឋអាជ្ញារបស់តុលាការអន្តរជាតិ សៀរ៉ាឡេអូន ក៏មានគោលការណ៍មួយស្រដៀងគ្នានេះដែរ ដែលផ្តល់អំណាចដល់សហព្រះរាជអាជ្ញា ឬក៏ព្រះរាជអាជ្ញាក្នុងការសម្រេចចោទប្រកាន់ ឬមិនចោទប្រកាន់។ ដូចដែលមានចែងនៅក្នុងមាត្រា៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលចែងយ៉ាងច្បាស់អំពីសិទ្ធិនៃការចោទប្រកាន់ មិនចោទប្រកាន់ នៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា។

[១៤:៤៨:០៩]

អំពីយុត្តាធិការ ឌុច ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ អ.វ.ត.ក នោះ ក៏មានការយល់ស្របគ្នារវាងសហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត ហើយនិងអង្គជំនុំជម្រះសាលាដំបូងដែរ។ ដោយសារបន្ទាប់ពីព្រះរាជអាជ្ញាបានធ្វើការបើកស៊ើបអង្កេតបឋមមក សហព្រះរាជអាជ្ញាបានសម្រេចជ្រើសរើសយកជនសង្ស័យចំនួនប្រាំរូប តាមរយៈដីកាបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ហើយចំពោះអង្គហេតុដូចដែលមានចែងក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ។ ក្រោយពីបានស៊ើបសួរអស់រយៈពេលមួយឆ្នាំ ជាងមួយឆ្នាំ នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ ហ្នឹង សហចៅក្រមស៊ើបអង្កេតហ្នឹង បានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយបានចាត់ទុកថា ទោះបីជា ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏ ឌុច ហ្នឹងអាចចាត់ទុកជា ចូលជាប្រភេទនៃអ្នកទទួលខុសត្រូវខ្ពស់បំផុតដែរនៃឧក្រិដ្ឋកម្មដែលបានកើតឡើង។ ដោយសារ ឌុច ហ្នឹងមានសិទ្ធិ ដោយការអះអាងរបស់សហចៅក្រមស៊ើបអង្កេត ឌុច មានសិទ្ធិនិងអំណាចជាក់ស្តែងប្រកបដោយប្រសិទ្ធភាព ក្នុងនាមជាអនុប្រធាន ហើយក្រោយមកក៏ជាប្រធាននៃមន្ទីរសន្តិសុខស-២១។ ហើយមន្ទីរនេះ ត្រូវគ្រប់គ្រងផ្ទាល់ដោយគណៈកម្មាការ

មជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជា។

[១៤:៤៩:២៩]

ដូចគ្នាដែរ ក៏អង្គជំនុំជម្រះសាលាដំបូងក៏យល់ស្របជាមួយនឹងការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេត ដោយយល់ឃើញថា ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច គឺស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ជាលក្ខណៈបុគ្គល ក្នុងឋានៈជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងអំឡុងឆ្នាំ៧៥ ដល់ ឆ្នាំ៧៩។ ការយល់ឃើញ និងការសម្រេចរបស់សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះសាលាដំបូងហ្នឹង ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច ជាអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត ហើយស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក។

[១៤:៥០:០៧]

នេះជាការសម្រេចមួយស្របទៅនឹងឆន្ទានុសិទ្ធិ ដែលការសម្រេចនេះមិនជាប់កាតព្វកិច្ចជានឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញាទេ។ នេះជាហេតុផល អង្គហេតុជាក់ស្តែង និងអង្គច្បាប់ដែលសហព្រះរាជអាជ្ញាជ្រើសរើស និងកំណត់ថា ឌុច ស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក រួមទាំងការពន្យល់អំពីអង្គហេតុជាក់ស្តែងជាមួយគ្នានឹងដែរ។ ចាស, សូមអស់ប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញ សូមលោកចៅក្រម ណូហ្គូជិ មានសំណួរ សូមអញ្ជើញ!

**ចៅក្រម ម៉ូតូ ណូហ្គូជិ៖**

ខ្ញុំមានសំណួរមួយសួរទៅកាន់ខាងសហព្រះរាជអាជ្ញា។ ភាគីទាំងពីរបានលើកឡើងដេញដោលពិភាក្សាអំពីមាត្រា២ នៃច្បាប់ស្តីអំពីការបង្កើត អ.វ.ត.ក។ ពាក់ព័ន្ធទៅនឹងមេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត។ ដូច្នេះ ខ្ញុំសូមសួរទៅខាងសហព្រះរាជអាជ្ញា អំពីការយល់ឃើញរបស់ខ្លួន ទាក់ទងទៅនឹងពាក្យទាំងនេះ។ ថាតើវាជាលក្ខខណ្ឌយុត្តាធិការដែរឬទេ ដែលតម្រូវឲ្យមានការពិនិត្យយុត្តាធិការនេះឡើងវិញ? ឬក៏វាពាក្យពេចន៍ទាំងអស់នោះគឺគ្រាន់តែជាបទដ្ឋានពាក្យណែនាំ ឬក៏បទដ្ឋានណែនាំមួយក្នុងការប្រើឆន្ទានុសិទ្ធិរបស់សហព្រះរាជអាជ្ញាក្នុងការចោទប្រកាន់តែប៉ុណ្ណោះ?

សូមអរគុណ។

**លោកស្រី ជា លាង៖**

សូមអរគុណលោកចៅក្រម ហើយខ្ញុំនឹងឆ្លើយនូវមាត្រា២ នេះ។ ខ្ញុំគិតថាមិនមែនជាយុត្តាធិការ

ទេ តែជាការមួយដែលយើងពិនិត្យទៅលើសមត្ថកិច្ច ហើយក្នុងការប្រើឆន្ទានុសិទ្ធិក្នុងការជ្រើសរើសក្នុងការចោទប្រកាន់។

**ចៅក្រម គង់ ស្រ៊ឹម៖**

បាទ សូមអញ្ជើញលោកស្រីចៅក្រម មីឡាត។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

លោកស្រី ជា លាង បានឆ្លើយតបនឹងសំណួរខ្ញុំរួចហើយ។

[១៤:៥២:៤៣]

**លោក អាន់ឌ្រូ ខេលី៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតនិយាយដោយសង្ខេប ហើយខ្ញុំសូមត្រឡប់ទៅនឹងសំណួរដែលលើកឡើងដោយលោកចៅក្រម ចាយ៉ាស៊ីញហ៍ ថាតើឃ្លោងឃ្លាមេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយដែលទទួលខុសត្រូវបំផុតនោះ គឺវាពាក្យជាប់គ្នា ឬក៏ដាច់ដោយឡែកពីគ្នា? ខ្ញុំសូមឆ្លើយដោយសង្ខេប ហើយខ្ញុំគាំទ្រយល់ស្របជាមួយនឹងខាងសហព្រះរាជអាជ្ញាជាតិ។ ប្រសិនបើខ្ញុំអាចចង្អុលយោងទៅលើកថាខណ្ឌ ២៧ និងកថាខណ្ឌ២៨ នៅក្នុងសេចក្តីការសន្និដ្ឋានរបស់យើងទៅនឹងបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តី។ នៅក្នុងគំនិតរបស់អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា គឺយើងឃើញថាប្រសិនបើយើងមើលកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ហើយនិងច្បាប់ដែលអនុម័តដោយរដ្ឋាភិបាលកម្ពុជា ដាច់ដោយឡែកពីគ្នានោះទេ យើងនឹងយល់ឃើញថា ក្រុមអ្នកជំនាញរបស់អង្គការសហប្រជាជាតិមុនពេលកិច្ចព្រមព្រៀងមុនឆ្នាំ១៩៩៩ បានបញ្ជាក់យ៉ាងច្បាស់ថា មានជនពីរប្រភេទដែលត្រូវតែធ្វើការចោទប្រកាន់។ ទីមួយគឺ ដែលជាមេដឹកនាំជាន់ខ្ពស់ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតទៅលើការរំលោភឲ្យមានអំពីឃោរឃៅនេះ។

[១៤:៥៤:១៩]

យើងមានការដេញដោលនៅក្នុងសភាជាតិកម្ពុជា ឧបនាយករដ្ឋមន្ត្រី សុខ អាន បានពន្យល់អំពីមាត្រា២ នៃសេចក្តីស្នើច្បាប់ក្រោយពីមានការពិភាក្សាគ្នារវាងអង្គសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា អនុញ្ញាតឲ្យសហព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ជនពីរប្រភេទ។ ទីមួយគឺ អ្នកមេដឹកនាំជាន់ខ្ពស់ ដែលមានតួនាទី ហើយប្រភេទទីពីរ អ្នកមិនមែនជាមេដឹកនាំជាន់ខ្ពស់ទេ ប៉ុន្តែប្រព្រឹត្តឧក្រិដ្ឋកម្ម ហើយចាត់ទុកថាជាជនដែលទទួលខុសត្រូវខ្ពស់បំផុត។

ដូច្នេះ ខ្ញុំគិតថា លោក លោកស្រីចៅក្រម នឹងពិចារណាទៅលើបញ្ហានេះ ដូចអ្វីដែលខ្ញុំបានបញ្ជាក់ និងលើកឡើងអម្បាញ់មិញ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, យើងអត់មានសំណួរបន្តទៅទៀតទេ។ អ៊ីចឹងសូមសម្រាកសិន។ យើងសម្រាកកន្លះម៉ោង គឺម៉ោងបីសាមសិប យើងចូលវិញ។ ហើយសូមខាងមន្ត្រីពន្ធនាគារអញ្ជើញជនជាប់ចោទទៅសម្រាកសិន ហើយម៉ោងបីសាមសិប សឹមចូលមកវិញ។

*(សវនាការសម្រាកពីម៉ោង ១៤:៥៦ នាទី ដល់ម៉ោង ១៥:២៩ នាទី)*

[១៥:២៨:៣៥]

**លោក ផន ធឿន៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញអង្គុយចុះ!

តុលាការប្រកាសបន្តសវនាការ។ សូមអញ្ជើញសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី ធ្វើសេចក្តីថ្លែង។

**លោក គឹម ម៉េងឃី៖**

សូមអរគុណ។ ខ្ញុំបាទមេធាវី គឹម ម៉េងឃី សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី ដែលជាក្រុមនៃមេធាវីគ្មានព្រំដែនប្រទេសបារាំង និងលោកស្រី ម៉ាទីន ហ្សាកកាំង ដែលជាសហភាគារបស់ខ្ញុំ សូមដាក់ជូននូវចម្លើយតបទៅនឹងមេធាវីការពារក្តី ដែលលើកឡើងអំពីយុត្តាធិការបុគ្គលនៃជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច។

ក្រោយពីបានស្តាប់សារណារបស់មេធាវីការពារក្តីនិងសហព្រះរាជអាជ្ញា ក្រុមសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា ការលើកឡើងទាំងអម្បាលមាណរបស់សហមេធាវីការពារក្តីពុំមានមូលហេតុច្បាប់ត្រឹមត្រូវឡើយ។ ដោយយល់ឃើញថា ជនរងគ្រោះចូលមកទីនេះ មិនមានគោលបំណងណាមួយ ដើម្បីធ្វើការសងសឹកទេ ក៏ប៉ុន្តែគោលបំណងសំខាន់ គឺចង់បានយុត្តិធម៌ ហើយនិងសំណង។

[១៥:៣០:៣០]

នៅក្នុងចំណុចមួយដែលសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់គឺថា សហមេធាវីការពារក្តីបានលើកឡើងច្រើនលើក ច្រើនសាដដែលៗ ពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ ប្រៀបធៀបជាមួយនឹងអតីតមេគុកដទៃទៀត ដែលលើកឡើងថាមាន១៩៥គុក គឺគាត់ហ្នឹងគឺជាមេគុកមួយដូចមេគុកដទៃទៀត។

ចំណុចទីពីរ គាត់លើកឡើងអំពីច្បាប់ដែលយកមកកាត់ទោស ដែលកំណត់អត្តសញ្ញាណអំពីជនជាប់ចោទជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ដោយគាត់លើកនូវច្បាប់មួយចំនួនដែលនៅក្នុងសារណារបស់គាត់ ហើយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី យល់ឃើញថា ការលើកឡើងច្បាប់មួយចំនួន គឺមិនត្រឹមត្រូវទេ។ ឧទាហរណ៍ដូចជាច្បាប់ស្តីអំពីកិច្ចព្រមព្រៀងក្រុងប៉ារីស ច្បាប់ស្តីអំពីដាក់ខ្មែរក្រហមឲ្យនៅក្រៅច្បាប់ គឺមិនបានកំណត់អំពីសញ្ញាណនៃអ្នកទទួលខុសត្រូវខ្ពស់បំផុតទេ។ ដូច្នេះមានតែច្បាប់ស្តីពីការបង្កើត អ.វ.ត.ក តែប៉ុណ្ណោះ ដែលត្រូវលើកយកមកនិយាយ ហើយនិងយុត្តិសាស្រ្តនៃតុលាការអន្តរជាតិដែលពាក់ព័ន្ធ។

[១៥:៣១:៥៣]

ចំណុចទីពីរ គឺមេធាវីការពារក្តី បានលើកឡើងអំពីអង្គហេតុដែលថាខ្លួនដូចជាមេគុកដទៃទៀត។ ការលើកបែបនេះ គឺគ្មានលក្ខណៈមួយប្រាកដប្រជា ហើយគ្មានភស្តុតាងសំអាងត្រឹមត្រូវឡើយ ដោយមូលហេតុថា ទីមួយ ការលើកថាជនជាប់ចោទ គឺមានឋានៈនៅក្នុងបក្ស គឺត្រឹមតែមេកង ឬក៏ជាអ្នកទទួលខុសត្រូវថ្នាក់ក្រោម។ ទីពីរ គឺថានៅក្នុងរបបខ្មែរក្រហមគ្មានច្បាប់។

ដូច្នេះបើសិនជាយើងមើល ស្តាប់ទៅនឹងការលើកឡើងរបស់មេធាវីការពារក្តី យើងឃើញថា បើសិនជានៅក្នុងសម័យនោះ គ្មានច្បាប់ តើគេយកអ្វីមកអាង? គឺគេប្រើច្បាប់ព្រៃ បានន័យថា អ្នកណាដែលធំ គឺអ្នកនោះជាអ្នកឈ្នះ។ ធម្មតាទេ អ្នកណាដែលខ្លាំង គឺអ្នកនោះជាអ្នកដឹកនាំ។ នេះហើយគឺជាអ្វីដែលមេធាវីការពារក្តីបានលើកឡើង។

[១៥:៣២:៥៥]

ហើយចំណុចមួយទៀត គឺថាមេធាវីការពារក្តីលើកឡើងថា សហព្រះរាជអាជ្ញា បានបញ្ជាក់ថាខ្លួនចាប់នូវកម្មាភិបាលខ្មែរក្រហមមួយមកសម្លាប់ ហើយគុកដទៃទៀតមិនបានធ្វើ ចាត់ទុកថាគាត់ជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ជាការមិនត្រឹមត្រូវ។

សម្រាប់ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា ការដែលចាប់មេកម្មាភិបាលនេះ

ហើយ ដែលជាការកំណត់យ៉ាងត្រឹមត្រូវបំផុត។ ពីព្រោះថា បើច្បាប់ព្រៃ វាមិនដែលមានគោងណាទៅស៊ីខ្លាបានទេ។ វាមានតែខ្លាទេ ដែលអាចស៊ីគោ។ ដូច្នេះ អ្នកដែលខ្លាំងទើបអាចដើរកម្ទេចអ្នកដែលខ្សោយបាន។

ហេតុដូច្នេះ សញ្ញាណនៃអ្នកទទួលខុសត្រូវខ្ពស់បំផុត គឺបានស្ដែងចេញនូវសកម្មភាពរបស់ប្រធាននៃមន្ទីរស-២១នេះឯង គឺតាមរយៈការចាប់នូវមេឃាតកធំៗផ្សេងទៀតយកមកសម្លាប់នៅទីនេះ។ ហើយពាក់ព័ន្ធទៅនឹងបច្ចេកទេសច្បាប់លម្អិតនៅក្នុងការឆ្លើយតបរបស់យើង។ ខ្ញុំសូមទុកឱកាសនេះជូនលោកស្រីមេធាវី ម៉ាទីន ហ្សាកកាំង សូមអរគុណ។

[១៥:៣៤:១១]

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

សូមគោរពឯកឧត្ដមប្រធាន លោក លោកស្រីចៅក្រម លោកជំទាវ និងលោកសហព្រះរាជអាជ្ញា លោកមេធាវីការពារក្ដីជនជាប់ចោទ លោក លោកស្រីមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ ដើម្បីផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបី នាងខ្ញុំមានកិត្តិយសក្នុងការឆ្លើយតបទៅនឹងសំណួររបស់អង្គជំនុំជម្រះ ដែលបានស្នើសុំឲ្យយើងខ្ញុំធ្វើការពន្យល់បន្ថែមអំពីបទប្បញ្ញត្តិដូចខាងក្រោម៖

សហមេធាវីការពារក្ដី សហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបី ត្រូវបានអញ្ជើញឲ្យឆ្លើយសំណួរថា ពាក្យថា តើពាក្យថាមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ និងអ្នកទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ដែលមានចែងនៅក្នុងច្បាប់ អ.វ.ត.ក គឺជាលក្ខខណ្ឌយុត្តាធិការមួយដែលតម្រូវឲ្យមានការពិនិត្យឡើងវិញរបស់តុលាការដែរឬទេ? ឬតើពាក្យនេះ គឺជាការណែនាំចំពោះឆន្ទានុសិទ្ធិរបស់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត ដែលតម្រូវឲ្យមានការពិនិត្យរបស់តុលាការដែរ។

ខ្ញុំនឹងរំឭកអំពីធាតុនៃច្បាប់ដែលលើកឡើងដោយភាគីទាំងអស់ ហើយខ្ញុំគិតថាអ្វីដែលយើងបានលើកឡើងនេះនឹងមានការផ្ដល់នៃការវិភាគផ្សេងៗ ហើយនិងផ្ដល់ធាតុបន្ថែម។

[១៥:៣៥:២០]

ជាដំបូង ខ្ញុំចង់លើកឡើងអំពីការជំទាស់របស់ ឌុច នៅក្នុងសារណាបណ្ដឹងសាទុក្ខរបស់គាត់ គឺជំទាស់ទៅនឹងយុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះសាលាដំបូង។ យុត្តាធិការលើរូបបុគ្គលត្រូវបានកំណត់ត្រឹមមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត

ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងអន្តរជាតិ។

កិច្ចព្រមព្រៀង និងច្បាប់ស្តីពី អ.វ.ត.ក មិនបានចែងច្បាស់អំពីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ។ ហើយនៅក្នុងកិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក ដដែល មិនមានចែងថា កាំង ហ្កេកអ៊ាវ ហៅ ឌុច អាចជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តខាងលើនោះទេ។

អង្គជំនុំជម្រះសាលាដំបូង បានសន្មតបានយក កាំង ហ្កេកអ៊ាវ ហៅ ឌុច មកឧបកិច្ចជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះ គឺសម្រាប់តែដើម្បីដំណើរការក្តីទៅជាលក្ខណៈវិជ្ជមានតែប៉ុណ្ណោះ។ ដូច្នេះ អង្គជំនុំជម្រះបានបដិសេធមិនព្រមពិនិត្យវិធាន៨៩ នៃវិធានផ្ទៃក្នុង ដូចដែលមេធាវីការពារក្តីបានស្នើសុំ ពីព្រោះថាអង្គជំនុំជម្រះដឹងយ៉ាងច្បាស់ថា តាមពិតមិនមានធាតុផ្សំណាមួយដែលអាចដាក់ ឌុច ឲ្យស្ថិតនៅក្នុងរបបនៃមាត្រា១ នៃកិច្ចព្រមព្រៀង និងមាត្រា១(ថ្មី) និងមាត្រា២(ថ្មី) នៃ អ.វ.ត.ក។ ហើយនៅក្នុងសេចក្តីផ្តើមនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងបានជាន់ឈ្លីកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។

[១៥:៣៧:១៦]

អង្គជំនុំជម្រះសាលាដំបូង បានរំលោភលើបទដ្ឋានអាជ្ញាបញ្ញានៃច្បាប់។ ពោលគឺគោលការណ៍នីត្យានុកូលភាព ដោយដកស្រង់ឧទាហរណ៍ចេញពីប្រព័ន្ធច្បាប់ ខំមិនឡ ដើម្បីធ្វើជាមូលដ្ឋាននៃការបកស្រាយជាគោលការណ៍របស់ខ្លួន ដើម្បីឲ្យអាចជំទាស់ទៅនឹងមាត្រា១ នៃកិច្ចព្រមព្រៀង និងមាត្រា១, ២ (ថ្មី) នៃច្បាប់ អ.វ.ត.ក ដែលកំណត់យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក មកត្រឹមតែជនមេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម។

បើសិនជាអង្គជំនុំជម្រះសាលាដំបូងបានពិនិត្យធាតុផ្សំនៃភស្តុតាង ដែលបានបង្ហាញដោយមេធាវីការពារក្តីនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលនោះ អង្គជំនុំជម្រះប្រាកដជាប្រកាសថាខ្លួនពុំមានយុត្តាធិការលើ កាំង ហ្កេកអ៊ាវ មិនខាន។

ហេតុដូច្នេះហើយ គឺអង្គជំនុំជម្រះសាលាដំបូងបានត្រឹមតែគេចវេសពីបញ្ហានេះ ដោយបានការពារខ្លួនត្រង់សំអាងហេតុថា អញ្ញត្រកម្មរបស់មេធាវីការពារក្តី ត្រូវបានលើកឡើងយឺតពេលទៅហើយ។ ហើយមេធាវីការពារក្តីបានបញ្ជាក់ថា មានភស្តុតាងដោះបន្ទុកសំខាន់ៗ ដែលជនជាប់ចោទបានបង្ហាញដែលបញ្ជាក់ពីតួនាទី និងតំណែងពិតប្រាកដរបស់ជនជាប់ចោទ ហើយដូចគ្នាដែរ គឺសហព្រះរាជអាជ្ញា

ក៏បានបង្ហាញភស្តុតាងថា ជនជាប់ចោទមិនស្ថិតនៅក្រោមរបបនៃមាត្រា១ នៃកិច្ចព្រមព្រៀង និងមាត្រា ១(ថ្មី), ២(ថ្មី) នៃច្បាប់ អ.វ.ត.ក។ តែភស្តុតាងទាំងនេះ មិនត្រូវបានពិនិត្យដោយអង្គជំនុំជម្រះសាលាដំបូងដែរ ហើយដោយសារតែបញ្ជាក់ថា គឺចេះតែលើកឡើងហួសពេល ហើយវាគឺជាកំហុសឆ្គង កំហុសឆ្គងធ្ងន់ធ្ងរដែលបានប៉ះពាល់ទៅដល់សាលក្រមដែលបានចេញ។

[១៥:៣៨:៥១]

ស្ថានភាពនេះកើតចេញពីប្រការដែលថា តាំងពីពេលបើកកិច្ចស៊ើបអង្កេតបឋម សហព្រះរាជអាជ្ញាមិនបានធ្វើការស្រាវជ្រាវរកអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត ដែលត្រូវបានសង្ស័យថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅមន្ទីរស-២១ នោះទេ។ ប៉ុន្តែ សហព្រះរាជអាជ្ញាបានផ្តោតត្រឹមតែទៅលើតួនាទី និងមុខងាររបស់ ឌុច នៅមន្ទីរស-២១ ក្នុងថ្ងៃ-- ចាប់ពីថ្ងៃ១៧ មេសា ៧៥ ទៅដល់ឆ្នាំ៧៩។ ហើយការភ័ន្តច្រឡំនេះ បានធ្វើឲ្យសហព្រះរាជអាជ្ញាយល់ខុសថា ជនជាប់ចោទគឺជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅមន្ទីស-២១ ដោយមិនទុកលទ្ធភាពឲ្យជនជាប់ចោទ និងមេធាវីរបស់ជនជាប់ចោទធ្វើការបង្ហាញភស្តុតាងផ្ទុយភ្លាមៗបាននោះឡើយ។

[១៥:៣៩:៤៣]

អាស្រ័យហេតុនេះហើយ បានសហព្រះរាជអាជ្ញាយល់ច្រឡំថា អ.វ.ត.ក មានយុត្តាធិការក្នុងការកាត់សេចក្តី ឌុច ពីព្រោះថា ឌុច ត្រូវតែទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនក្នុងឋានៈជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សហព្រះរាជអាជ្ញាថែមទាំងបានចាត់ទុក ឌុច ថាជាស្ថិតនៅក្នុងចំណោមមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យទៀតផង។

ដូច្នេះហើយបានជាបន្ទាប់មកសហចៅក្រមស៊ើបអង្កេត ទំនងជាផ្អែកទៅលើសេចក្តីសន្និដ្ឋានចុងក្រោយនេះ ដើម្បីកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះថា ជនជាប់ចោទត្រូវបានចាត់ទុកថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត។ ក៏ប៉ុន្តែភស្តុតាងទាំងអស់នេះ ស្តែងឲ្យឃើញថា ទាំងសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតមិនបានបង្ហាញថា ជនជាប់ចោទស្ថិតនៅក្រោមយុត្តិធិការរបស់ អ.វ.ត.ក ដោយមិនអាចប្រកែកបានទេ ផ្អែកទៅលើការវិនិច្ឆ័យតាមផ្លូវច្បាប់ជាក់លាក់ ឬផ្អែកទៅលើភស្តុតាងគ្រប់គ្រាន់។

ដូច្នេះ គឺមានតែទទួលនូវឥទ្ធិពលនៃធាតុផ្សំទាំងអស់នេះហើយ ទើបអង្គជំនុំជម្រះសាលាដំបូង

បានវិនិច្ឆ័យដោយភ័ន្តច្រឡំថា ឌុច ស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួន ហើយថាទឡ្ហីករណ៍ផ្ទុយរបស់មេធាវីការពារក្តីមិនអាចទទួលយកបានទេ ដោយសារតែបានលើកឡើងយឺតពេលទៅហើយ។ ហេតុនេះ មេធាវីការពារក្តីមិនអាចជំទាស់តាំងពីដំបូងទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដែលបានប្រកាន់យកនៅពេលដែលខ្លួនបានចេញដីកាបញ្ជូនរឿងឲ្យស៊ើបសួរប្រឆាំងនឹង ឌុច។

[១៥:៤១:១០]

ដូច្នេះ យើងអាចសួរថា តើយើងផ្អែកលើភស្តុតាងអ្វីដើម្បីទទួលនូវសំណុំរឿង០០១? អង្គជំនុំជម្រះសាលាដំបូង មិនបានបំពេញករណីកិច្ចរបស់ខ្លួនក្នុងការផ្ទៀងផ្ទាត់មុននឹងទទួលសំណុំរឿង០០១ ថាតើលក្ខខណ្ឌចាំបាច់ត្រូវបានបំពេញដែរឬទេ ដើម្បីឲ្យខ្លួនអាចអនុវត្តយុត្តាធិការបុគ្គលបាន និងកាត់សេចក្តី ឌុច ស្របតាមបទប្បញ្ញត្តិនៃមាត្រា១ នៃកិច្ចព្រមព្រៀង និងមាត្រា១(ថ្មី) និងមាត្រា២(ថ្មី) នៃច្បាប់ អ.វ.ត.ក។ ហើយយោបល់របស់ចៅក្រមអន្តរជាតិម្នាក់ បានប្រឆាំងទៅនឹងជំនឿជាក់ថា អង្គជំនុំជម្រះសាលាដំបូងមិនមានយុត្តាធិការក្នុងការវិនិច្ឆ័យទោស ហើយបានបង្ហាញភស្តុតាងថា អង្គជំនុំជម្រះបានដឹង និងទទួលស្គាល់ថា-- អង្គជំនុំជម្រះមិនមានយុត្តាធិការនៅក្នុងសំណុំរឿងនេះទេ។

[១៥:៤១:៥៩]

ជាការសន្និដ្ឋានអង្គជំនុំជម្រះមិនមានយុត្តាធិការទៅលើ ឌុច ដែលមានតំណែងនៅក្នុងរចនាសម្ព័ន្ធនៃកម្ពុជាប្រជាធិបតេយ្យ និងនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា គឺថាមានតំណែងទាប មិនមែនខ្ពស់នោះទេ។ ដូច្នេះ ចាប់ពីថ្ងៃ៣០ មីនា ឆ្នាំ២០០៩ ដល់ថ្ងៃទី២៧ វិច្ឆិកា ឆ្នាំ២០០៩ នេះ គឺថាចាត់ទុកជាលទ្ធផលនៃការភ័ន្តច្រឡំក្នុងការវាយតម្លៃទៅលើយុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះសាលាដំបូង។

ខ្ញុំគិតថា ខ្ញុំព្យាយាមពន្យល់នូវជំហររបស់មេធាវីការពារក្តីចំពោះនឹងការយល់ឃើញរបស់ពួកគេ។ ខ្ញុំសូមរំឭកនូវបទប្បញ្ញត្តិមួយចំនួននៃកិច្ចព្រមព្រៀង ដែលចេញពីសេចក្តីសម្រេចនៃមហាសន្និបាតរបស់អង្គការសហប្រជាជាតិនៅឆ្នាំ២០០២។

[១៥:៤២:៥៧]

បើអ៊ីចឹង ខ្ញុំសូមបញ្ជាក់នូវមាត្រា១ ទាំងស្រុង គឺថាមាត្រានេះមិនមាននូវការស្នើរស្នាក់នោះទេ គឺថាគោលបំណងរបស់កិច្ចព្រមព្រៀងនេះ គឺថាដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះ (ឮមិនច្បាស់)។

មាត្រា១ នេះ គឺមានចែងដូចតទៅ៖ គោលបំណងរបស់កិច្ចព្រមព្រៀងនេះ គឺកំណត់អំពីកិច្ច

សហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទំនៀមទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភទៅលើអនុសញ្ញាអន្តរជាតិ ដែលកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី ១៧ មេសា ៧៥ ដល់ថ្ងៃទី៦ មករា ៧៩។

គឺថាអ្វីដែលបានសរសេរនេះ គឺថាយើងដកចេញនូវលទ្ធភាពក្នុងការបញ្ជាក់ថា មេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយដែលទទួលខុសត្រូវ គឺថាលទ្ធភាពនូវការបានបង្រួតគ្នា។ ដូច្នេះ វាមិនមានការសង្ស័យទេថា គឺថាយើងមានជម្រើសក្នុងការកាត់សេចក្តីទៅលើជនប្រភេទទាំងពីរនេះ។ ហើយខ្ញុំសោកស្តាយណាស់ដែលសហមេធាវីការពារក្តីខ្លួនឯងនេះ បានបកស្រាយគឺថាទៅលើអត្ថបទនេះ គឺថាមិនមានការសង្ស័យទេ គឺនៅពេលដែលមានការសួរដោយអង្គជំនុំជម្រះ គឺថាគាត់ការបដិសេធ ប៉ុន្តែគឺថាការត្រឡប់មកលើអ្វីដែលខ្លួនបាននិយាយ ហើយនិងការបដិសេធនូវអ្វីដែលបានលើកឡើង គឺថាក្នុងភាសាបារាំង គឺថាមានលក្ខណៈត្រឹមត្រូវ។

[១៥:៤៤:៤២]

មាត្រា២ គឺថាបានបញ្ជាក់អំពីការកម្រិតទៅលើយុត្តាធិការរបស់ អ.វ.ត.ក គឺថាមាត្រា២ នេះគឺបានបញ្ជាក់ថា កិច្ចព្រមព្រៀងនេះ គឺថាទទួលស្គាល់ថា អង្គជំនុំជម្រះមានយុត្តាធិការបុគ្គលលើមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ដែលមានចែងនៅក្នុងមាត្រា១ គឺថានៅក្នុងភាសាបារាំង គឺថាៗមាត្រានេះគឺមានលក្ខណៈរួម ហើយមិនមានការលក្ខណៈជាជម្រើសនោះទេ។ គឺក្នុងបរិបទនេះហើយ ដែលកើតមាននូវច្បាប់នៅថ្ងៃទី២៧ តុលា ២០០៤ គឺមាត្រា១ នៃច្បាប់ អ.វ.ត.ក បានចែងឡើងវិញនូវគោលបំណងនៃកិច្ចព្រមព្រៀង ហើយមាត្រា១ គឺជនទាំងឡាយ-- មេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះគឺថា យើងត្រូវបានហៅថា “ជាជនសង្ស័យ”។ ហើយនៅក្នុងនេះគឺថា មិនមានការមន្ទិលសង្ស័យនោះទេ គឺពាក្យពេចន៍នៃមាត្រានេះ គឺថាយើងអាចចាត់ទុកថាជាជនសង្ស័យ គឺថាមានបុគ្គលពីរប្រភេទ ហើយយើងមិនបានបូករួមចូលគ្នាទេ។ វាគឺជាជម្រើស គឺផ្តល់ឲ្យជាជម្រើសផ្សេងគ្នា ហើយវាបានផ្តល់នូវការ-- មាត្រា៣ គឺយើងបានលើកអំពីក្រមព្រហ្មទណ្ឌឆ្នាំ៥៦ ហើយមាត្រា៤ គឺនិយាយអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។

[១៥:៤៦:១៤]

ហើយមាត្រា៥ និយាយអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយមាត្រា៦ គឺកិច្ចអនុញ្ញាទីក្រុមហ្សឺណែវ មាត្រា៧ គឺអនុសញ្ញាទីក្រុងឡាអេ ហើយនិងមាត្រា៨ សន្ធិសញ្ញាទីក្រុងវីយែន។ ហើយចំពោះមាត្រា២៩ គឺខ្ញុំចង់បញ្ជាក់ថា ខាងមេធាវីការពារក្តីគឺមិនបានលើកឡើងអំពីចំណុចនេះទេ។ ហើយគឺថានៅពេលដែលវិភាគអំពី ឌុច នោះគឺថាមិនមានការបញ្ចូល ឌុច ទៅក្នុងឋានៈនេះ។ ហើយជនសង្ស័យណាដែលមានផែនការញុះញង់ បញ្ជា ប្រព្រឹត្ត ឬជួយ និងជំរុញក្នុងការរៀបចំផែនការ ឬការប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងមាត្រា៣ (ថ្មី), ៤, ៥, ៦, ៧ និង៨ នៃច្បាប់នេះត្រូវទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មនេះ។ ទទួលតួនាទី ឬឋានៈរបស់ជនសង្ស័យមិនអាចជួយឲ្យជននេះរួចផុតពីការទទួលខុសត្រូវពីបទឧក្រិដ្ឋ ឬជួយកាត់បន្ថយទណ្ឌកម្មដល់ជននេះឡើយ។

[១៥:៤៧:១២]

ប្រការដែលថាសកម្មភាពក្នុងចំណោម សកម្មភាពដែលមានចែងនៅក្នុងមាត្រា៣ (ថ្មី), ៤, ៥, ៦, ៧ និង ៨ នៃច្បាប់នេះ ដែលត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់នេះ មិនអាចជួយឲ្យថ្នាក់លើរួចផុតពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនោះបានទេ ប្រសិនបើថ្នាក់លើមានការបញ្ជា និងមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាព ឬមានអំណាចនិងការត្រួតពិនិត្យទៅលើអ្នកនៅក្រោមបង្គាប់ ហើយបានដឹងនិងមានហេតុផលដឹងថា អ្នកនៅក្រោមបង្គាប់បានប្រព្រឹត្ត ឬនឹងប្រព្រឹត្តនៅសកម្មភាពបែបនេះ ហើយខ្លួនមិនបានចាត់វិធានការចាំបាច់សមស្របដើម្បីបង្ការអំពើបែបនេះ ឬក៏ដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តនេះ។

[១៥:៤៧:៤៨]

ហើយជនសង្ស័យដែលបានប្រព្រឹត្តទៅតាមបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬថ្នាក់លើណាមួយមិនអាចជួយឲ្យជននេះរួចផុតពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនេះឡើយ។ គឺនៅក្នុងបរិបទច្បាប់នេះហើយដែលសហព្រះរាជអាជ្ញាធ្វើការស្រាវជ្រាវដើម្បីកំណត់នូវបុគ្គលដែលជាប់ពាក់ព័ន្ធនឹងបទយុត្តាធិការ ស្តីពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។ ការពិនិត្យអង្គហេតុនិងភស្តុតាងដែលប្រមូលបាននាំឲ្យសហព្រះរាជងអាជ្ញា ប្រកាន់យកគោលការណ៍ចោទប្រកាន់ ដោយយោងទៅតាមអត្ថបទច្បាប់ខាងលើចំពោះ ឌុច ដោយសារតែការប្រព្រឹត្តរបស់ ឌុច ទាំងអស់នៅក្នុងក្របខ័ណ្ឌនៃមុខងារជាប្រធានមន្ទីរស-២១។

[១៥:៤៨:៣២]

ហើយភស្តុតាងដែលបានប្រមូលបានទាំងអស់បានស្តែងឲ្យឃើញថា ផ្ទុយស្រឡះពីអ្វីដែលបានចោទប្រកាន់។ ជនជាប់ចោទមិនមែនគ្រាន់តែជាអ្នកអនុវត្តធម្មតានោះទេ ហើយគឺថាគាត់មានលទ្ធភាពក្នុងការក្នុងការបញ្ចេញយោបល់។ ឌុច ជាអនុប្រធាន និងបន្ទាប់មកជាប្រធានមន្ទីរស-២១ ដែលត្រូវបានតែងតាំងដោយសមាជិកអចិន្ត្រៃយ៍មួយរូប នៃគណៈមជ្ឈិមកាលពីសម័យនោះ ដោយសារតែគាត់មានបទពិសោធន៍ ដែលទទួលបាននៅក្នុងការគ្រប់គ្រងមន្ទីរឃុំឃាំងម-១៣ ដែលនៅទីនេះគាត់បានបង្ហាញពីការជឿជាក់យ៉ាងខ្លាំងទៅលើរបបខ្មែរក្រហម ហើយនិងគុណសម្បត្តិរបស់គាត់ជាអ្នកសួរចម្លើយពូកែជាងគេ។

ការតែងតាំងដោយគណៈមជ្ឈិមជាប្រធានមន្ទីរស-២១ មិនអាចជួយឲ្យគាត់រួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅមន្ទីរស-២១នោះទេ។ ហើយជនជាប់ចោទបានដឹកនាំមន្ទីរស-២១ យ៉ាងសកម្ម។ គាត់មានតួនាទីជាអ្នកត្រួតពិនិត្យ ចូលរួមនៅក្នុងការសួរចម្លើយ ធ្វើចំណារទៅលើចម្លើយសារភាព ផ្តល់តម្រុយដល់បក្សពាក់ព័ន្ធនឹងការស្រាវជ្រាវរកជនក្បត់ថ្មីៗដែលអាចមាន។ គ្រប់គ្រងមន្ទីរស-២១ ដែលស្ថិតនៅក្រោមការបញ្ជារបស់គាត់ទាំងស្រុង និងបង្រៀនអំពីបុគ្គលិកអំពីបច្ចេកទេសសួរចម្លើយ និងធ្វើទារុណកម្ម។

[១៥:៤៩:៣៤]

ឌុច មានអំណាចត្រួតពិនិត្យទាំងស្រុងទៅលើការប្រព្រឹត្តរបស់អ្នកនៅក្រោមបង្គាប់ និងការប្រព្រឹត្តទៅនៃមន្ទីរស-២១។ ឌុច ជាអ្នកសម្របសម្រួល និងចូលរួមដោយផ្ទាល់ ដោយចេតនា ដោយប្រយោល ឬដោយផ្ទាល់ ឬដោយប្រយោលនៅក្នុងការបោសសម្អាតមនុស្សជាង១២.០០០នាក់។ គាត់បានអនុវត្តតាមគោលនយោបាយនេះ ហើយនិងវិធីសាស្ត្របំភិតបំភ័យ។ អង្គហេតុដែលមានភាពធ្ងន់ធ្ងរដែលបានប្រព្រឹត្តក្រោមបញ្ជារបស់ ឌុច គឺជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវ។

[១៥:៥០:១៤]

សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់អះអាង ដោយការកំណត់ប្រភេទបទល្មើសនេះ បន្ទាប់ពីបានស៊ើបសួរលើសំណុំរឿង។ ដូច្នេះ ជនជាប់ចោទលើកឡើងដោយភ័ន្តច្រឡំថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសឆ្គងដោយចាត់ទុកថាខ្លួន គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ៧៥ ដល់ថ្ងៃ៦ មករា ៧៩ នៅមន្ទីរស-២១។ គេមិនអាច

សន្និដ្ឋានថា ការកំណត់ប្រភេទបទល្មើសនេះគ្មានមូលដ្ឋានច្បាប់នោះទេ។ ដោយហេតុថា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាបានចាត់ទុក ឌុច ជាមេដឹកនាំជាន់ខ្ពស់នៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។

[១៥:៥០:៣៩]

សហចៅក្រមស៊ើបអង្កេតត្រូវបានចងភ្ជាប់ដោយអង្គហេតុ និងបទល្មើស ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតមានអំណាចនៅក្នុងការកំណត់ប្រភេទបទល្មើសឡើងវិញផ្សេងពីនេះ ដែលសហចៅក្រមស៊ើបអង្កេតបានធ្វើរួចមកហើយ។ ដូច្នេះ ទឡ្ហីករណ៍នេះមិនអាចត្រូវបានការពារដោយជនជាប់ចោទឡើយ។

ការវាយតម្លៃទៅលើការកំណត់ឋានៈជាជនសង្ស័យពោល គឺបុគ្គលដែលចូលទៅក្នុងនិយមន័យឋានៈបុគ្គលនៃអត្ថបទច្បាប់បង្កើតយុត្តាធិការពិសេសរបស់ អ.វ.ត.ក ត្រូវធ្វើការពិនិត្យជាមុនដោយសហព្រះរាជអាជ្ញា និងពិនិត្យឡើងវិញដោយសហចៅក្រមស៊ើបអង្កេតនៅពេលបិទកិច្ចស៊ើបសួរ។ គឺនៅក្នុងបរិបទនេះហើយ ដែលអង្គជំនុំជម្រះសាលាដំបូងនឹងត្រូវប្តឹងអំពីអង្គហេតុ ដែលបានកើតឡើងនៅក្នុងអំឡុងថ្ងៃ១៧ មេសា ៧៥ ដល់ថ្ងៃ៦ មករា ៧៩ ដែលបានប្រព្រឹត្តដោយបុគ្គលម្នាក់ ដែលជាប់ពាក់ព័ន្ធយ៉ាងច្បាស់នៅក្នុងក្របខ័ណ្ឌនៃការអនុវត្តបទប្បញ្ញត្តិស្តីពីយុត្តាធិការបុគ្គល នៃអត្ថបទច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ ហើយបុគ្គលនោះហើយ គឺ ឌុច នេះឯងតែម្តង។

[១៥:៥១:៤១]

ទន្ទឹមនឹងនេះ នៅពេលទទួលបានការប្តឹងចោទប្រកាន់ទៅលើជនសង្ស័យ កាំង ហ្កេកអ៊ាវ ហៅ ឌុច អង្គជំនុំជម្រះសាលាដំបូងមិនអាចចាត់ទុកថាលក្ខខណ្ឌនៃការប្តឹងមានលក្ខណៈគ្រប់គ្រាន់ឡើយ។ គឺអង្គជំនុំជម្រះមានយុត្តាធិការក្នុងការពិនិត្យឲ្យបានច្បាស់អំពីអង្គហេតុ និងភស្តុតាងដែលបានលើកឡើងដើម្បីផ្ទៀងផ្ទាត់ថា តើយុត្តាធិការរបស់ខ្លួនពិតជាត្រូវបានបញ្ជាក់ដោយការពិតនៃអង្គហេតុទាំងនេះ និងការចោទប្រកាន់អង្គហេតុចំពោះជនសង្ស័យ គឺ កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែរឬទេ? ដូច្នេះ យើងខ្ញុំសូមឆ្លើយសំណួរដែលបានចោទដូចតទៅនេះ៖

[១៥:៥២:១៤]

ពិតណាស់ និយមន័យនៃពាក្យមេដឹកនាំខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលមានចែងនៅក្នុងច្បាប់ អ.វ.ត.ក គឺជាលក្ខខណ្ឌយុត្តាធិការមួយ

ដែលតម្រូវឲ្យមានការវាយតម្លៃជាមុនដោយសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត។ ប៉ុន្តែប្រាកដណាស់ អង្គជំនុំជម្រះអាចធ្វើការពិនិត្យឡើងវិញបាន។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះសាលាដំបូងបានដឹងយ៉ាងច្បាស់អំពីលក្ខខណ្ឌចាំបាច់នេះ ហើយបានធ្វើការពិនិត្យអង្គហេតុបទចោទ និងភស្តុតាងប្រឆាំងនឹងជនជាប់ចោទយ៉ាងហ្មត់ចត់ ដើម្បីអាចឆ្លើយតបឲ្យបានច្បាស់ទៅនឹងការកម្រិតយុត្តាធិការបុគ្គលរបស់ខ្លួន។

[១៥:៥២:៥៤]

លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូង បានឆ្លើយតបយ៉ាងច្បាស់ទៅនឹងការសង្កេតនេះ។ ជាក់ស្តែងបន្ទាប់ពីបានពិនិត្យមួយម្តងៗនូវឧក្រិដ្ឋកម្មជាច្រើន ដែលបានចោទប្រកាន់ទៅលើជនជាប់ចោទ អង្គជំនុំជម្រះបានរំឭកថា គឺនៅចំណុច ២.៥.២.៥, ៣២៨ ភស្តុតាងបានបង្ហាញយ៉ាងច្បាស់ថា មន្ទីរស-២១ គឺជាផ្នែកដ៏សំខាន់មួយនៃរចនាសម្ព័ន្ធយោធា និងនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយនិងត្រូវបានចាត់ទុកថាមានសារៈសំខាន់យ៉ាងខ្លាំង នៅក្នុងការសម្រេចឲ្យបាននូវទិសដៅនៃនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។

មន្ទីរស-២១ បានអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដូចជាការកម្ទេចខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា។ តួនាទីរបស់ជនជាប់ចោទជាប្រធានមន្ទីរស-២១ ដែលរាយការណ៍ដោយផ្ទាល់ទៅសមាជិកគណៈអចិន្ត្រៃយ៍ បានផ្តល់ឲ្យគាត់នូវតំណែងពិសេសមួយដើម្បីអនុវត្តនូវគោលនយោបាយនេះ។ អង្គជំនុំជម្រះសន្និដ្ឋានថា ជនជាប់ចោទបានដឹងនៅកម្មវត្ថុនៃគោលនយោបាយនេះ ហើយអង្គជំនុំជម្រះក៏សន្និដ្ឋានដែរថា មន្ទីរស-២១ គឺជាសមាសធាតុដ៏សំខាន់ក្នុងការអនុវត្តគោលនយោបាយនេះ។

[១៥:៥៣:៥២]

អង្គជំនុំជម្រះបានរំឭកថា សហចៅក្រមស៊ើបអង្កេតមិនបានចោទប្រកាន់ជនជាប់ចោទថា ជាមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យនោះទេ។ ប៉ុន្តែ បានចោទប្រកាន់ថា ជាជនជាប់ចោទម្នាក់ក្នុងចំណោមជនទាំងឡាយដែលត្រូវទទួលខុសត្រូវខ្ពស់បំផុត ចំពោះការរំលោភបំពានដែលកើតឡើងនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក។ ហើយនៅក្នុងកថាខណ្ឌ១២៩ ការស៊ើបសួរបានបង្ហាញថា ទោះបី ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ក៏គាត់អាចត្រូវបានចាត់ទុកចូលទៅក្នុងប្រភេទនៃអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្មដែលបាន និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរដែលប្រព្រឹត្តនៅចន្លោះថ្ងៃទី១៧ មេសា ៧៥ ដល់ថ្ងៃទី៦ មករា ៧៩ ដោយផ្អែកទៅលើអំណាចឋានានុក្រមជាផ្លូវការ

និងប្រកបដោយប្រសិទ្ធភាពក្នុងឋានៈគាត់ជាអនុលេខា បន្ទាប់មកជាលេខា ក៏ដូចតាមរយៈការចូលរួមដោយផ្ទាល់នៅក្នុងឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅមន្ទីរស-២១ ដែលជាមន្ទីរសន្តិសុខគ្រប់គ្រងផ្ទាល់ដោយគណៈមជ្ឈិមនៃបក្សកុម្មុយនីស្ត។

[១៥:៥៤:៤៧]

កិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ អ.វ.ត.ក មិនបានចែងច្បាស់អំពីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ ឬជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ។ ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជាដែលបានបង្កើតនៅឆ្នាំ៩៨ ផ្អែកតាមសេចក្តីសម្រេចដោយមហាសន្និបាតរបស់អង្គការសហប្រជាជាតិលេខ ៥២, ១៣៥ បានផ្តល់អនុសាសន៍ថា “តុលាការនេះផ្តោតទៅលើបុគ្គលទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរបំផុត ទៅលើសិទ្ធិមនុស្សនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ”។ ដូច្នេះ គឺវារួមបញ្ចូលមេដឹកនាំជាន់ខ្ពស់ដែលទទួលខុសត្រូវចំពោះការរំលោភបំពានព្រមទាំងជនទាំងឡាយណាដែលស្ថិតនៅថ្នាក់ក្រោម ប៉ុន្តែ មានចំណងទាក់ទងផ្ទាល់ទៅនឹងអំពើព្រៃផ្សៃធ្ងន់ធ្ងរបំផុតនោះ។

យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិផ្សេងៗទៀត ដែលបានពិនិត្យផងដែរ អំពីអត្ថន័យនៃឃ្លាមេដឹកនាំជាន់ខ្ពស់ដែលត្រូវបានសង្ស័យថា ជាអ្នកទទួលខុសត្រូវខ្ពស់ផុតនោះ បានពិចារណាទាំងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និងកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ។

[១៥:៥៥:៤៧]

ហើយនៅក្នុងអំឡុងសវនាការគឺក្នុងឋានៈជាប្រធានមន្ទីរស-២១ ឌុច បានដឹកនាំក្រុមសួរចម្លើយហើយបានចូលរួមនៅក្នុងសកម្មភាពរបស់មន្ទីរនេះ ហើយនិងបានបណ្តុះបណ្តាលបុគ្គលិកឲ្យចេះសួរចម្លើយ និងធ្វើទារុណកម្ម។ ហើយ ឌុច គាត់បានពិនិត្យមើលប្រតិបត្តិការទូទៅនៃមន្ទីរនេះ គឺបានចារទៅលើសំណួរចម្លើយ ហើយមន្ទីរស-២១ គឺជាមន្ទីរសំខាន់បំផុតរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបានចាត់ទុកថាជាផ្នែកមួយនៃរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា ដោយរាយការណ៍ទៅលើថ្នាក់ដឹកនាំជាន់ខ្ពស់បំផុតរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីធ្វើការប្រតិបត្តិការពាសពេញប្រទេស និងទទួលកម្មាភិបាលជាន់ខ្ពស់និងអ្នកទោសសំខាន់ៗ។ មនុស្សយ៉ាងតិចណាមួយ១២.០០០នាក់ ត្រូវបានឃុំខ្លួននៅមន្ទីរស-២១ ជាតួលេខដែលមិនពេញលេញដោយសារតែនៅមន្ទីរស-២១ គឺមិនមានទម្លាប់កត់ត្រាឈ្មោះអ្នកទោសទាំងអស់នោះទេ។ ហើយជនរងគ្រោះត្រូវបានបញ្ជូនមកស្ទើរតែមកពីគ្រប់ទូទាំងប្រទេសទៅ

មន្ទីរស-២១ មានន័យថា វិសាលភាពនេះគឺ មានទូទាំងប្រទេស។

[១៥:៥៦:៥៧]

ដូច្នេះ អង្គជំនុំជម្រះយល់ស្របជាមួយនឹងការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេត ហើយយល់ឃើញថា ជនជាប់ចោទគឺ ស្ថិតនៅក្នុងយុត្តាធិការរបស់បុគ្គលរបស់ អ.វ.ត.ក ក្នុងឋានៈជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភបំពានធ្ងន់ធ្ងរទៅលើច្បាប់អន្តរជាតិ និងអន្តរជាតិដែលបានប្រព្រឹត្តនៅក្នុងអំឡុងឆ្នាំ៧៥ ដល់ឆ្នាំ៧ ៩។ ដូច្នេះ អង្គជំនុំជម្រះមិនចាំបាច់ពិនិត្យទៅលើបញ្ហាថាតើជនជាប់ចោទជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យដែរឬយ៉ាងណាទេ? ហើយក្រោយពីអានពិនិត្យទៅលើឯកសារទាំងអស់នោះគឺ សហព្រះរាជអាជ្ញាបាន-- ដោយនីតិវិធីបានផ្តោតលើសំណួរថាតើ កាំង ហ្កេកអ៊ាវ ជាអ្នកទទួលខុសត្រូវជាន់ខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ? សហចៅក្រមស៊ើបអង្កេតក៏បានសួរខ្លួនឯងនូវសំណួរដដែលនេះដែរ ហើយបានកែប្រែដោយផ្នែកនូវសេចក្តីសន្និដ្ឋានដំបូងរបស់សហព្រះរាអាជ្ញា។

អង្គជំនុំជម្រះសាលាដំបូងបានសួរខ្លួនឯងនៅសំណួរដដែលនេះជាពិសេស ហើយបានឆ្លើយដោយវិជ្ជមាន។ អំពីអញ្ញត្រកម្មបន្ទាន់បង្ខំលើភាពគ្មានយុត្តាធិការរបស់ អ.វ.ត.ក។ ខ្ញុំសូមរំឭកថា យោងតាមកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ អ.វ.ត.ក អង្គជំនុំជម្រះវិសាមញ្ញអនុវត្តយុត្តាធិការរបស់ខ្លួនស្របតាមវិធាននីតិវិធីដែលកំណត់នៅក្នុងច្បាប់កម្ពុជា ក្រោយពីបានបង្កើតឡើង ហើយ អ.វ.ត.ក បានអនុម័តវិធានផ្ទៃក្នុង។ វិធានផ្ទៃក្នុងមានគោលបំណងពង្រឹងនីតិវិធីកម្ពុជា ដែលអនុវត្តចំពោះមុខការកាត់សេចក្តីនៅចំពោះមុខ អ.វ.ត.ក ។

[១៥:៥៨:៣៨]

កិច្ចព្រមព្រៀង អ.វ.ត.ក និង-- អង្គការសហប្រជាជាតិ និងអ.វ.ត.ក ចែងថាប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងអំពីករណីពិសេសមួយ ឬក៏ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬក៏ប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃវិធីទាំងនេះជាមួយនឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំពីបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរ-ជាតិ។

ដូច្នេះ ទោះបីជាច្បាប់កម្ពុជាចែងពីនីតិវិធី នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក៏ដោយ ក៏វិធានកម្រិតនីតិវិធីអន្តរជាតិ ត្រូវបានប្រើប្រាស់ជាគោលបានតាមតម្រូវការ។ ក៏ប៉ុន្តែ ក្នុងអំឡុងពេល

សវនាការបឋមជនជាប់ចោទមិនបានលើកឡើង អំពីអញ្ញត្រកម្មពាក់ព័ន្ធនឹងយុត្តាធិការរបស់ អ.វ.ត.ក ផ្នែកវិធាន៨៧ នៃវិធានផ្ទៃក្នុងទេ។ នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលមេធាវីការពារក្តី បានលើកឡើងអំពីភាពមិនមានយុត្តាធិការរបស់អង្គជំនុំជម្រះក្នុងការកាត់សេចក្តីជនជាប់ចោទទេ។ ដោយសារតែជនជាប់ចោទមិនមែនជាមេដឹកនាំជាន់ខ្ពស់ ឬជាជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។

[១៦:០០:០៣]

អង្គជំនុំជម្រះ-- អស់រយៈពេលប្រាំបួនខែមកហើយ ដែលបានភាគីការពារក្តីបានលើកបញ្ហាហ្នឹង ហើយលើកសំអាងហេតុដែលទាក់ទងទៅផលវិបាកតាំងពីដើមមកមិនព្រមថាអង្គជំនុំជម្រះពុំមានយុត្តា-ធិការនោះទេ។ ហើយអង្គជំនុំជម្រះយល់ឃើញថា ការលើកឡើងខកនេះមិនអាចលើកជាអញ្ញត្រកម្មត្រឹមត្រូវតាមច្បាប់នោះទេ។ ហើយលើសពីនេះទៅទៀត មេធាវីការពារក្តីបានលើកឡើងថា ឧបសម្ព័ន្ធប្រាំនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ១៩៩១ និងច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យនៅក្រៅច្បាប់ឆ្នាំ១៩៩៤ បានធ្វើឲ្យជនជាប់ចោទផុតពីការចោទប្រកាន់ផងដែរ។

[១៦:០១:០២]

អង្គជំនុំជម្រះកត់សម្គាល់ថា ទឡ្ហីករណ៍នេះត្រូវបានលើកឡើងយឺតពេល អាស្រ័យហេតុដូច្នេះត្រូវបដិសេធចោល។

សូមរំឭកផងដែលថា ក្នុងសវនាការថ្ងៃទីមួយនៃអង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញាបានអានទាំងស្រុងនូវបទចោទប្រកាន់ ហើយ កាំង ហ្គេកអ៊ាវ ដែលបានមានវត្តមាននៅក្នុងសវនាការ និងមានជំនួយពីមេធាវីការពារ បានយល់ព្រមលើអង្គហេតុមួយភាគធំ ដែលបានចោទប្រកាន់លើគាត់មួយចំណុចៗម្តង ដោយជំទាស់តែទៅលើចំណុចមួយចំនួននៃអង្គហេតុទាំងអស់ ដែលជាកម្មវត្ថុនៃការចោទប្រកាន់ ទោះបីជាអង្គហេតុទាំងនោះមានភាពធ្ងន់ធ្ងរយ៉ាងណាក៏ដោយ។

[១៦:០១:៤៧]

ជនជាប់ចោទ និងមេធាវីខាងការពារក្តី ដែលមានវត្តមាននៅជិតគាត់មិនធ្លាប់បានតវ៉ាទាល់តែសោះថា អ.វ.ត.ក គ្មានយុត្តាធិការលើ ឌុច ហើយក៏ ហើយចេញពីការសវនាការនេះ ពីការអានបទចោទទាំងអស់នេះ លើ ឌុច នេះ ហើយដែល ឌុច ទទួលស្គាល់ជាង៨0ភាគរយ។

ហេតុដូច្នេះ អង្គជំនុំជម្រះបានបង្ហាញភស្តុតាងនៃអង្គហេតុទាំងអស់។ នៅក្នុងបរិបទនេះ ជន

ជាប់ចោទ ហើយនិងមេធាវីរបស់ខ្លួនមិនដែលបានជំទាស់លើយុត្តាធិការរបស់ អ.វ.ត.ក ហើយក៏មិនដែលប្រកែកថា គាត់ជាអ្នកទទួលខុសត្រូវសំខាន់នៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនោះដែរ។ ហើយដោយយោលទៅលើភស្តុតាងដែលគេចោទប្រកាន់នោះ។

ដូច្នេះ ជនជាប់ចោទមិនបានលើកឡើងជាផ្លូវការ និងត្រឹមត្រូវតាមច្បាប់អំពីភាពគ្មានយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។ នៅក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិបន្ទាន់បង្ខំ ស្របតាមនីតិវិធីដែលអនុវត្តនៅចំពោះ អ.វ.ត.ក។

[១៦:០៣:០៨]

ដោយអនុវត្តតាមអត្ថបទច្បាប់កម្ពុជា អនុសញ្ញាអន្តរជាតិ និងវិធានទំនៀមទម្លាប់នៃច្បាប់មនុស្សធម៌អន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ខ្លួនត្រូវបានប្តឹងត្រឹមត្រូវតាមច្បាប់ និងបានចាត់ទុកអង្គហេតុប្រឆាំងនឹង ឌុច ថាធាតុផ្សំនៃយុត្តាធិការបុគ្គលដែលជាមូលនៃបណ្តឹង ដើម្បីអនុញ្ញាតឲ្យខ្លួនធ្វើការផ្តន្ទាទោសជនជាប់ចោទបាន។

[១៦:០៣:៣៥]

អាស្រ័យហេតុនេះ ដើម្បីផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី យើងខ្ញុំសូមស្នើឲ្យអង្គជំនុំជម្រះតុលាការកំពូលតម្កល់ខ្លឹមនៃសាលក្រម ដែលបានប្រកាសដោយអង្គជំនុំជម្រះសលាដំបូងនៅថ្ងៃទី ២៦ កក្កដា ឆ្នាំ២០១០ ត្រង់ចំណុចដែលអង្គជំនុំជម្រះសាលាដំបូងបានពិនិត្យឡើងវិញ នូវលក្ខខណ្ឌកំណត់យុត្តាធិការបុគ្គល និងបានចាត់ទុក ឌុច ជាជនសង្ស័យដែលការកាត់សេចក្តីស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក យោងតាមសេចក្តីសម្រេចនៃមហាសន្និបាទអង្គការសហប្រជាជាតិ និងច្បាប់ចុះថ្ងៃទី២០ តុលា ឆ្នាំ២០០៤ របស់ព្រះរាជាណាចក្រកម្ពុជា។ សូមអរគុណ។

[១៦:០៤:១៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហមេធាវីការពារជនជាប់ចោទធ្វើសេចក្តីថ្លែងតបទៅហ្នឹងសហព្រះរាជអាជ្ញា និងមេធាវីជាតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ សូមអញ្ជើញ!

**លោក ការ សាវុត្ថ៖**

សូមអរគុណឯកឧត្តមប្រធាន។ ខ្ញុំបាទសូមអនុញ្ញាតឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញា។

ចំណុចទីមួយ សហព្រះរាជអាជ្ញាបានលើកឡើងថា ឌុច ទទួលស្គាល់ឧក្រិដ្ឋកម្មនៅមន្ទីរស-២១

ហើយការទទួលស្គាល់ហ្នឹង ធ្វើឲ្យ ឌុច ទៅជាយុត្តាធិការបុគ្គលរបស់របស់ អ.វ.ត.ក។ ខ្ញុំបាទសូមអនុញ្ញាតជម្រាបថា ឌុច ទទួលស្គាល់ឧក្រិដ្ឋកម្មនៅស-២១ តាំងពីនៅតុលាការយោធា។ អត់ប្រកែកទេ ក៏ប៉ុន្តែសំខាន់នោះ សួរថាតើអ្នកណាជាម្ចាស់នៃឧក្រិដ្ឋកម្ម? អ្នកណាជាប្រធាននៃឧក្រិដ្ឋកម្ម?

[១៦:០៥:៣០]

អ្នកជាម្ចាស់នៃឧក្រិដ្ឋកម្ម គឺអ្នកណាដែលមានសិទ្ធិសម្រេច និងមានសិទ្ធិបញ្ជា។ ហើយអ្នកដែលមានសិទ្ធិសម្រេច និងសិទ្ធិបញ្ជា មិនមែន ឌុច ទេ។ ឌុច ទទួលបញ្ជាពីថ្នាក់លើ ពី សុន សេន ដូចគ្នា។ នេះខ្ញុំសូមជម្រាបឆ្លើយសំណួរដែលជាបញ្ហាទីមួយ។

ទីពីរ សហព្រះរាជអាជ្ញាបានលើកឡើងថា មេធាវីលើកពីអញ្ញត្រកម្ម។ មេធាវីលើកពីអញ្ញត្រកម្មហ្នឹង វាប្រាសចាកពីអង្គហេតុនិងអង្គច្បាប់។ ខ្ញុំបាទសូមឆ្លើយទៅវិញថា សាលក្រមក្នុងកថាខណ្ឌទី១៤ និងទី១៥ អង្គជំនុំជម្រះសាលាដំបូងថា មេធាវីលើកឡើងហ្នឹងមិនមែនជាអញ្ញត្រកម្មទេ។ ហ្នឹងឆ្លើយខ្លីតែប៉ុណ្ណឹងទេ។

[១៦:០៦:១៨]

ចំណុចទីបី ថា ឌុច នៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ហើយមេធាវីលើកឡើងថា មិនមែននៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ទេ វាទាស់គ្នាអ៊ីចឹងកន្លែងហ្នឹង។

អ៊ីចឹង ខ្ញុំសូមឲ្យមើលមាត្រា២៤ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។ គេបានបញ្ជាក់ច្បាស់ថា បុគ្គលម្នាក់ៗទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើផ្ទាស់ខ្លួនតែប៉ុណ្ណោះ។ ហើយអានេះមានអំពើផ្ទាល់ខ្លួនរបស់ ឌុច ឯណា។ ដូចដែលសហព្រះរាជអាជ្ញាបានបញ្ជូនដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាត្រង់កថាខណ្ឌទី១៥ និងទី១៦ បញ្ជូនរឿងទៅជំនុំជម្រះ និងកថាខណ្ឌទី១០ និងទី១១ របស់សហចៅក្រមស៊ើបអង្កេតបញ្ជូនរឿងទៅជម្រះ។

[១៦:០៧:១៧]

បញ្ជាក់ច្បាស់ហើយ ថាបក្សកុម្មុយនីស្តជាអ្នកបញ្ជា មាន ឌុច ឯណាបញ្ជា។ អ៊ីចឹង អ្នកណាបញ្ជា? អ្នកនុ៎ងហើយទទួលខុសត្រូវ។ បក្សកុម្មុយនីស្តបញ្ជា ហើយមកឧបកិច្ចយក ឌុច ទៅទទួលខុសត្រូវជំនួសជាការមិនត្រឹមត្រូវ។

ទីបួន ថាព្រះរាជអាជ្ញាលើកឡើងថា មេធាវីខកខានមិនបានកោះហៅលោក នួន ជា មិនឲ្យចៅក្រមស៊ើបអង្កេតហ្នឹងកោះហៅ នួន ជា មកតទល់។ ខ្ញុំបាទសូមអនុញ្ញាតជម្រាបថា នេះជាភស្តុតាង។

ម៉ាសែល ឡឺម៉ុងដ៍ និងអ្នកស្រី អូសស្ទីន បង្គាប់ទៅលោក បាស្ទីន ជាមន្ត្រីនគបាលយុត្តិធម៌ឲ្យស៊ើបអង្កេតតែដាក់បន្ទុក មិនឲ្យស៊ើបអង្កេតភស្តុតាងដាក់បន្ទុក-- អ៎! ដោះបន្ទុក។

[១៦:០៨:២០]

ដូច្នេះ ភារកិច្ចស៊ើបអង្កេតដោះបន្ទុក ដាក់បន្ទុក វាជាភារកិច្ចរបស់សហចៅក្រមស៊ើបអង្កេត។ កូនក្តីខ្ញុំបានឆ្លើយហើយតើ គាត់មិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតទេ មានគេនៅពីលើគាត់ បើតាមរាប់ទៅ១៤នាក់ នៅពីលើគាត់ទៀត។ ទម្រាំដល់ សុន សេន មាន១៤នាក់។

អ៊ីចឹង កូនក្តីខ្ញុំគាត់ឆ្លើយអស់ហើយតើ មេធំបំផុតលើ១៤ហ្នឹង គឺសុន សេន។ សុន សេន បាត់ទៅនៅឆ្នាំ៧៧ សុន សេន ទៅសមរភូមិទៅ នួន ជា។ ហើយចុះកូនក្តីខ្ញុំ ឆ្លើយថា នួន ជា មេធំរបស់គាត់ហើយ ហើយចុះចៅក្រមស៊ើបអង្កេត ដែលជាមានភារកិច្ចក្នុងការស៊ើបអង្កេតដោះបន្ទុកនោះ ម៉េចក៏មិនអញ្ជើញ នួន ជា មកតទល់? ហើយឥឡូវមកពេលនេះ ដល់ពេលមកដល់តុលាការកំពូលហើយ ថាមេធាវីខកខាន។ វាមិនមែនភារកិច្ចអីរបស់មេធាវី។ នេះចំណុចទីបួន។

[១៦:០៩:១៦]

ចំណុចទីប្រាំ សហព្រះរាជអាជ្ញាបានលើកឡើងថា អ្នកណាក៏ដឹងដែរថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ ជារបបមួយដែលគ្មានច្បាប់។ ហើយសូមតុលាការពិចារណាមើល បើវាគ្មានច្បាប់ទៅហើយនោះ របបដែលគ្មានច្បាប់ទៅហើយនោះ អ្នកណាធ្វើអីក៏វាអត់ខុសទេ។ មានអីខុសបើវាអត់មានច្បាប់ផង។ អ៊ីចឹង ឌុច ធ្វើហ្នឹង វាមានខុសអី បើអត់មានច្បាប់។ ខ្ញុំសូមឆ្លើយខ្លីៗ។

ទីប្រាំមួយ ថាមេធាវីលើកពីច្បាប់ដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ហ្នឹង សហព្រះរាជអាជ្ញាសូមបដិសេធចោល។ ព្រោះសហព្រះរាជអាជ្ញាលើកឡើងតែពីច្បាប់អ.វ.ត.ក ទេ។ ខ្ញុំបាទសូមអនុញ្ញាតជម្រាបថា ព្រះរាជអាជ្ញា ជាអ្នកការពារច្បាប់ មិនមែនមេធាវីអ្នកការពារច្បាប់ទេ គឺសហព្រះរាជអាជ្ញាជាអ្នក-- មេធាវីជាអ្នកអនុវត្តច្បាប់ទេ សូមឲ្យអនុវត្តច្បាប់ទេ។

[១៦:១០:២៤]

អ៊ីចឹង ឃើញថា មាត្រា១២៩ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ជាក់ច្បាប់ច្បាស់ណាស់ ថាកាត់ក្តីយុត្តិធម៌ត្រឹមត្រូវនោះ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរតាមនីតិវិធី និងតាមច្បាប់ជាធរមាន។ អ៊ីចឹង ច្បាប់ដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់នោះ ជាច្បាប់នៅជាធរមាន។

ដូច្នេះ ព្រះរាជអាជ្ញា សូមមេត្តាកុំបំពានលើរដ្ឋធម្មនុញ្ញមាត្រា១២៩ នេះ។

ទីប្រាំពីរ សហព្រះរាជអាជ្ញាបានលើកឡើងថា ស-២១ នេះ ជាមន្ទីរសន្តិសុខមជ្ឈិម ឯសន្តិសុខចុងជ្រោយ វាថ្នាក់ស្រុកទេ វាតូចទេ។ ទីមួយ សូមឲ្យតុលាការពិចារណា អាធំនេះ វាធំមែន ស្ថាប័នៗ វាធំ ក៏ប៉ុន្តែអាធំហ្នឹងសម្លាប់តែ ១២.៣៧០នាក់ ទេ។ នុ៎ះ អាតូច នុ៎ះ គ្រាន់តែតូចផង ថ្នាក់ស្រុក វាសម្លាប់ដល់ ១៥០.០០០នាក់។

[១៦:១១:៣៣]

អ៊ីចឹង ព្យសនកម្ម ការខូចខាត ទំហំនៃការឈឺចាប់ ទំហំនៃវិនាសកម្ម អា១២.២៧០នាក់ និង ១៥០.០០០នាក់ អាណាវាឈឺចាប់ជាងអាណា? ម៉េចក៏អានុ៎ង ថានៅក្រៅយុត្តាធិការរបស់អ.វ.ត.ក? សូមមេត្តាពិចារណា។

ហើយមួយទៀត ច្បាប់គេតម្រូវឲ្យយកបុគ្គល ឲ្យយកមនុស្ស ឲ្យយកបុគ្គលមកកាត់ទោស ពីព្រោះបុគ្គលហ្នឹងវាមានធាតុផ្សំរបស់វា គឺធាតុអត្តនោម័តិ វាមានធាតុសត្យានុម័ត ឃើញនែ៎? ឯស្ថាប័ន ធំមែន កំពូលមែន ប៉ុន្តែច្បាប់ ឃើញទេ? គេឲ្យយកអ្នកដឹកនាំណាដែលវាក្នុងយុត្តាធិការរបស់អ.វ.ត.ក។ ហើយអ៊ីចឹង អាស្ថាប័ននេះ វាមិននៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដូចគ្នា ទាំងចុងជ្រោយ ទាំងស-២១។ ពីព្រោះគេមិនត្រូវ ច្បាប់មិនមែនតម្រូវឲ្យយកស្ថាប័នមកកាត់ទោសទេ គេឲ្យយកបុគ្គល អ្នកដែលទទួលខុសត្រូវខ្ពស់បំផុតមកកាត់ទោស។

[១៦:១២:៤៩]

ចំណុចទីប្រាំបី សហព្រះរាជអាជ្ញាលើកឡើងថា មេធាវីថា លើកឡើងនៅក្នុងសវនាការកាលសាលាដំបូងនោះ លើកហើយលើកទៀតថា មិនប្រឆាំងនឹងយុត្តាធិការរបស់ អ.វ.ត.ក ទេ មកដល់ពេលនេះ ក៏មេធាវីនៅតែរក្សាចម្លើយដដែល។ ខ្ញុំឥតប្រឆាំងនឹងយុត្តាធិការរបស់ អ.វ.ត.ក ទេ។ អ.វ.ត.ក ក៏មានសិទ្ធិជំនុំជម្រះទៅលើអ្នកមេដឹកនាំខ្ពស់បំផុត និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម។ ខ្ញុំអត់ប្រកែកទេ ខ្ញុំទទួលស្គាល់។ ក៏ប៉ុន្តែ អ្វីដែលមេធាវីជំទាស់ មេធាវីជំទាស់ទៅលើវិធីសាស្ត្រដែលសហព្រះរាជអាជ្ញា រហូតដល់ចៅក្រមស៊ើបអង្កេត និងសាលាដំបូង ដែលខំឧបកិច្ច ឌុច ដែលមិនមែនជាមេដឹកនាំជាន់ខ្ពស់ ហើយមិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនោះ យកទៅឧបកិច្ចឲ្យមកចូលក្នុងអ្នកដឹកនាំ ដែលមិនមែនអ្នកទទួលខុសត្រូវខ្ពស់បំផុត។ មេធាវីគេប្រឆាំងត្រង់ហ្នឹងទេ សូមស្តាប់ឲ្យច្បាស់។

[១៦:១៣:៥៣]

ចំណុចទីប្រាំបួន សហព្រះរាជអាជ្ញាថា សហព្រះរាជអាជ្ញាមានសិទ្ធិផ្អែកតាមមាត្រា៤០ ក្រមនីតិវិធីព្រហ្មទណ្ឌ។ ខ្ញុំក៏ឯកភាពហើយ ថាមានមែន ព្រះរាជអាជ្ញាទូទៅ វាមានតាមហ្នឹងមែន។ ដោយឡែកព្រះរាជអាជ្ញានៅក្នុង អ.វ.ត.ក យើងនេះ មាត្រា៥ ចំណុចទី៣ និងមាត្រា៦ ចំណុចទី៣ នៃកិច្ចព្រមព្រៀង អ.វ.ត.ក បានកំណត់វិសាលភាពនៃការស៊ើបអង្កេតនៃការចោទប្រកាន់នេះ របស់សហព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេតឲ្យដើរតែក្នុងរង្វង់ហ្នឹង គឺច្បាប់ហ្នឹង គេក្រឹត្យ គេគូសឲ្យដើរតែក្នុងហ្នឹង។ មិនមែនថាលើកអាណាដទៃទៀតមក ចេះតែមានសិទ្ធិដើរទៅចាប់ចង ដើរទៅចោទប្រកាន់ អាក្រៅពីពួកហ្នឹង គឺមិនត្រឹមត្រូវទេ។ ហ្នឹងខ្ញុំបាទទទួលយកមិនបានវិញដែរ កាលណាក្រៅពីអារង្វង់ហ្នឹង។

[១៦:១៤:៥១]

ហើយចំពោះ ចប់ចំពោះសហព្រះរាជអាជ្ញា។ ចំពោះខាងដើមបណ្តឹងរដ្ឋប្បវេណីថាខ្ញុំលើកឡើងថាសម័យនោះគ្មានច្បាប់ ក៏ប៉ុន្តែលោកមេធាវី លើកឡើងតែពាក់កណ្តាលទេ។ ខ្ញុំអត់និយាយប៉ុណ្ណឹងទេ ខ្ញុំលើកឡើងថា សម័យនោះគ្មានច្បាប់ មានតែមាគ៌ារបស់បក្ស មានមាគ៌ារបស់អង្គការដែលទាំងអស់គ្នាគ្មានអ្នកណាមួយអាចល្មើសបាន។ រួចជាក់ស្តែងក្នុងសម័យនោះអ្នកណាល្មើសនឹងមាគ៌ាអង្គការបាន។ ឧទាហរណ៍ តាឌុច នៅស-២១ វន វ៉េត គេបញ្ជូនមក ចៅហ្វាយចាស់គាត់ហើយនេះ ហើយគាត់ជួយចៅហ្វាយចាស់គាត់បានទេ បើមាគ៌ាពីលើមក គេថា មនុស្សហ្នឹងខ្មាំង នឹងអាខែងរបបរបស់គេត្រូវតែកម្ទេស។ មិនដឹងធ្វើម៉េចត្រូវតែកម្ទេច អាហ្នឹងមាគ៌ាវាអ៊ីចឹង វាមាគ៌ារបស់បក្ស។ ខ្ញុំឆ្លើយខ្លីទៅដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណឹង ហើយសូមអនុញ្ញាតឲ្យលោកមេធាវី កង ឫទ្ធារី ឆ្លើយបន្ត។

សូមអរគុណ។

**លោក កង ឫទ្ធារី៖**

សូមអរគុណ ឯកឧត្តមប្រធាន ដែលអនុញ្ញាតឲ្យខ្ញុំបាទឆ្លើយបន្តទៅទៀតចំពោះ ឆ្លើយតបទៅនឹងសេចក្តីថ្លែងហេតុរបស់សហព្រះរាជអាជ្ញាបាទ។

[១៦:១៦:១០]

សហព្រះរាជអាជ្ញាបានប្រើពាក្យច្រើនណាស់ ដែលថាការចោទប្រកាន់លោក កាំង អ៊ាវហ្កេក ហៅ ឌុច ជាប្រធានស-២១ ឲ្យឋិតនៅក្នុងយុត្តាធិការនៃសាលាជម្រះក្តី អ.វ.ត.ក នេះគឺប្រើឆន្ទានុសិទ្ធិ។ ការប្រើប្រាស់ឆន្ទានុសិទ្ធិដោយមិនចង្អុលបង្ហាញនូវបទដ្ឋានច្បាប់ ឬក៏ភស្តុតាងទាញចេញពីអង្គហេតុណាមួយភ្ជាប់ទៅនឹងបទដ្ឋាននោះ គឺជាការរំលោភច្បាប់ទាំងស្រុង គឺរំលោភទៅនឹងមាត្រាទី១៣ នៃសន្ធិ

សញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ គឺការទទួលបាននូវការកាត់ក្តីត្រឹមត្រូវបាននីតិវិធី។ និងមាត្រា៥ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ ដែលចែងថា "ការបកស្រាយច្បាប់របស់ចៅក្រមតាមសទិសភាព ត្រូវបានហាមឃាត់យ៉ាងតឹងរឹងបំផុត"។

ដូច្នេះ ការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់សហព្រះរាជអាជ្ញា ក្នុងការចោទប្រកាន់ដោយលើកយកទទ្ធីករណ៍នៃទំនៀមទម្លាប់អន្តរជាតិពីសេចក្តីសម្រេចចិត្តតុលាការជម្រះក្តីផ្សេង គឺជាកំហុសឆ្គង ហើយសូមឲ្យទាត់ចោលនូវការអំណះអំណាងបែបនេះ។

[១៦:១៧:១៩]

សហព្រះអាជ្ញាក៏បានលើកឡើងដែរថា ស-២១ មានមុខងារបោសសម្អាតផ្ទៃក្នុងតែប៉ុណ្ណោះ ពីព្រោះទទួលបានសុទ្ធតែជាអ្នកទោសដែលមានឋានៈខ្ពស់។ ជាការពិត សហមេធាវីសូមគាំទ្រចំពោះបញ្ហានេះ ហើយក៏បានធ្វើសេចក្តីសន្និដ្ឋានថា ដោយសារតែវាទទួលមុខងារបោសសម្អាតតែផ្ទៃក្នុងបក្សតែប៉ុណ្ណោះ វាមានព្យសនកម្មលើប្រជាជនស្លូតត្រង់តិចជាង ហើយវាមិនមែនជាមុខងាររបស់ អ.វ.ត.ក បច្ចុប្បន្នដែលទៅរកយុត្តិធម៌ឲ្យបក្សកុម្មុយនីស្តកម្ពុជាទេ ពីព្រោះថា មន្ទីរស-២១ មានភារកិច្ចបោសសម្អាតតែខ្មាំងសត្រូវរបស់រដ្ឋទេ *អិនណឹមីអូសស្តេត* (និយាយភាសាអង់គ្លេស) ពីព្រោះឲ្យតែនរណាប៉ុនប៉ងផ្តួលរំលំរដ្ឋាភិបាល គឺបញ្ជូនទៅស-២១ទាំងអស់ លើកលែងតែប្រហែលជាប្រមាណពីប្រាំ ទៅដប់ភាគរយទេដែលជាជនស្លូតត្រង់។

[១៦:១៨:១២]

ផ្ទុយទៅវិញ គុកផ្សេងៗទៀត ដែល១៩៥ គុក ក្នុងនោះ ខ្ញុំលើកតែគុក៩ ដែលសំខាន់ៗ ហើយមានចំនួនតួលេខស្លាប់ សម្លាប់មនុស្សច្រើនជាងស-២១ ដល់ទៅដប់ដង និងតិចបំផុតដល់ទៅពីរដង គឺដូចជា គុក ទីមួយ ចុងជ្រោយ ជាង១០ម៉ឺននាក់ ពី៧ ទៅ ១០ម៉ឺននាក់។ ពោធិ៍ទន្លេ កោះធំ ខេត្តកណ្តាល ៣.៥២៧នាក់។ វត្តអូរត្រកួន កំពង់ចាម កងមាស ៣២.៦៩០នាក់។ បឹងរ៉ៃ ស្វាយរៀង ស្វាយជ្រុំ ២០.០០០ ទៅ ៣០.០០០នាក់។ វត្តកំពង់ត្រឡាច កំពត ២១.១៥១នាក់។ វត្តកាកោះ តាកែវ បាទី ២០.០០០នាក់។ វត្តបារាយជាន់ដែក កំពង់ធំ ១៥.០០០នាក់ ទៅ២០.០០០នាក់។ វត្តព្រះធាតុស្វស្តិ៍ តាកែវ បុរីជលសា ១៥.០០០នាក់ ទៅ១៧.០០០នាក់។ វត្តគីរីរម្យ បាត់ដំបង បាណន់ ១៥.៧០០នាក់។ ឯ ស-២១ ហៅ គុកទួលស្លែង ភ្នំពេញ ដង្កោ តែ១ម៉ឺន-- តាមតួលេខនេះគឺ ១៤.០០០ ទៅ ១៥.០០០នាក់ គឺតិចជាងគេ។ តិចជាងគេ ហើយមុខងារគាត់តូចទៀត គឺសម្លាប់តែកម្មាភិបាលផ្ទៃក្នុង និងបណ្តា

កងទ័ពដែលប្រឆាំងវិន័យរបស់របបកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះទេ។

[១៦:១៩:៣៥]

ឯគុកដែលខ្ញុំបាទរៀបរាប់អម្បាញ់មិញនេះ មានតួលេខសម្លាប់មនុស្សច្រើនហ្នឹង គឺសម្លាប់មនុស្សពីរក្រុម គឺ សត្រូវអង្គការ ឬសត្រូវរបស់រដ្ឋហ្នឹងមួយ។ ទីពីរ គឺសត្រូវ *អិនណឹមីអូសក្លាស* (និយាយភាសាអង់គ្លេស) គឺសត្រូវវណ្ណៈ គឺប្រជាជនស៊ីវិលហ្នឹងឯង ដែលគេចោទថា ជាមន្ត្រីរាជការសង្គមចាស់ នាយទុនសក្តិភូមិ *កុងប្រាដ័* អីនោះបាទ! ជាពិសេសពួកអ្នក១៧ មេសា ហ្នឹងតែម្តង។

ហេតុនេះព្យសនកម្មរបស់មន្ទីរឃុំឃាំងផ្សេងៗទៀត ដូចជា ចុងជ្រោយ ហ្នឹងធំណាស់ មិនមែនតូចទេ។ ធំជាងគុកទួលស្លែងទៅទៀត។ គុកទួលស្លែងដែនវិសាលភាពវាលើដែនដីធំមែនទូទាំងប្រទេស ប៉ុន្តែ ដែនវិសាលភាពវាលើបុគ្គលគឺតូចទេ។ ផ្ទុយទៅវិញ គុកតាមភូមិភាគ ដែលខ្ញុំរៀបរាប់តែដប់អម្បាញ់មិញនេះ គឺថាវាមានវិសាលភាពលើបុគ្គលធំជាងស-២១ ទៅទៀត។

[១៦:២០:២៧]

សហព្រះរាជអាជ្ញាប្រើពាក្យថា ខ្លួនប្រើឆន្ទានុសិទ្ធិក្នុងការកំណត់ថា កាំង អ៊ាវហ្គេក ហៅ ឌុច ថាឋិតនៅក្នុងយុត្តាធិការនៃ អ.វ.ត.ក គឺបានរំលោភអំណាច ដោយពុំបានចង្អុលបង្ហាញពីភស្តុតាងជាក់លាក់ណាមួយ ដែលភ្ជាប់ទៅនឹងមាត្រា១ មាត្រា២ នៃ អ.វ.ត.ក ទេ ពីព្រោះថា ពាក្យថា ក្រុមមេដឹកនាំជាន់ខ្ពស់របស់របបកម្ពុជាប្រជាធិបតេយ្យ មិនប្រាកដជាត្រូវបានទទួលយកដោយសាលាជម្រះក្តីអ.វ.ត.ក ទេ ពីព្រោះថា ក្នុងចំណោមមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យខ្លះ ក៏មានអ្នកខ្លះមិនមានពាក់ព័ន្ធនឹងឧក្រិដ្ឋដែរ នេះជាពាក្យប្រារព្ធនៅក្នុងសេចក្តីផ្តើមរបស់អង្គការសហប្រជាជាតិ។ របាយការណ៍របស់អ្នកជំនាញការអង្គការសហប្រជាជាតិ ដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិ។ ហើយគឺមានតែពួកអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្មប៉ុណ្ណោះ ដែលត្រូវបានចងភ្ជាប់ទៅនឹងពួកមេដឹកនាំជាន់ខ្ពស់។ បានន័យថា ក្រុមអ្នកមេដឹកនាំជាន់ខ្ពស់របស់របបកម្ពុជាប្រជាធិបតេយ្យហើយ បានប្រព្រឹត្តឧក្រិដ្ឋកម្មទៅទៀតៗទើបគេចាត់ទុកថា ជាក្រុមមេដឹកនាំ-- ជាក្រុមទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម។ នេះជាការកំណត់និយមន័យខុសរបស់សហព្រះរាជអាជ្ញា ជាដើមហេតុធ្វើឲ្យការដាក់ភស្តុតាងមិនបានសមរម្យល្អទៅដល់អង្គជំនុំជម្រះ ធ្វើឲ្យអង្គជំនុំជម្រះមានការភាន់ច្រឡំលើយុត្តាធិការ។

[១៦:២១:៥០]

ទីពីរទៀត ភារកិច្ចនៃការពិនិត្យលើដែនយុត្តាធិការរបស់អង្គជំនុំជម្រះ អ.វ.ត.ក មិនមែនពឹង

ផ្អែកតែទៅលើសេចក្តីសន្និដ្ឋានរបស់សហមេធាវីទេ គឺសហព្រះរាជអាជ្ញានិងអង្គជំនុំជម្រះ គឺក្រុមប្រឹក្សាជំនុំជម្រះត្រូវពិនិត្យដោយខ្លួនឯងផងដែរ ទាំងយុត្តាធិការលើបទល្មើស និងទាំងយុត្តាធិការលើបុគ្គល។ បាទ, មិនចាំបាច់មានការទាមទារឲ្យគេពិនិត្យទេ។ មិនចាំបាច់ទាមទារឲ្យសហមេធាវីលើកឡើងទេ គឺខ្លួនឯងជាអ្នកពិនិត្យតែម្តង តើក្រុមប្រភេទណាខ្លះថាជាក្រុមជនសង្ស័យត្រូវបានចោទប្រកាន់ និងក្រុមណាដែលមិនគួរចោទប្រកាន់? ហើយការលើកឡើងរបស់សហមេធាវីថា ជាការលើកឡើងយឺតពេល គឺជារឿងមិនអាចទទួលយកបានទេ សុំទាត់ចោល។ ពីព្រោះថា ការលើកឡើងរបស់ សេចក្តីសន្និដ្ឋានរបស់សហមេធាវីការពារជនជាប់ចោទ គឺតាមនីតិវិធី គឺឲ្យលើកឡើងក្រោយគេបង្អស់។ អ៊ីចឹង ចុងបញ្ចប់នៃសវនាការ ទើបឲ្យគាត់ធ្វើសេចក្តីសន្និដ្ឋាន។ ពេលនោះភស្តុតាងបានលេចឡើងដែរ។ ភស្តុតាងដោះបន្ទុកនៅលើយុត្តាធិការឋានៈបុគ្គលបានលេចឡើងនៅពេលនោះ។

ដូច្នេះ គាត់មានសិទ្ធិសន្និដ្ឋាននៅពេលនោះដែរ។ ដូច្នេះវាមិនមែនជាការលើកឡើងយឺតពេលទេ។ សេចក្តីសន្និដ្ឋានរបស់មេធាវីពឹងផ្អែកទាំងស្រុងទៅលើរាល់ភស្តុតាងទាំងអស់ តាមវិធាន៨៧ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ភស្តុតាងត្រូវបានដាក់ដោយភាគី គ្រប់ភាគីទាំងអស់ ហើយអាចទទួលយកបានគ្រប់ពេលវេលា។ ដូច្នេះ គេមិនអាចយកវិធាន៨៩ មកទាត់ចោលវិធាន៨៧ នេះបានទេ។

[១៦:២៣:១៩]

សេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទៀតថា គុកនេះជាគុកមជ្ឈិម។ ស-២១ ជាគុកមជ្ឈិម។ ខ្ញុំសូមទទួលស្គាល់។ កាំង ហ្គេកអ៊ាវ ហៅ ឌុច គាត់នៅខាងក្រោយនេះ គាត់មិនបានឆ្លើយបដិសេធម្តងណាទេ អំពីឧក្រិដ្ឋកម្មកើតនៅគុកទួលស្លែង ហើយគាត់ក៏មិនដែលឆ្លើយថា គុកនេះជាគុករបស់ភូមិភាគដែរ វាគុករបស់មជ្ឈិម។ ជាគុករបស់មជ្ឈិម ហើយជាគុកសម្ងាត់យោធាទៀត ពីព្រោះគ្រប់គ្រងពីដើមមកដោយ៧០៣ កងពល៧០៣ ដោយ ណាត។ អ៊ិន លន ហៅ ណាត ដែលជាអតីតប្រធាន ហើយក៏ជាជនរងគ្រោះនៃស-២១ ហ្នឹងដែរ។ ដោយសារតែវាគុកមជ្ឈិមហ្នឹងហើយ បានជាមានមនុស្សពីមជ្ឈិមចុះមកគ្រប់គ្រង។ មនុស្សពីមជ្ឈិមមកគ្រប់គ្រង ដូចដែលខ្ញុំបានលើករួចហើយ មានពីរខ្សែ មួយខ្សែបក្សពីរខ្សែរដ្ឋាភិបាល។

[១៦:២៤:០១]

ខ្សែបក្ស គឺមានខាង ប៉ុល ពត។ ហ្នឹងគឺបញ្ជូនមនុស្សមួយក្រុមគឺ ស-៧១ មាន ប៉ង់ ហើយនិងលីន ដែលគ្រប់គ្រងមានគុកផ្ទាល់ខ្លួនឯងមួយទៀតនៅវត្តបុទុម សម្រាប់បោសសម្អាតខ្មាំងសត្រូវណា

ដែលប្រឆាំងនឹង ប៉ុល ពត ផ្ទាល់។ ឯខាង-- ហើយនិងគណៈកម្មាធិការអចិន្ត្រៃយ៍ ក្នុងការសម្រេចបញ្ជូនមនុស្សមក ខាងខ្មែរបក្សមាន ប៉ង់ មាន លើន ហើយនិងមានគណៈអចិន្ត្រៃយ៍របស់មជ្ឈិមបក្ស របស់បក្សកុម្មុយនីស្តកម្ពុជា។ ឯខ្មែរខាងរដ្ឋាភិបាលមានគណៈយោធាមជ្ឈិម ហើយសមាជិកគណៈយោធាមជ្ឈិម មានចុះក្នុងសំណុំរឿងហើយ ខ្ញុំមិនលើកក្នុងពេលនេះទេដើម្បីកុំឲ្យខាតពេលវេលា។ ហើយនិងមន្ទីរសេនាធិការកងទ័ព ដែលមាន សុន សេន ជាប្រធាន ហើយក្រុមប្រធានមន្ទីរសេនាធិការកងទ័ពយើងមានអស់ហើយ មានចំណុះកងពលច្រើណាស់ ដែលក្នុងហ្នឹង មាន សៀត ឆែ ហៅ ទុំ មានឈ្មោះរឿង មាន មាស មុត, ស៊ូ ម៉េត ។ល។ ដូច្នេះ មានមនុស្សមួយក្រុមទៀតនៅពីលើគាត់។ តែ សុន សេន ចុះមកក្តាប់គុកនេះផ្ទាល់ ក្រៅពីហ្នឹងមានអ្នកត្រួតពិនិត្យទូទៅទៀត។ មួយទៀតគឺ នួន ជា មុនពេលដែល នួន ជា ជំនួសឲ្យ សុន សេន គឺ នួន ជាខ្លួនឯងហ្នឹង ជាអ្នកត្រួតពិនិត្យបទបញ្ជាមកលើស-២១ ហ្នឹងទៀត។ ហេតុនេះសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាត្រឹមត្រូវបាន៥០ភាគរយត្រង់ហ្នឹងឯង ត្រង់ថាគាត់ថាជាគុកមជ្ឈិម។ យើងក៏ឯកភាពជាមួយ ប៉ុន្តែគាត់សន្និដ្ឋានថា កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនៅស-២១ នោះហើយជាការភ័ន្តច្រឡំ។

[១៦:២៥:៣០]

មន្ទីរសន្តិសុខផ្សេងៗទៀត សេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា យើងក៏បានឯកភាពដែរថា មន្ទីរសន្តិសុខផ្សេងៗទៀតនៅតាមភូមិភាគ គឺវាឯករាជ្យជាការពិត វាឯករាជ្យ។ ហើយគាត់គាត់និយាយថា វាមានឋានៈ វាមានតួនាទីតូចជាងស-២១ នេះហើយដែលយើងជំទាស់។ ពីព្រោះថា សូម្បីតែ សុន សេន ក៏មិនអាចលូកដៃទៅលើមន្ទីរសន្តិសុខនៃតាមភូមិភាគបានដែរ គឺមានតែអចិន្ត្រៃយ៍ភូមិភាគទេ លើកលែងតែ ប៉ុល ពត ម្នាក់គត់ដែលមានសិទ្ធិគ្រប់គ្រងលើភូមិភាគតមកទៀត។ គេរាយការណ៍មកមិនមែនរាយការណ៍ពីសន្តិសុខពីតាមភូមិភាគមិនមែនរាយការណ៍មកឲ្យ សុន សេន ទេ គឺរាយការណ៍ឲ្យ ប៉ុល ពត បាន ប៉ុល ពត ទម្លាក់បទបញ្ជាហ្នឹង រឿងខ្លះត្រូវទទួលយកពីភូមិភាគមក បានជាយើងឃើញថា មានវត្តមានអ្នកទោសតាមភូមិភាគហ្នឹង។ គឺដោយសារបញ្ជា ប៉ុល ពត ៗបញ្ជាឲ្យ សុន សេន ទៅទទួលយកអ្នកទោសហ្នឹង ឬក៏សម្រេចយ៉ាងណាជាមួយហ្នឹងភូមិភាគ។ សុន សេន គ្មានសិទ្ធិទៅទៀតត្រួតត្រាលើភូមិភាគ ជាពិសេសយើងឃើញប្រតិចារឹករបស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ហើយគឺភូមិភាគនិរតី គាត់មិនដែលទទួលបានម្នាក់ទេ ពីព្រោះអី? ពីព្រោះ តាម៉ុក ជាអចិន្ត្រៃយ៍របស់លេខាបក្សនិរតី មានអំណាចខ្លាំងណាស់។ អស់លោកទាំងឡាយជាជនជាតិខ្មែរ ដែលមានវត្តមានទីនេះអស់

លោកក៏ដឹងដែរ ជាពិសេសសហចៅក្រមកម្ពុជា សហព្រះរាជអាជ្ញាកម្ពុជា លោកបានដឹងហើយថា ភូមិភាគនិរតីធ្វើបាបយ៉ាងម៉េចខ្លះ ចំពោះភូមិភាគបូព៌ា ភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យ។

នេះជាការបែងចែកអំណាច ហើយបើយើងពិនិត្យមើលលើភស្តុតាងប្រកបដោយស្តង់ដារ ហើយ និងដែលដាក់ដោយការិយាល័យសហព្រះរាជអាជ្ញាខ្លួនឯង គឺកិច្ចប្រជុំសម្ងាត់ សេចក្តីសម្រេចចិត្តសម្ងាត់ របស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ចុះថ្ងៃទី៣០ មីនា ឆ្នាំ១៩៧៦ យើងអត់សង្ស័យទេ ថាអ្នកណាខ្លះត្រូវ ភ្ជាប់ដោយមាត្រា១ និងមាត្រា២ នៃ អ.វ.ត.ក។

បាទ សូមអរគុណ។ សូមចប់តែប៉ុណ្ណេះ ចំពោះការឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញា។

[១៦:២៧:១៧]

ឆ្លើយតបទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំសូមទាត់ចោលទាំងស្រុងចំពោះសេចក្តីសន្និដ្ឋាន របស់ដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះវាប្រឆាំងទៅនឹងមាត្រា២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ត្រង់ កថាខណ្ឌ៣ ថា "បណ្តឹងអាជ្ញានិងបណ្តឹងរដ្ឋប្បវេណី ជាបណ្តឹងពីរផ្សេងពីគ្នា។ បណ្តឹងអាជ្ញាមានគោល បំណង និងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឲ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះ តាមច្បាប់កំណត់។ បណ្តឹងរដ្ឋប្បវេណី មានគោលបំណងធ្វើឲ្យជួសជុលការខូចខាតដែលបណ្តាលមក ពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះឲ្យអ្នករងគ្រោះបានទទួលសំណងជំងឺចិត្តថ្នូន ល្មមនឹងព្យសនកម្មដែលខ្លួនបានទទួល"។ បានន័យថា គាត់ធ្វើសេចក្តីសន្និដ្ឋានឆ្លើយតបមក ឬប្តឹងទាមទារ តែលើសំណងរដ្ឋប្បវេណីទេ។ ឯបណ្តឹងអាជ្ញាត្រូវធ្វើឡើងដោយសហព្រះរាជអាជ្ញា។ ដូច្នេះ ខ្ញុំមិន អាចទទួលយកបានរាល់សេចក្តីសន្និដ្ឋាន សូម្បីតែមួយមាត់ អំពីភាគីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ ថា លើបញ្ហាថា កាំង ហ្កេកអ៊ាវ ហៅ ឌុច ហ្នឹងមានឋិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ឬអត់ មិនមាន ជាភារកិច្ចរបស់អស់លោកទេ។

បាទ សូមអរគុណ សូមបញ្ចប់ត្រឹមប៉ុណ្ណេះ។

[១៦:២៨:៤២]

**ប្រធានអង្គជំនុំ៖**

អ៊ីចឹង នាពេលថ្ងៃនេះ គឺយើងបញ្ចប់ដល់ការឆ្លើយតបរបស់សហមេធាវីការពារជនជាប់ចោទ។ អ៊ីចឹង អង្គជំនុំជម្រះតុលាការកំពូលប្រកាសផ្អាកសវនាការនាពេលនេះ ហើយបន្តនៅថ្ងៃស្អែក ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១១ នៅវេលាម៉ោងប្រាំបួនព្រឹក។ អ៊ីចឹង បង្គាប់ឲ្យមន្ត្រីពន្ធនាគារ នាំជនជាប់ចោទទៅមន្ទីរ

ឃុំឃាំងវិញ ហើយស្អែកនឹងបង្គាប់ឲ្យនាំជនជាប់ចោទ ចូលសវនាការនៅថ្ងៃទី២៩ ខែ៣ ឆ្នាំ២០១១ នៅវេលាម៉ោងប្រាំបួនព្រឹក៕

**លោក ផន ធឿន៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:៣០ នាទី)*